សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និង វិទ្យាសាស្ត្រសេដ្ឋកិច្ច

Université Royale Droit et des Science Economiques

Royal University of Law and Economics

## សារណាបញ្ចប់ការសិក្សា

# បត្យាប័ន

ស្រាវជ្រាវចាប់ពីថ្ងៃទី០៣ ខែមេសា ឆ្នាំ២០២៣ ដល់ថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០២៣

ស្រាវជ្រាវដោយ

និស្សិតឈ្មោះ លោក **ឡុក ដាវីត**

កញ្ញា **ម៉េង ហេងលីម**

ណែនាំដោយ

លោក **ជួន ប៊ុនធី**

ថ្នាក់បរិញ្ញាបត្រ **នីតិសាស្ត្រ**

ជំនាន់ទី២៣

ឆ្នាំចូលសិក្សា ២០១៩

ឆ្នាំសរសេរសារណា ២០២៣

# សេចក្តីថ្លែងអំណរគុណ

ខ្ញុំបាទ **ឡុក ដាវីត** និងនាងខ្ញុំ **ម៉េង ហេងលីម** ជានិស្សិតថ្នាក់បរិញ្ញាបត្រ ផ្នែកនីតិសាស្ត្រ ឆ្នាំទី៤ នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ឆ្នាំសិក្សា ២០២២-២០២៣។

**សូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅជូនចំពោះ**

លោកឪពុកឈ្មោះ **ឡុក ចាន់ធី**, អ្នកម្ដាយឈ្មោះ **គឹម វណ្ណឌី** និង លោកឪពុកឈ្មោះ **លន់ មាន**, អ្នកម្ដាយឈ្មោះ **ឃុំត ស៊ាងអួន** ដែលបានខិតខំប្រឹងប្រែង និងលះបង់អស់ពីកម្លាំងកាយចិត្តក្នុងការចិញ្ចឹមបីបាច់ថែរក្សា និងអប់រំកូនឱ្យក្លាយជាពលរដ្ឋល្អ ព្រមទាំងជួយឧបត្ថម្ភកូនឱ្យបានទទួលនូវការសិក្សា ចំណេះដឹង និងពុទ្ធិដ៏គាប់ប្រសើរ ដើម្បីជាស្ពានឈានទៅរកការបំពេញការងារចិញ្ចឹមជីវិត និងដើម្បីបម្រើប្រយោជន៍របស់ប្រទេសជាតិយើងទៅថ្ងៃខាងមុខ។

**សូមគោរព និងថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅទៅដល់**

**ឯកឧត្តម លុយ ចណ្ណា** សាកលវិទ្យាធិការនៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ព្រមទាំងសាកលវិទ្យាធិការរង គណៈគ្រប់គ្រង រួមទាំងលោកគ្រូ អ្នកគ្រូ សាស្ត្រាចារ្យ និងបុគ្គលិកនៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ចទាំងអស់ដែលបានខិតខំអស់ពីសមត្ថភាពក្នុងការដឹកនាំ គ្រប់គ្រង សម្របសម្រួលក៏ដូចជាបង្ហាត់បង្រៀនក្នុងគោលបំណងដើម្បីបណ្ដុះបណ្ដាលនូវធនធានមនុស្សដ៏ល្អប្រពៃដែលជាទំពាំងស្នងឬស្សីជម្រុញឲកម្ពុជាមានការអភិវឌ្ឍទៅថ្ងៃមុខ។

**ហើយក៏សូមធ្វើការសម្តែងនូវការអរគុណជូនចំពោះ**

**លោក ជួន ម៉ុនធី** ដែលជាសាស្ត្រាចារ្យណែនាំក្នុងការសរសេរសារណាបញ្ចប់ការសិក្សារបស់ពួកយើងខ្ញុំដែលបានចំណាយនូវពេលវេលាដ៏មានតម្លៃក្នុងការបណ្ដុះបណ្ដាល ណែនាំ និងតម្រង់ទិសដល់ក្រុមយើងខ្ញុំព្រមទាំងការផ្ដល់យោបល់ និងការកែលំអរចំណុចខ្វះខាតក្នុងការសរសេរសារណានេះ។ ទោះបីជាមានជួបនូវឧបសគ្គជាច្រើនក្នុងការសរសេរក៏ដោយក៏លោកគ្រូតែងតែលើកទឹកចិត្ត និងណែនាំអំពីចំណុចខ្វះខាតដោយផ្ដល់ការពន្យល់យ៉ាងក្បោះក្បាយ និងច្បាស់លាស់ដល់ក្រុមយើងខ្ញុំ។ ពួកខ្ញុំពិតជាមានសេចក្ដីសោមនស្សរីករាយដែលមានលោកគ្រូជាសាស្ត្រាចារ្យណែនាំសារណាសម្រាប់ក្រុមយើងខ្ញុំ។

ឆ្លៀតពេលនេះដែរយើងខ្ញុំទាំងពីរសូមប្រសិទ្ធិពរជ័យ សិរីមង្គល និងពុទ្ធពរទាំងបួនប្រការគឺ អាយុ វណ្ណៈ សុខៈ ពលៈ កុំបីឃ្លៀងឃ្លាតឡើយ ជូនចំពោះលោកអ្នកមានគុណ ថ្នាក់ដឹកនាំ សាស្ត្រាចារ្យណែនាំ លោកគ្រូ អ្នកគ្រូ និងមិត្តភក្តិទាំងអស់ព្រមទាំងសមាជិកក្រុមដែលបានផ្ដល់ជាកម្លាំងកាយចិត្តក្នុងការសម្រេចនូវសារណាបញ្ចប់ការសិក្សានេះ។

# **អារម្ភកថា**

ក្រោយពីទទួលបានការសិក្សាថ្នាក់បរិញ្ញាបត្រ នីតិសាស្ត្រ រយៈពេលបីឆ្នាំនៅសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ចកន្លងមកយើងខ្ញុំទទួលបាននូវចំណេះដឹងជាច្រើនឥតគណនា ចាប់ពីមូលដ្ឋានច្បាប់រហូតដល់ចំណេះជំនាញច្បាប់ ជាពិសេសពួកយើងបានទទួលនូវចំណេះដឹងពាក់ព័ន្ធនឹងការសរសេរសារណាដែលជាហេតុធ្វើឱ្យពួកយើងមានលទ្ធភាពក្នុងការសរសេរសារណាដើម្បីបញ្ចប់ការសិក្សាថ្នាក់បរិញ្ញាបត្រនីតិសាស្ត្រនេះ។

ដោយផ្អែកលើសមត្ថភាព និងចំណេះដឹងដែលយើងខ្ញុំមាន ពួកយើងសម្រេចយកប្រធានបទស្តីពី "**បត្យាប័ន**" ដើម្បីធ្វើជាប្រធានបទដើម្បីសរសេរជាសារណាបញ្ចប់ការសិក្សារបស់យើងខ្ញុំ។

សារណារនេះធ្វើឡើងក្នុងគោលបំណងធ្វើការសិក្សាស្រាវជ្រាវឱ្យបានស៊ីជម្រៅពាក់ព័ន្ធនឹងបត្យាប័ន និងសម្រាប់ឱ្យមិត្តអ្នកអានក៏ដូចជា សិស្ស និស្សិតទាំងអស់យល់ឱ្យកាន់តែច្បាស់អំពីចំណេះដឹងផ្សេងៗទាក់ទងនឹងបត្យាប័ននេះ។

យើងខ្ញុំសូមខន្តីអភ័យទោសទុកជាមុនពីសំណាក់សាស្ត្រាចារ្យ សិស្ស និស្សិត និងមិត្តអ្នកអានទាំងអស់នូវរាល់កំហុសឆ្គងដោយប្រការណាមួយចំពោះខ្លឹមសារដែលបានបកស្រាយអក្ខរាវិរុទ្ធនៅក្នុងកិច្ចការស្រាវជ្រាវនេះហើយយើងខ្ញុំរង់ចាំទទួលការរិះគន់ពីសំណាក់មជ្ឈដ្ឋានទាំងអស់ដើម្បីស្ថាបនា និងកែលំអស្នាដៃស្រាវជ្រាវ យើងខ្ញុំនេះឱ្យកាន់តែប្រសើរឡើងមួយកំរិតទៀត ។

# មាតិកា

**ទំព័រ**

**សេចក្តីផ្តើម** ...... **១**

## ជំពូកទី ១

## សញ្ញាណទូទៅនៃបត្យាប័ន

**១.អត្ថន័យ និងពាក្យគន្លឹះ** ...... **៤**

១.១.អត្ថន័យនៃបត្យាប័ន ...... **៤**

១.២.ពាក្យគន្លឹះផ្សេងទៀតដែលពាក់ព័ន្ធនឹងបត្យាប័ន ...... **៤**

**២.របបគតិយុត្តនៃបត្យាប័ន** ...... **៥**

២.១.រដ្ឋធម្មនុញ្ញ ...... **៥**

២.២.សន្ធិសញ្ញាគំរូរបស់អង្គការសហប្រជាជាតិ ...... **៥**

២.៣.សន្ធិសញ្ញាបត្យាប័នរវាងរដ្ឋកម្ពុជាជាមួយរដ្ឋបរទេស ...... **៥**

២.៤.ក្រមនីតិវិធីព្រហ្មទណ្ឌ ...... **៥**

**៣.ក្រសួង ស្ថាប័នដែលមានសមត្ថកិច្ចពាក់ព័ន្ធនឹងបត្យាប័ន** ...... **៦**

៣.១.ក្រសួងយុត្តិធម៌ ...... **៦**

៣.២.ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ...... **៧**

៣.៣. សាលាឧទ្ធរណ៍ ...... **៨**

## ជំពូកទី ២

## ក្របខណ្ឌ លក្ខខណ្ឌ និងមោឃភាពនៃបត្យាប័ន

**១.ក្របខណ្ឌនៃការធ្វើបត្យាប័ន** ...... **១០**

១.១.បត្យាប័នក្នុងករណីមានសន្ធិសញ្ញា ...... **១១**

ក.សន្ធិសញ្ញាស្តីពីបត្យាប័ន រវាងព្រះរាជាណាចក្រកម្ពុជា និងព្រះរាជាណាចក្រថៃ ...... **១១**

ខ.សន្ធិសញ្ញាស្តីពីបត្យាប័ន រវាងព្រះរាជាណាចក្រកម្ពុជា និងសាធារណរដ្ឋប្រជាមានិតចិន...... **១២**

គ.សន្ធិសញ្ញា ស្តីពីបត្យាប័ន រវាងព្រះរាជាណាចក្រកម្ពុជា និងសាធារណរដ្ឋប្រជាមានិតឡាវ ...... **១២**

ឃ.កិច្ចព្រមព្រៀងស្តីពីបត្យាប័ន រវាងព្រះរាជាណាចក្រកម្ពុជា និងសាធារណរដ្ឋកូរ៉េ........................១២
ង.សន្ធិសញ្ញាស្តីពីបត្យាប័ន រវាងព្រះរាជាណាចក្រកម្ពុជា និងសាធារណរដ្ឋសង្គមនិយមវៀតណាម..១២
ច.អនុសញ្ញាស្តីពីបត្យាប័ន រវាងព្រះរាជាណាចក្រកម្ពុជា និងសាធារណរដ្ឋបារាំង ........................១៣
ឆ.សន្ធិសញ្ញាស្តីពីបត្យាប័ន រវាងព្រះរាជាណាចក្រកម្ពុជា និងសហព័ន្ធរុស្ស៊ី................................១៣
១.២.បត្យាប័នក្នុងករណីមិនមានសន្ធិសញ្ញា...................................................................... ១៤
១.៣.ក្របខណ្ឌនៃបត្យាប័នដែលមានចែងក្នុងច្បាប់ពិសេស ................................................. ១៤
ក.ច្បាប់ស្តីពីការប្រឆាំងនឹងភេរវកម្ម ............................................................................. ១៤
ខ.ច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ......................................................................... ១៥
**២.លក្ខខណ្ឌនៃការធ្វើបត្យាប័ន**.......................................................................................១៥
២.១.លក្ខខណ្ឌទាក់ទងនឹងបទល្មើស ................................................................................ ១៥
២.២.លក្ខខណ្ឌទាក់ទងនឹងបុគ្គលដែលត្រូវធ្វើបត្យាប័ន ........................................................ ១៧
២.៣.លក្ខខណ្ឌទាក់ទងនឹងទីកន្លែងប្រព្រឹត្តបទល្មើស ......................................................... ១៧
២.៤.លក្ខខណ្ឌទាក់ទងនឹងទោសដាក់ពន្ធនាគារ ................................................................. ១៩
២.៥.លក្ខខណ្ឌទាក់ទងនឹងពាក្យសុំធ្វើបត្យាប័ន....................................................................២០
**៣.មោឃភាពនៃបត្យាប័ន** ............................................................................................... ២០
៣.១.បណ្តឹងមោឃភាព.......................................................................................................២០
៣.២.អនុភាពមិនផ្អាកនៃបណ្តឹងសុំមោឃភាព.........................................................................២០
៣.៣.អនុភាពនៃមោឃកម្មចំពោះបត្យាប័ន............................................................................២១

## ជំពូកទី ៣
## នីតិវិធីបត្យាប័ន

**១.គោលការណ៍កម្រិតក្នុងការធ្វើបត្យាប័ន**..........................................................................២២
១.១.អំពើដែលមានលក្ខណៈនយោបាយ...............................................................................២២
១.២.អំពើដែលត្រូវបានប្រព្រឹត្តលើដែនដីនិងដែលត្រូវបានផ្តន្ទាទោសជាស្ថាពររួចហើយ ...................... ២៣

១.៣.ការរលត់បណ្តឹងអាជ្ញា ........ ២៤
ក.មរណភាពនៃជនល្មើស ........ ២៥
ខ.ការផុតអាជ្ញាយុកាល ........ ២៥
គ.ការលើកលែងទោសទូទៅ ........ ២៥
ឃ.និរាករណ៍នៃច្បាប់ព្រហ្មទណ្ឌ ........ ២៦
ង.អាជ្ញាអស់ជំនុំ ........ ២៧
**២.នីតិវិធីបត្យាប័នក្នុងករណីដែលព្រះរាជាណាចក្រកម្ពុជាជារដ្ឋទទួលសំណើ** ........ ២៨
២.១.នីតិវិធីពាក់ព័ន្ធនឹងពាក្យសុំ ........ ២៨
២.២.នីតិវិធីចាប់ខ្លួន និងការឃុំខ្លួនចំពោះបុគ្គលដែលគេទាមទារ ........ ២៩
២.៣.នីតិវិធីនៅដំណាក់កាលសភាស៊ើបសួរ ........ ៣០
២.៤.នីតិវិធីក្រោយផ្តល់បត្យាប័ន ........ ៣១
**៣.នីតិវិធីបត្យាប័នក្នុងករណីដែលព្រះរាជាណាចក្រកម្ពុជាជារដ្ឋដាក់សំណើ** ........ ៣២
៣.១.សំណើបត្យាប័ន ........ ៣២
៣.២.សំណើសុំឱ្យចាប់ខ្លួនបណ្តោះអាសន្ន ........ ៣៤
៣.៣.នីតិវិធីនៅដំណាក់កាលសភាស៊ើបសួរ ........ ៣៥
៣.៤.និតិវិធីក្រោយផ្តល់បត្យាប័ន ........ ៣៦
ក.ការប្រគល់ជនដែលត្រូវស្នើសុំ ........ ៣៦
ខ.ការប្រគល់ទ្រព្យសម្បត្តិ ........ ៣៧
**សេចក្តីសន្និដ្ឋាន** ........ ៣៨
**អនុសាសន៍** ........ ៤០
**ឯកសារយោង**
**បញ្ជីឧបសម្ព័ន្ធ**

# សេចក្តីផ្តើម

# សេចក្តីផ្តើម

## ១.លំនាំបញ្ហានៃកិច្ចការស្រាវជ្រាវ

បច្ចុប្បន្នពិភពលោកមានការរីកចម្រើន និងអភិវឌ្ឍន៍ជឿនលឿនគ្រប់ទិសទី ហើយបច្ចេកវិទ្យាក៏មានការរីកចម្រើនផងដែរជាហេតុធ្វើឱ្យជនល្មើសងាយស្រួលក្នុងការរត់គេចខ្លួន និងជ្រកកោននៅប្រទេសមួយផ្សេងទៀតដែលជាឧបសគ្គក្នុងការអនុវត្តច្បាប់ឱ្យមានប្រសិទ្ធិភាព។ ដើម្បីដោះស្រាយបញ្ហានេះ និងដើម្បីធានាប្រសិទ្ធិភាពនៃការអនុវត្តច្បាប់ ព្រមទាំងបង្កើនកិច្ចសហប្រតិបត្តិការផ្លូវច្បាប់ជាមួយប្រទេសផ្សេងៗក្នុងតំបន់ និងនៅលើពិភពលោក ការធ្វើបត្យាប័នជានីតិវិធីមួយដ៏មានសារៈសំខាន់បំផុត។

ចំពោះសារបាននៃច្បាប់ធ្វើបត្យាប័ននៅកម្ពុជាត្រូវបានចាប់ផ្តើមក្នុងសម័យអាណានិគមបារាំង (១៨៦៣-១៩៥៣) ដែលប្រព័ន្ធច្បាប់របស់ប្រទេសកម្ពុជាត្រូវបានរងឥទ្ធិពលយ៉ាងខ្លាំងដោយច្បាប់បារាំងដែលបានរួមចំណែកដល់ការបង្កើតក្របខណ្ឌច្បាប់ផ្លូវការសម្រាប់ការធ្វើបត្យាប័ន។

ឆ្លងកាត់រយៈពេលនៃរបបខ្មែរក្រហម (១៩៧៥-១៩៧៩) ប្រទេសកម្ពុជាស្គាល់នូវប្រវត្តិសាស្ត្រដ៏ជូរចត់ និងខ្មៅងងឹតដែលក្នុងអំឡុងពេលនោះប្រព័ន្ធច្បាប់របស់ប្រទេសត្រូវបានខូចខាតយ៉ាងធ្ងន់ធ្ងរ។

ក្រោយរយៈពេលនេះ កម្ពុជាបានចាប់ផ្តើមដំណើរការកំណែទម្រង់ច្បាប់ និងការកសាងឡើងវិញដែលរួមមានការតាក់តែងរដ្ឋធម្មនុញ្ញថ្មីនៅឆ្នាំ១៩៩៣ ព្រមទាំងចាប់ផ្តើមអនុវត្តនូវការធ្វើបត្យាប័នវិញតាមរយៈការចុះសន្ធិសញ្ញាបត្យាប័នជាមួយព្រះរាជាណាចក្រថៃ ធ្វើឡើងនៅទីក្រុងបាំងកកក្នុងឆ្នាំ១៩៩៨ ហើយដែលត្រូវបានអនុម័តកាលពីថ្ងៃទី ១៩ ខែកក្កដា ឆ្នាំ ១៩៩៩។

ក្រោយពីការចុះសន្ធិសញ្ញាបត្យាប័នជាមួយព្រះរាជាណាចក្រថៃ ព្រះរាជាណាចក្រកម្ពុជាបានចុះសន្ធិសញ្ញាបត្យាប័នជាមួយប្រទេសផ្សេងទៀតជាបន្តបន្ទាប់ដើម្បីបង្កើតជានីតិវិធីលំអិតក្នុងការធ្វើបត្យាប័នរវាងរដ្ឋ និងរដ្ឋ និងដើម្បីបង្កើតកិច្ចសហប្រតិបត្តិការគ្នាក្នុងវិស័យច្បាប់ជាមួយប្រទេសដទៃ។

ចាប់តាំងពីពេលនោះមកការធ្វើបត្យាប័នបានដើរតួនាទីក្នុងកិច្ចខិតខំប្រឹងប្រែងរបស់រាជរដ្ឋាភិបាលកម្ពុជាដែលជាលទ្ធផលនៃការខិតខំប្រឹងប្រែងនោះ បត្យាប័នត្រូវបានក្លាយជានីតិវិធីដោយឡែកមួយដែលមានចែងក្នុងក្រមនីតិវិធីព្រហ្មទណ្ឌ។

ក្រមនីតិវិធីព្រហ្មទណ្ឌបានបង្កើតបត្យាប័ននេះឡើង សម្រាប់ជាវិធានទូទៅក្នុងការអនុវត្តបត្យាប័នក្នុងព្រះរាជាណាចក្រកម្ពុជា ជាមួយប្រទេសទាំងឡាយដែលមិនបានកំណត់ពីសន្ធសញ្ញាបត្យាប័នជាមួយព្រះរាជាណាចក្រកម្ពុជាដោយបានកំណត់អំពី សមត្ថកិច្ច លក្ខខណ្ឌ និងនីតិវិធីនៃការធ្វើបត្យាប័ន ទាំងក្នុងករណីដែលកម្ពុជាជារដ្ឋទទួលសំណើ និងករណីដែលកម្ពុជាជារដ្ឋធ្វើសំណើ។

## ២.ចំណោទបញ្ហានៃការដោះស្រាយ

ក្នុងបរិបទនៃការសិក្សាស្រាវជ្រាវទោះបីជាមាន ក្រមនីតិវិធីព្រហ្មទណ្ឌ និងកិច្ចព្រមព្រៀងទាំងឡាយ បានចែងអំពីបត្យាប័នក្តី ក៏បទប្បញ្ញត្តិទាំងនេះគ្រាន់តែវិធានសម្រាប់ការអនុវត្តបត្យាប័នប៉ុណ្ណោះពោល គឺពុំបាន បកស្រាយលំអិតអំពីបត្យាប័នឡើយ អាស្រ័យហេតុនេះក្រុមយើងខ្ញុំបានលើកយកប្រធានបទស្តីពី បត្យាប័ន ដើម្បីជាការសិក្សាស្រាវបន្ថែម និងដើម្បីចងក្រងទុកជាឯកសារស្តីពីប្រធានបទនេះ សម្រាប់ជាការស្រាវ និង សិក្សាបន្ថែមព្រមទាំងធ្វើការស្វែងយល់ថា តើបត្យាប័នមាន លក្ខខណៈ ដំណើរការ និងនីតិវិធីយ៉ាងដូចម្តេចខ្លះ?

## ៣.គោលបំណងនៃការស្រាវជ្រាវ

ដើម្បីឆ្លើយតបនឹងចំណោទបញ្ហាខាងលើនេះ ក្រុមយើងខ្ញុំនឹងធ្វើការបកស្រាយក្នុងសៀវភៅសារណានេះ ដោយធ្វើការស្វែងយល់ឱ្យបានច្បាស់អំពី សញ្ញាណទូទៅនៃបត្យាប័ន ព្រមទាំងនីតិវិធីនៃការធ្វើបត្យាប័ន។

## ៤.ទំហំ និងដែនកំណត់នៃការស្រាវជ្រាវ

ប្រធានបទនេះ មានគោលបំណងធ្វើការស្រាវជ្រាវលើនីតិវិធីបត្យាប័នទាំងក្នុងក្របខណ្ឌដែលមាន សន្ធិសញ្ញាបត្យាប័ន និងក្របខណ្ឌដែលមិនមានសន្ធិសញ្ញាបត្យាប័ន ព្រមទាំងក្របខណ្ឌពិសេសនៃការធ្វើ បត្យាប័ន ដោយធ្វើការបកស្រាយទៅលើ សញ្ញាណទូទៅ ក្របខណ្ឌ លក្ខខណ្ឌ និងមោឃភាពនៃបត្យាប័ន ព្រមទាំងនីតិវិធីនៃបត្យាប័ន។

## ៥.សារៈសំខាន់នៃប្រធានបទ

ឆ្លងកាត់ការខិតខំប្រឹងប្រែងអស់រយៈពេល ៣ខែក្នុងការខិតខំប្រឹងប្រែងអស់ពីកម្លាំងកាយចិត្ត និងតស៊ូ អំណត់អត់ធ្មត់ ដោយសេចក្តីព្យាយាម ក្នុងការសិក្សាស្រាវជ្រាវរបស់ក្រុមយើងខ្ញុំ ធ្វើឱ្យសារណាមួយនេះមាន សារៈសំខាន់បំផុតសម្រាប់ អ្នកសិក្សាស្រាវជ្រាវ និងនិស្សិតច្បាប់ដែលមានបំណងចង់ធ្វើការស្វែងយល់អំពី សញ្ញាណទូទៅ ព្រមទាំងនីតិវិធីធ្វើបត្យាប័នក្នុងព្រះរាជាណាចក្រកម្ពុជា ដោយអនុលោមទៅតាមក្រមនីតិវិធី ព្រហ្មទណ្ឌ និងកិច្ចព្រមព្រៀងស្តីពីបត្យាប័នផ្សេងៗរបស់កម្ពុជា។

## ៦.វិធីសាស្ត្រនៃការស្រាវជ្រាវ

ក្នុងការសិក្សាស្រាវជ្រាវនេះ ក្រុមយើងខ្ញុំបានធ្វើការស្វែងរកឯកសារជាច្រើនតាមរយៈបច្ចេកវិទ្យាដែល មានតាមប្រព័ន្ធអនឡាញ ការប្រមូលឯកសារច្បាប់ផ្សេងៗដែលពាក់ព័ន្ធនឹងនីតិវិធីបត្យាប័ន និងកិច្ចព្រមព្រៀង ផ្សេងៗស្តីពីបត្យាប័នរបស់កម្ពុជា ក៏ដូចជាសៀវភៅទ្រឹស្តីច្បាប់ផ្សេងៗព្រមទាំងមានការចូលរួមណែនាំពីលោកគ្រូ សាស្ត្រាចារ្យណែនាំ សិស្សច្បង និងមិត្តរួមថ្នាក់ផងដែរ។ លើសពីនេះទៅទៀតក្រុមយើងខ្ញុំ ក៏បានចូលទៅ ស្រាវជ្រាវបន្ថែមក្នុងបណ្ណាល័យផងដែរ ដើម្បីជាប្រយោជន៍ក្នុងស្វែងយល់អំពីប្រធានបទនេះឱ្យកាន់តែ ច្បាស់លាស់បន្ថែមទៀត។

# ៧.រចនាសម្ព័ន្ធនៃកិច្ចការស្រាវជ្រាវ

ដើម្បីធ្វើការស្វែងយល់ឱ្យបានលំអិត និងកាន់តែច្បាស់អំពីប្រធានបទស្តីពីបត្យាប័នក្រុមយើងខ្ញុំបានធ្វើការស្រាវជ្រាវអំពី សញ្ញាណទូទៅនៃបត្យាប័ន ក្របខណ្ឌ លក្ខខណ្ឌ និងមោឃភាពនៃបត្យាប័ន ព្រមទាំងនីតិវិធីនៃការធ្វើបត្យាប័ន ដើម្បីឱ្យការសិក្សាស្រាវជ្រាវនេះមានភាពច្បាប់លាស់។ ជាលទ្ធផលក្រុមយើងខ្ញុំទទួលបាននូវប្លង់ស្ថាពរមួយ ដែលបែងចែកជាបីជំពូកដូចខាងក្រោម៖

ជំពូកទី ១.សញ្ញាណទូទៅនៃបត្យាប័ន

១.អត្ថន័យ និងពាក្យគន្លឹះ

២.របបគតិយុត្តនៃបត្យាប័ន

៣.ក្រសួង ស្ថាប័នដែលមានសមត្ថកិច្ចពាក់ព័ន្ធនឹងបត្យាប័ន

ជំពូកទី ២.ក្របខណ្ឌ លក្ខខណ្ឌ និងមោឃភាពនៃបត្យាប័ន

១.ក្របខណ្ឌនៃការធ្វើបត្យាប័ន

២.លក្ខខណ្ឌនៃការធ្វើបត្យាប័ន

៣.មោឃភាពនៃបត្យាប័ន

ជំពូកទី ៣.នីតិវិធីបត្យាប័ន

១.គោលការណ៍កម្រិតក្នុងការធ្វើបត្យាប័ន

២.នីតិវិធីបត្យាប័នក្នុងករណីដែលព្រះរាជាណាចក្រកម្ពុជាជារដ្ឋទទួលសំណើ

៣.នីតិវិធីបត្យាប័នក្នុងករណីដែលព្រះរាជាណាចក្រកម្ពុជាជារដ្ឋដាក់សំណើ

# ជំពូកទី ១
# សញ្ញាណទូទៅនៃបត្យាប័ន

# ជំពូកទី ១

# សញ្ញាណទូទៅនៃបត្យាប័ន

## ១.អត្ថន័យ និងពាក្យគន្លឹះ

### ១.១.អត្ថន័យនៃបត្យាប័ន

បត្យាប័នក្នុងន័យទូលាយសំដៅទៅដល់ការបញ្ជូនខ្លួនជនល្មើសពីរដ្ឋមួយទៅរដ្ឋមួយទៀត។ បើនិយាយតាមផ្លូវច្បាប់ បត្យាប័ន គឺជានីតិវិធីនៃការប្រគល់ខ្លួនបុគ្គលម្នាក់ដោយរដ្ឋ (រដ្ឋទទួលសំណើ) ទៅឱ្យអាជ្ញាធររបស់រដ្ឋមួយផ្សេងទៀត (រដ្ឋដាក់សំណើ) ក្នុងគោលបំណងដើម្បីយកជននោះមកធ្វើការចោទប្រកាន់ចំពោះមុខយុត្តាធិការរបស់ខ្លួន ឬយកជននោះមកអនុវត្តទោសនៅក្នុងប្រទេសរបស់ខ្លួន។ បត្យាប័នគឺសំដៅដល់នីតិវិធីមួយដែលក្នុងនោះមានរដ្ឋមួយដែលជារដ្ឋធ្វើសំណើដែលធ្វើសំណើសុំជនណាម្នាក់ទៅរដ្ឋមួយទៀតដើម្បីយកជននោះមកធ្វើការចោទប្រកាន់នៅចំពោះមុខយុត្តាធិការរបស់ខ្លួន ឬយកជននោះមកអនុវត្តទោសនៅចំពោះមុខយុត្តាធិការរបស់ខ្លួននៅក្នុងប្រទេសរបស់ខ្លួន។

សរុបជារួមបត្យាប័ន គឺសំដៅទៅដល់នីតិវិធីទាំងឡាយនៃទំនាក់ទំនងរវាងរដ្ឋនិងរដ្ឋក្នុងការផ្ទេរក្នុងការបញ្ជូនជនជនល្មើស ទៅធ្វើការចោទប្រកាន់ឬមួយក៏ទៅធ្វើការអនុវត្តទោស។

បត្យាប័នត្រូវបានបញ្ញត្តបញ្ជាក់នៅក្នុងក្រមនីតិវិធីព្រហ្មទណ្ឌ ក្នុងជំពូកទី២ មាតិកាទី១ គន្ថីទី៩ ចាប់ពីមាត្រា ៥៦៦ រហូតដល់៥៩៤ ដែលចែងពីបត្យាប័ន។ បត្យាប័នកើតមានឡើងនៅពេលដែលរដ្ឋមួយដែលជាអ្នកស្នើសុំ ហៅថារដ្ឋដាក់សំណើ ឬរដ្ឋធ្វើសំណើ បានធ្វើការស្នើសុំទៅរដ្ឋមួយផ្សេងទៀត ដើម្បីធ្វើបត្យាប័ន ដែលរដ្ឋនោះហៅថារដ្ឋទទួលសំណើ។

### ១.២.ពាក្យគន្លឹះផ្សេងទៀតដែលពាក់ព័ន្ធនឹងបត្យាប័ន

- រដ្ឋធ្វើសំណើគឺ ជារដ្ឋដែលជាអ្នកស្នើសុំធ្វើបត្យាប័នអាណិកជនបរទេស
- រដ្ឋទទួលសំណើគឺ ជារដ្ឋដែលទទួលបានសំណើសុំធ្វើបត្យាប័ន
- សន្ធិសញ្ញាគឺ ជាកិច្ចព្រមព្រៀងអន្តរជាតិដែលធ្វើឡើងរវាងរដ្ឋនិងរដ្ឋនៅក្នុងទម្រង់ជាលាយលក្ខណ៍អក្សរ។
- បុគ្គលដែលគេទាមទារ ជាអាណិកជនបរទេសដែលស្នាក់នៅលើដែនដីនៃព្រះរាជាណាចក្រកម្ពុជា និងដែលជាកម្មវត្ថុនៃពាក្យស្នើសុំឱ្យធ្វើបត្យាប័ន។[១]

[១] ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៨០៧/០២៤, ១០ សីហា ២០០៧, មាត្រា ៥៦៨

## ២.របបគតិយុត្តនៃបត្យាប័ន

### ២.១.រដ្ឋធម្មនុញ្ញ

គំនិតជាមូលដ្ឋាន នៃបត្យាប័នត្រូវបានបញ្ញត្តក្នុងរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា។

យោងតាម មាត្រា ៣៣ នៃរដ្ឋធម្មនុញ្ញបានបញ្ញត្តថាប្រជាពលរដ្ឋខ្មែរគ្រប់រូបមិនត្រូវបានដកសញ្ជាតិឬចាប់បញ្ជូនខ្លួនទៅប្រទេសក្រៅណាមួយឡើយលើកលែងតែមានកិច្ចព្រមព្រៀងនឹងគ្នាទៅវិញទៅមក។[៦]

ផ្អែកតាមបញ្ញត្តិនេះ គោលការណ៍នៃការមិនដកសញ្ជាតិ ឬចាប់បញ្ជូនខ្លួនប្រជាពលរដ្ឋខ្មែរទៅប្រទេសក្រៅណាមួយ គឺជាគោលការណ៍សំខាន់មួយ ដែលហាមមិនឱ្យព្រះរាជាណាចក្រកម្ពុជា និងរដ្ឋបរទេសណាមួយធ្វើបត្យាប័នប្រជាពលរដ្ឋខ្មែរដោយឯកតោភាគីបានឡើយពោល គឺអាចធ្វើបត្យាប័នបានលុះត្រាតែមានកិច្ចព្រមព្រៀងនឹងគ្នាទៅវិញទៅមក។

### ២.២.សន្ធិសញ្ញាគំរូរបស់អង្គការសហប្រជាជាតិ

សន្ធិសញ្ញាគំរូរបស់អង្គការសហប្រជាជាតិ ស្តីពីការធ្វើបត្យាប័ន បានចែងអំពីគំរូសម្រាប់ច្បាប់ជាតិ និងកិច្ចព្រមព្រៀងទ្វេភាគីដែលពាក់ព័ន្ធនឹងការធ្វើបត្យាប័នដើម្បីធានាថាដំណើរការនៃការធ្វើបត្យាប័នឆ្លុះបញ្ចាំងអំពីកាតព្វកិច្ចសិទ្ធិមនុស្សអន្តរជាតិ។

### ២.៣.សន្ធិសញ្ញាបត្យាប័នរវាងរដ្ឋកម្ពុជាជាមួយរដ្ឋបរទេស

សន្ធិសញ្ញាបត្យាប័នសំដៅលើក្របខណ្ឌនៃបត្យាប័នពិសេស ដែលក្នុងករណីដែលព្រះរាជាណាចក្រកម្ពុជាមានសន្ធិសញ្ញាដែលចែងអំពីនីតិវិធីលម្អិតនៃការធ្វើបត្យាប័នជាមួយរដ្ឋបរទេសណាមួយ នីតិវិធីបត្យាប័ន ត្រូវអនុលោមទៅតាមសន្ធិសញ្ញាបត្យាប័នដែលកម្ពុជាបានផ្តល់សច្ចាប័ន។

### ២.៤.ក្រមនីតិវិធីព្រហ្មទណ្ឌ

ដើម្បីបង្កើតឱ្យមាននីត្យានុកូលភាពក្នុងការធ្វើបត្យាប័នក្នុងព្រះរាជាណាចក្រកម្ពុជា ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជាបានបញ្ញត្តអំពីបត្យាប័នក្នុងជំពូកទី២ នៃគន្ថីទី៩ដែលជានីតិវិធីដោយឡែករបស់ក្រមនីតិវិធីព្រហ្មទណ្ឌ។ បញ្ញត្តិនៃក្រមនីតិវិធីព្រហ្មទណ្ឌបានកំណត់អំពីលក្ខខណ្ឌ និងនីតិវិធីផ្សេងៗដើម្បីធ្វើបត្យាប័នដែលទាក់ទងនឹងព្រះរាជាណាចក្រកម្ពុជា។

បញ្ញត្តិស្តីពីបត្យាប័នដែលមានចែងក្នុងក្រមនីតិវិធីព្រហ្មទណ្ឌជានីតិវិធីនៃនីតិរួមទាក់ទងការធ្វើបត្យាប័នសម្រាប់ព្រះរាជាណាចក្រកម្ពុជា ក្នុងករណីដែលពុំមានកិច្ចព្រមព្រៀងចែងអំពីនីតិវិធីលំអិតស្តីពីបត្យាប័ន។

[៦] រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា, ប្រកាសប្រើឱ្យថ្ងៃទី ២៤ ខែកញ្ញា ឆ្នាំ១៩៩៣,មាត្រា ៣៣

## ៣.ក្រសួង ស្ថាប័នដែលមានសមត្ថកិច្ចពាក់ព័ន្ធនឹងបត្យាប័ន

ភាពស្មុគស្មាញនៃការធ្វើបត្យាប័នចាំបាច់ត្រូវមានស្ថាប័នពាក់ព័ន្ធមួយចំនួនរួមចំណែកអនុវត្តកិច្ចការងារនេះដើម្បីឱ្យបត្យាប័នមានភាពរលូន និងមានប្រសិទ្ធិភាព។ ស្ថាប័នទាំងនោះ មានដូចជា ក្រសួងយុត្តិធម៌ជាអាជ្ញាធរកណ្តាល ក្រសួងការបរទេស ជាអ្នកទទួលសំណើ និងជាអ្នកបញ្ជូនសំណើ និងសភាស៊ើបសួរ។

### ៣.១.ក្រសួងយុត្តិធម៌

ក្រសួងយុត្តិធម៌ជា ក្រសួងចំណុះឱ្យរាជរដ្ឋាភិបាលកម្ពុជាដែលមានសមត្ថកិច្ច ដឹកនាំ និងគ្រប់គ្រងលើវិស័យយុត្តិធម៌នៃព្រះរាជាណាចក្រកម្ពុជា។ បើសង្កេតទៅលើសន្ធិសញ្ញា បត្យាប័នរវាងកម្ពុជាជាមួយនឹងរដ្ឋបរទេសទាំងឡាយ យើងសង្កេតឃើញថា ក្រសួងយុត្តិធម៌ ជាអាជ្ញាធរកណ្តាលក្នុងការធ្វើបត្យាប័ន។

តាមរយៈប្រកាសស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់អាជ្ញាធរកណ្តាល នៃក្រសួងយុត្តិធម៌ ក្រសួងយុត្តិធម៌បានបង្កើតឱ្យមានអាជ្ញាធរកណ្តាលនៃក្រសួងយុត្តិធម៌ ដើម្បីជួយសម្រួលលើការងារជួយគ្នាទៅវិញទៅមកផ្នែកច្បាប់ក្នុងវិស័យព្រហ្មទណ្ឌ រដ្ឋប្បវេណី ពាណិជ្ជកម្ម បត្យាប័ន និងការបញ្ជូនទណ្ឌិត។

ផ្អែកតាម ប្រកាសស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់អាជ្ញាធរកណ្តាល នៃក្រសួងយុត្តិធម៌បានចែងថា អាជ្ញាធរកណ្តាលមានបេសកកម្ម តួនាទី និងភារកិច្ចដូចតទៅៈ

- ទទួលពិនិត្យ និងសម្របសម្រួលលើសំណើ នៃការជួយគ្នាទៅវិញទៅមកផ្នែកច្បាប់ក្នុងវិស័យព្រហ្មទណ្ឌ រដ្ឋប្បវេណី ពាណិជ្ជកម្ម បត្យាប័ន និងការបញ្ជូនទណ្ឌិត
- បញ្ជូនសំណើទៅភ្នាក់ងារពាក់ព័ន្ធ និងបញ្ជូនសំណើត្រឡប់ទៅភាគីម្ចាស់សំណើ
- រៀបចំបញ្ចូលព័ត៌មាន និងតាមដានរាល់សំណើដែលបានទទួល និងបញ្ជូនដើម្បីធានាឱ្យមានដំណោះស្រាយប្រកបដោយប្រសិទ្ធភាព និងឱ្យបានឆាប់រហ័ស
- ដើរតួរជាអង្គភាពបង្គោល ដើម្បីសម្របសម្រួលរាល់បញ្ហាទាក់ទងនឹងជំនួយផ្នែកច្បាប់
- ធ្វើការទំនាក់ទំនងដោយផ្ទាល់ ឬតាមរយៈផ្លូវទូត ជាមួយស្ថាប័នជាតិ និងអន្តរជាតិដើម្បីសម្របសម្រួលលើការជួយគ្នាទៅវិញទៅមកផ្នែកច្បាប់
- រៀបចំពិនិត្យ និងសម្របសម្រួល ការបកប្រែភាសាលើសំណើសុំឯកសារ សំណុំរឿង ភស្តុតាង និងឯកសារពាក់ព័ន្ធនឹងជំនួយផ្នែកច្បាប់
- រៀបចំទិន្នន័យនៃសំណើសុំជំនួយផ្នែកច្បាប់ និងចងក្រងឯកសារច្បាប់ដោយបញ្ចូនទៅក្នុងប្រព័ន្ធមូលដ្ឋានទិន្នន័យដោយបង្ហោះនៅលើគេហទំព័ររបស់ក្រសួងយុត្តិធម៌
- រក្សាការសំងាត់ចំពោះសំណើសុំជំនួយខ្លឹមសារ និងឯកសារគាំទ្រសំណើ ហេតុការណ៍នៃការផ្តល់ជំនួយ និងចំណាត់ការណាមួយដែលអនុវត្តទៅតាមសំណើ

- ធានានូវព័ត៌មាន និងភស្តុតាងត្រូវបានការពារមិនឱ្យបាត់បង់ និងការទទួលបានការប្រើប្រាស់ ការកែប្រែ ការបង្ហាញដោយគ្មានការអនុញ្ញាត ឬការប្រើប្រាស់មិនត្រឹមត្រូវផ្សេងៗ
- រៀបចំផែនការសកម្មភាពនៃការអភិវឌ្ឍលើការងារសម្របសម្រួលការចំណាយ ដំណើរទស្សនកិច្ចសិក្សា ចូលរួមសិក្ខាសាលា និងកិច្ចប្រជុំទាំងក្នុង និងក្រៅប្រទេស
- ធ្វើការទំនាក់ទំនងជាមួយដៃគូអភិវឌ្ឍន៍ ដើម្បីស្វែងរកជំនួយក្នុងការបណ្តុះបណ្តាលធនធានមនុស្ស។[៣]

ផ្អែកតាមប្រកាសខាងលើក្រសួងយុត្តិធម៌មានតួនាទីយ៉ាងសំខាន់ជាអាជ្ញាធរកណ្តាលក្នុងការធ្វើបត្យាប័ន ដែលមានតួនាទី និងភារកិច្ចក្នុងការទទួលពិនិត្យ និងសម្របសម្រួលលើសំណើធ្វើបត្យាប័ន។

## ៣.២.ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ

ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិបំពេញមុខងារជាសេនាធិការឱ្យរាជរដ្ឋាភិបាលលើការដឹកនាំ និងគ្រប់គ្រងវិស័យការបរទេស និងសហប្រតិបត្តិការអន្តរជាតិនៃព្រះរាជាណាចក្រកម្ពុជា។

ក្នុងនីតិវិធីបត្យាប័ន ក្រសួងនេះដើរតួនាទី យ៉ាងសំខាន់ពាក់ព័ន្ធនឹងការបញ្ជូនពាក្យសុំធ្វើបត្យាប័ន។

គ្រប់ពាក្យសុំធ្វើបត្យាប័នត្រូវតែជូនរដ្ឋាភិបាលកម្ពុជាតាមផ្លូវទូត ពាក្យសុំនេះត្រូវមានលិខិតបញ្ជាក់ភស្តុតាងអមជាមួយផង ។

លិខិតបញ្ជាក់ភស្តុតាងត្រូវមាន :

- ឯកសារដែលមានលក្ខណៈគ្រប់គ្រាន់ក្នុងការកំណត់អត្តសញ្ញាណបុគ្គលដែលគេទាមទារ
- របាយការណ៍អំពីអង្គហេតុដែលត្រូវចោទប្រកាន់លើបុគ្គលដែលគេទាមទារ
- អត្ថបទច្បាប់ដែលអនុវត្តទៅលើអំពើនោះ និងទោសដែលត្រូវទទួលរង
- លិខិតចម្លងនៃសេចក្តីសម្រេចផ្តន្ទាទោសប្រសិនបើមាន ។

ឯកសារទាំងអស់ត្រូវចុះហត្ថលេខា បោះត្រាជាផ្លូវការ និងបិទស្រោម ហើយប្រសិនបើមិនមែនជាភាសាខ្មែរ បារាំងឬអង់គ្លេសត្រូវតែភ្ជាប់មកជាមួយនូវឯកសារបកប្រែជា ភាសាមួយនៃភាសាទាំងបីនេះ ដោយមានសេចក្តីបញ្ជាក់ផង។[៤]

បញ្ញត្តិខាងលើនៃក្រមនីតិវិធីព្រហ្មទណ្ឌបានកំណត់សមត្ថកិច្ចឱ្យក្រសួងការបរទេស មានសមត្ថកិច្ចលើពាក្យសុំធ្វើបត្យាប័នតាមផ្លូវទូតទាំងការទទួលពាក្យសុំធ្វើបត្យាប័នពីបរទេសក្នុងករណីដែលកម្ពុជា ជារដ្ឋទទួលសំណើ និងការបញ្ជូនពាក្យសុំធ្វើបត្យាប័នពីកម្ពុជា ក្នុងករណីដែលកម្ពុជា ជារដ្ឋដាក់សំណើ។

---

[៣] ប្រកាសស្តីពីការរៀបចំនិងការប្រព្រឹត្តទៅ អាជ្ញាធរកណ្តាលនៃក្រសួងយុត្តិធម៌, លេខ១០០កយ.ប្រក/១៧,១២ មេសា ២០១៧,ប្រការ៣

[៤] ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៨០៧/០២៤, ១០ សីហា ២០០៧, មាត្រា ៥៧៩

ក្នុងករណីដែលព្រះរាជាណាចក្រកម្ពុជា ជារដ្ឋទទួលសំណើសុំធ្វើបត្យាប័ន ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិនៃព្រះរាជាណាចក្រកម្ពុជាត្រូវទទួលពាក្យសុំធ្វើបត្យាប័នដោយរដ្ឋបរទេសពីទូតរបស់រដ្ឋនោះប្រចាំនៅកម្ពុជាដោយត្រូវបញ្ជូនសំណើសុំធ្វើបត្យាប័ននោះទៅកាន់រដ្ឋមន្ត្រីក្រសួងការបរទេស។[៥]

បន្ទាប់មករដ្ឋមន្ត្រីក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិត្រូវបញ្ជូនសំណើធ្វើបត្យាប័នបន្តទៅរដ្ឋមន្ត្រីក្រសួងយុត្តិធម៌ដើម្បីផ្ទៀងផ្ទាត់មើលនិយតភាពនៃពាក្យសុំ ។[៦]

ក្នុងករណីដែលព្រះរាជាណាចក្រកម្ពុជាជារដ្ឋដាក់សំណើវិញ ផ្អែកតាម មាត្រា ៦ នៃកិច្ចព្រមព្រៀងបត្យាប័នបានបញ្ញត្តថា ក្នុងស្មារតីនៃកិច្ចព្រមព្រៀងនេះគូភាគីត្រូវប្រាស្រ័យទាក់ទងគ្នា តាមរយៈផ្លូវទូតវៀរលែងតែមានបញ្ញត្តិផ្សេងចែងក្នុងកិច្ចព្រមព្រៀងនេះ។[៧]

យោងតាមបញ្ញត្តិខាងលើក្នុងកិច្ចព្រមព្រៀងនេះ ក្រសួងការបរទេស និងសហប្រតិបត្តិការមានសមត្ថកិច្ចសំខាន់ក្នុងការបញ្ជូនសំណើបត្យាប័នដូចករណីដែលប្រទេសកម្ពុជាដើរតួនាទីជារដ្ឋទទួលសំណើដែរ។

### ៣.៣. សាលាឧទ្ធរណ៍

សភាស៊ើបសួរ គឺជាសភាពិសេសនៅសាលាឧទ្ធរណ៍ដែលជាស្ថាប័នស៊ើបសួរជាន់ខ្ពស់នៃសាលា-ឧទ្ធរណ៍។ សភាស៊ើបសួរបង្កើតឡើងនៅក្នុងគោលបំណងពិនិត្យអត្ថិភាពនៃនីតិវិធីស៊ើបសួររបស់ចៅក្រមស៊ើបសួរ ឬនិយាយបានថានីតិវិធីស៊ើបសួររបស់មន្ទីរស៊ើបសួរនៃសាលាដំបូងខេត្តក្រុងទាំងអស់ដើម្បីធ្វើយ៉ាងឱ្យត្រឹមត្រូវនូវការស៊ើបសួរ តាមនីតិវិធីដែលកំណត់នៅក្នុងក្រមនីតិវិធីព្រហ្មទណ្ឌ។ សភាស៊ើបសួរមានសមត្ថកិច្ចពិនិត្យលើនិយតភាពនៃការស៊ើបសួរទាំងអស់។

ក្នុងរឿងបត្យាប័នសភាស៊ើបសួរមានសមត្ថកិច្ច ពីរបែប គឺផ្តល់យោបល់ទៅលើបត្យាប័នដែលស្នើសុំដោយរដ្ឋបរទេស និងសមត្ថកិច្ចមួយទៀត គឺពិនិត្យអំពីនិយតភាពនៃបត្យាប័នដែលស្នើសុំដោយ ព្រះរាជាណា-ចក្រកម្ពុជា។ សភាស៊ើបសួរនៃសាលាឧទ្ធរណ៍ គឺជាសាលាជម្រះក្តីដែលមានសមត្ថកិច្ចក្នុងការផ្តល់ យោបល់លើបត្យាប័ន ហើយអគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ភ្នំពេញជាអ្នករៀបចំសំណុំរឿង ដើម្បីប្តឹងទៅសភាស៊ើបសួរ។

ក្នុងករណីដែលកម្ពុជាជារដ្ឋដែលស្នើសុំបត្យាប័ន សភាស៊ើបសួរមានសមត្ថកិច្ចក្នុងការពិនិត្យអំពើនិយតភាពនៃបត្យាប័ន។ សភាស៊ើបសួរនៃសាលាឧទ្ធរណ៍ ជាអង្គការតែមួយគត់ដែលមានសមត្ថកិច្ចដើម្បី

---

[៥] ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៨០៧/០២៤, ១០ សីហា ២០០៧, មាត្រា ៥៧៩

[៦] ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៨០៧/០២៤, ១០ សីហា ២០០៧, មាត្រា ៥៨០

[៧] កិច្ចព្រមព្រៀងស្តីពីបត្យាប័ន រវាងព្រះរាជាណាចក្រកម្ពុជា និងសាធារណរដ្ឋកូរ៉េ, នស/រកម/០១១១/០០១, ០៦ មករា ២០១១,មាត្រា៦

ពិចារណាលើនិយតភាពនៃបត្យាប័នដែល រាជរដ្ឋាភិបាលកម្ពុជាបានទទួល។[៩]

ក្នុងនីតិវិធីបត្យាប័នដែលកម្ពុជា ជារដ្ឋដែលស្នើសុំធ្វើបត្យាប័ននៅពេលដែលរដ្ឋទទួលសំណើបានយល់ព្រមធ្វើបត្យាប័នបុគ្គលដែលប្រទេសកម្ពុជាទាមទារឱ្យធ្វើបត្យាប័ន បុគ្គលនេះនឹងត្រូវបញ្ជូនឱ្យមកកាន់ប្រទេសកម្ពុជាវិញ។ ក្រោយពីបុគ្គលដែលត្រូវធ្វើបត្យាប័នបានមកដល់ប្រទេសកម្ពុជា នីតិវិធីបន្ទាប់គឺជាការពិនិត្យអំពីនិយតភាពនៃបត្យាប័ននោះដោយផ្អែកតាម មាត្រា ៥៩០នៃក្រមនីតិវិធីព្រហ្មទណ្ឌ គឺសភាស៊ើបសួរនៃសាលាឧទ្ធរណ៍ភ្នំពេញជាអង្គការតែមួយគត់ដែលមានសមត្ថកិច្ចពិនិត្យអំពីនិយតភាពនៃបត្យាប័ន។ លើសពីនេះទៅទៀត បុគ្គលដែលត្រូវធ្វើបត្យាប័នមានរយៈពេល ១៥ថ្ងៃ គិតពីពេលដែលសាមីខ្លួន បានមកដល់កម្ពុជា ដើម្បីលើកអំពីមោឃភាពនៃបត្យាប័ន។

ចំពោះនីតិវិធីបណ្ដឹងអំពីមោឃភាពនៃបត្យាប័នត្រូវធ្វើឡើងនៅចំពោះមុខសភាស៊ើបសួរ ដោយសភាស៊ើបសួរ ធ្វើការស្ដាប់ចម្លើយរបស់បុគ្គលដែលត្រូវធ្វើបត្យាប័ន សេចក្ដីសន្និដ្ឋានស្នើសុំរបស់អគ្គព្រះរាជអាជ្ញា និងសេចក្ដីសន្និដ្ឋានរបស់មេធាវី។ ក្រោយនីតិវិធីនៅចំពោះមុខសភាស៊ើបសួរ និងក្រោយពីសភាស៊ើបសួរបានពិនិត្យអំពីនិយតភាពរួច។ សភាស៊ើបសួរអាចសម្រេចបដិសេធនីតិវិធីបត្យាប័ន។ បត្យាប័នត្រូវចាត់ទុកជាមោឃៈ ប្រសិនបើក្រោយពេលដែលសភាស៊ើបសួរបានពិនិត្យអំពីនិយតភាពនៃបត្យាប័នរួចហើយពុំមានមោឃភាពនៃបត្យាប័នទេ នោះបត្យាប័ននឹងត្រូវផ្ដល់ឱ្យ។

ក្នុងករណីដែលព្រះរាជាណាចក្រកម្ពុជាជារដ្ឋទទួលសំណើវិញ សភាស៊ើបសួរមានសមត្ថកិច្ចជាអ្នកផ្ដល់យោបល់លើបត្យាប័ន។ សភាស៊ើបសួរផ្ដល់យោបល់មិនយល់ព្រមប្រសិនបើយល់ឃើញថាលក្ខខណ្ឌច្បាប់នៃបត្យាប័នមិនត្រូវបានបំពេញទេ។[១០] លើសពីនេះទៅទៀត សភាស៊ើបសួរមានតួនាទីយ៉ាងសំខាន់ក្នុងការផ្ដល់យោបល់លើបត្យាប័នពោល គឺមុននឹងសម្រេចបង្គាប់ឱ្យធ្វើបត្យាប័នរាជរដ្ឋាភិបាលកម្ពុជាចាំបាច់ត្រូវតែទទួលយោបល់ពីសាលាជម្រះក្ដីជាមុនសិន ។ ប្រសិនបើជាយោបល់មិនយល់ព្រមឱ្យធ្វើបត្យាប័ននោះរាជរដ្ឋាភិបាលមិនអាចបង្គាប់ឱ្យធ្វើបត្យាប័នទេហើយ បុគ្គលដែលគេទាមទារនឹងត្រូវដោះលែងឱ្យមានសេរីភាពឡើងវិញភ្លាម ។

---

[៩] ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៨០៧/០២៤, ១០ សីហា ២០០៧, មាត្រា ៥៩០

[១០] ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៨០៧/០២៤, ១០ សីហា ២០០៧, មាត្រា ៥៨៦

# ជំពូកទី ២

# ក្របខណ្ឌ លក្ខខណ្ឌ

# និងមោឃភាពនៃបត្យាប័ន

# ជំពូកទី ២
# ក្របខណ្ឌ លក្ខខណ្ឌ និងមោឃភាពនៃបត្យាប័ន

## ១.ក្របខណ្ឌនៃការធ្វើបត្យាប័ន

ក្របខណ្ឌនៃការធ្វើបត្យាប័នសំដៅលើវិធានដែលត្រូវយកមកអនុវត្តចំពោះការធ្វើបត្យាប័ន។

ចំពោះក្របខណ្ឌនៃការធ្វើបត្យាប័នក្នុងព្រះរាជាណាចក្រកម្ពុជាត្រូវបានកំណត់ដោយក្រមនីតិវិធី-ព្រហ្មទណ្ឌតាមប្បញ្ញតិនៃមាត្រា ៥៦៦នៃក្រមនីតិវិធីព្រហ្មទណ្ឌ ដែលធ្វើការបែងចែកក្របខណ្ឌនៃការធ្វើបត្យាប័នជាបីក្របខណ្ឌគឺ បត្យាប័នក្នុងករណីមានសន្ធិសញ្ញា បត្យាប័នក្នុងករណីគ្មានសន្ធិសញ្ញា និងក្របខណ្ឌនៃបត្យាប័នដែលមានចែងក្នុងច្បាប់ពិសេស។

ក្រមនីតិវិធីព្រហ្មទណ្ឌបានបញ្ញត្តថា បត្យាប័នអាណិកជនបរទេសដែលត្រូវចាប់ខ្លួននៅលើដែនដីនៃព្រះរាជាណាចក្រកម្ពុជាត្រូវបានគ្រប់គ្រងដោយបទប្បញ្ញត្តិនៃសន្ធិសញ្ញា និងអនុសញ្ញាអន្តរជាតិដែលត្រូវបានទទួលសច្ចាប័នពីព្រះរាជាណាចក្រកម្ពុជា ក្នុងករណីគ្មានសន្ធិសញ្ញា ឬអនុសញ្ញាអន្តរជាតិដែលត្រូវបានទទួលសច្ចាប័នពីព្រះរាជាណាចក្រកម្ពុជាទេ បទប្បញ្ញត្តិនៃជំពូកនេះត្រូវយកមកអនុវត្តលើកលែងតែមានបញ្ញត្តិពិសេសនៅក្នុងច្បាប់ផ្សេងទៀត ។[១០]

ផ្អែកតាមបញ្ញត្តិខាងលើក្របខណ្ឌនៃបត្យាប័នត្រូវបានចែកជាបីផ្នែក គឺផ្នែកទីមួយចែងថាក្របខណ្ឌនៃបត្យាប័នពិសេសជាក្របខណ្ឌដែលបត្យាប័នត្រូវអនុលោមទៅតាមសន្ធិសញ្ញា ឬអនុសញ្ញាដែលព្រះរាជាណា-ចក្រកម្ពុជាបានផ្តល់សច្ចាប័នដែលបច្ចុប្បន្នកម្ពុជាមានអនុសញ្ញាមួយចំនួនស្តីពីការធ្វើបត្យាប័នទាក់ទងការធ្វើបត្យាប័នរវាងព្រះរាជាណាចក្រកម្ពុជាជាមួយនឹងប្រទេសមួយចំនួន អាស្រ័យហេតុនេះនៅពេលដែលមានអនុសញ្ញាដែលចែងលម្អិតអំពីនីតិវិធីមួយចំនួនស្តីពីការធ្វើបត្យាប័ន ជាគោលការណ៍ត្រូវធ្វើទៅធ្វើតាមក្របខណ្ឌនៃអនុសញ្ញាឬសន្ធិសញ្ញានោះ។ ចំពោះផ្នែកទីពីរប្រសិនបើគ្មានអនុសញ្ញា ជាគោលការណ៍ត្រូវអនុវត្តទៅតាមក្រមនីតិវិធីព្រហ្មទណ្ឌ ដែលជានីតិវិធីនៃនីតិរួមទាក់ទងការធ្វើបត្យាប័ន។ រីឯផ្នែកទីបី ក្នុងករណីមួយចំនួនមានចែងក្នុងបទប្បញ្ញត្តិពិសេសទាក់ទងការធ្វើបត្យាប័ន។ ដូច្នេះក្នុងករណីមានច្បាប់ចែងជាពិសេសរឿងបត្យាប័នគឺត្រូវធ្វើទៅតាមច្បាប់ពិសេសនោះ។

[១០] ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៨០៧/០២៤, ១០ សីហា ២០០៧, មាត្រា ៥៦៧

## ១.១.បត្យាប័នក្នុងករណីមានសន្ធិសញ្ញា

ការរៀបចំសន្ធិសញ្ញា អនុសញ្ញា ឬកិច្ចព្រមព្រៀងមានការកំណត់ក្នុង មាត្រា ៧ នៃអនុសញ្ញា **Vienna Convention on the Law of Treaties** ឆ្នាំ១៩៦៩ ។ សន្ធិសញ្ញា អនុសញ្ញា ឬកិច្ចព្រមព្រៀងអាចធ្វើជាទ្វេភាគី ឬពហុភាគី ទៅតាមការព្រមព្រៀង និងការឯកភាពគ្នាថាបង្កើតជាទ្វេភាគី ឬពហុភាគី ទៅតាមកម្មវត្ថុនៃការធ្វើសន្ធិសញ្ញា។ ការរៀបចំសន្ធិសញ្ញា ត្រូវផ្អែកលើច្បាប់រដ្ឋដែលមានរដ្ឋធម្មនុញ្ញាចម្បង អាចភ្ជាប់ទៅនឹងសន្ធិសញ្ញាអន្តរជាតិ ដើម្បីការពារសិទ្ធិ និងផលប្រយោជន៍រដ្ឋ ហើយច្បាប់រដ្ឋក៏មិនអាចជំទាស់ នឹងសន្ធិសញ្ញាអន្តរជាតិដែលរដ្ឋនោះបានផ្តល់សច្ចាប័នរួចរាល់ផងដែរ។ ប៉ុន្តែបើសិនមានប៉ះពាល់នឹងផលប្រយោជន៍ជាតិ រដ្ឋនោះអាចស្នើសុំលុបចោល ឬដកខ្លួន ចេញពីសន្ធិសញ្ញានោះបាន។

ចំពោះសន្ធិសញ្ញាស្តីពីបត្យាប័នត្រូវធ្វើឡើងតាមរយៈការចរចាគ្នាដើម្បីកំណត់នូវនីតិវិធីសមស្រប និងកំណត់នូវបទល្មើសទាំងឡាយណាដែលអនុញ្ញាតិឱ្យធ្វើបត្យាប័នបាន ឬមិនបាន។

សន្ធិសញ្ញាទាក់ទងនឹងការធ្វើបត្យាប័ននេះបានផ្តល់នូវភាពងាយស្រួលជាច្រើនដល់រដ្ឋជាភាគីតាមរយៈការឱ្យរដ្ឋជាភាគីបានដឹងជាមុននូវនីតិវិធីក្នុងការធ្វើបត្យាប័នព្រមទាំងដែនអនុវត្តខ្លះដែលរដ្ឋជាភាគីបានធ្វើការព្រមព្រៀងគ្នានៅក្នុងសន្ធិសញ្ញា។ សន្ធិសញ្ញាដែលកម្ពុជាបានធ្វើបត្យាប័នជាមួយរដ្ឋបរទេសមានដូចជាៈ

- ❑ សន្ធិសញ្ញាស្តីពីបត្យាប័ន រវាងកម្ពុជា-ថៃ ឆ្នាំ១៩៩៨
- ❑ សន្ធិសញ្ញាស្តីពីបត្យាប័ន រវាងកម្ពុជា-ចិន ឆ្នាំ១៩៩៩
- ❑ សន្ធិសញ្ញា ស្តីពីបត្យាប័ន រវាងកម្ពុជា-ឡាវ ឆ្នាំ១៩៩៩
- ❑ កិច្ចព្រមព្រៀងស្តីពីបត្យាប័ន រវាងកម្ពុជា-កូរ៉េ ឆ្នាំ២០០៩
- ❑ សន្ធិសញ្ញាស្តីពីបត្យាប័ន រវាងកម្ពុជា-វៀតណាម ឆ្នាំ២០១៤
- ❑ អនុសញ្ញាស្តីពីបត្យាប័ន រវាងកម្ពុជា-បារាំង ឆ្នាំ២០១៥
- ❑ សន្ធិសញ្ញាស្តីពីបត្យាប័ន រវាងកម្ពុជា-រុស្ស៊ី ឆ្នាំ២០១៧

### ក.សន្ធិសញ្ញាស្តីពីបត្យាប័ន រវាងព្រះរាជាណាចក្រកម្ពុជា និងព្រះរាជាណាចក្រថៃ

សន្ធិសញ្ញាស្តីពីបត្យាប័ន រវាងព្រះរាជាណាចក្រកម្ពុជា និងព្រះរាជាណាចក្រថៃ ធ្វើឡើងនៅទីក្រុងបាំងកក នាថ្ងៃទី០៦ ខែឧសភា ឆ្នាំ១៩៩៨ ដែលត្រូវបានអនុម័តកាលពីថ្ងៃទី ១៦ ខែមិថុនា ឆ្នាំ ១៩៩៩។

សន្ធិសញ្ញាស្តីពីបត្យាប័ន រវាងព្រះរាជាណាចក្រកម្ពុជា និងព្រះរាជាណាចក្រថៃ បង្កើតឡើងក្នុងបំណងជំរុញកិច្ចសហប្រតិបត្តិការដ៏មានប្រសិទ្ធិភាព រវាងប្រទេសទាំងពីរក្នុងការកំចាត់ឧក្រិដ្ឋកម្មឈរលើមូលដ្ឋានគោរពនូវអធិបយ្យភាពគ្នាទៅវិញទៅមក សមភាព និងផលប្រយោជន៍ទាំងសងខាងតាមការចុះសន្ធិសញ្ញាបត្យាប័ន។ សន្ធិសញ្ញានេះមានទាំងអស់ចំនួន ២៨ប្រការ។

**ខ.សន្ធិសញ្ញាស្តីពីបត្យាប័ន រវាងព្រះរាជាណាចក្រកម្ពុជា និងសាធារណរដ្ឋប្រជាមានិតចិន**

សន្ធិសញ្ញាសន្ធិសញ្ញាស្តីពីបត្យាប័ន រវាងព្រះរាជាណាចក្រកម្ពុជាកម្ពុជា និងសាធារណរដ្ឋប្រជាមានិតចិន ធ្វើឡើងនៅទីក្រុងប៉េងកាំង នាថ្ងៃទី០៩ ខែកុម្ភៈឆ្នាំ ១៩៩៩ និងត្រូវបានសភាអនុម័តយល់ព្រមកាលពីថ្ងៃទី ០៥ ខែមិថុនា ឆ្នាំ ២០០០។

សន្ធិសញ្ញានេះមានគោលបំណងជម្រុញកិច្ចសហប្រតិបត្តិការដ៏មានប្រសិទ្ធិភាព រវាងប្រទេសទាំងពីរនៅក្នុងការកំចាត់ឧក្រិដ្ឋកម្ម ដោយឈរនៅលើមូលដ្ឋានគោរពនូវអធិបតយ្យភាពគ្នាទៅវិញទៅមកសមភាព និងផលប្រយោជន៍ទាំងសងខាងតាមការចុះសន្ធិសញ្ញាបត្យាប័ន។ អនុសញ្ញាស្តីពីការធ្វើបត្យាប័ន រវាងព្រះរាជា-ណាចក្រកម្ពុជា និងសាធារណរដ្ឋប្រជាមានិតចិនមានប្រការចំនួន២២ ។

**គ.សន្ធិសញ្ញា ស្តីពីបត្យាប័ន រវាងព្រះរាជាណាចក្រកម្ពុជា និងសាធារណរដ្ឋប្រជាមានិតឡាវ**

សន្ធិសញ្ញា ស្តីពីបត្យាប័ន រវាងព្រះរាជាណាចក្រកម្ពុជា និងសាធារណរដ្ឋប្រជាមានិតឡាវ បានចុះហត្ថលេខានៅទីក្រុងវៀងច័ន្ទនាថ្ងៃទី២១ ខែតុលា ឆ្នាំ១៩៩៩ ដែលត្រូវបានអនុម័តថ្ងៃទី០៩ ខែកុម្ភៈ ឆ្នាំ ២០០៥។

សន្ធិសញ្ញានេះមានគោលបំណងជំរុញកិច្ចសហប្រតិបត្តិការដ៏មានប្រសិទ្ធិភាពរវាងប្រទេសទាំងពីរក្នុងការកំចាត់ឧក្រិដ្ឋកម្មឈរលើមូលដ្ឋានគោរពនូវអធិបតេយ្យភាពគ្នាទៅវិញទៅមក សមភាព ផលប្រយោជន៍ទាំងសងខាង និងផលប្រយោជន៍ទាំងសងខាងតាមការចុះសន្ធិសញ្ញាបត្យាប័នដែលបានព្រមព្រៀងគ្នា។

**ឃ.កិច្ចព្រមព្រៀងស្តីពីបត្យាប័ន រវាងព្រះរាជាណាចក្រកម្ពុជា និងសាធារណរដ្ឋកូរ៉េ**

កិច្ចព្រមព្រៀងស្តីពីបត្យាប័ន រវាងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា និងរដ្ឋាភិបាលនៃសាធារណរដ្ឋកូរ៉េ បានចុះហត្ថលេខានៅទីក្រុងភ្នំពេញ នាថ្ងៃទី២២ ខែតុលា ឆ្នាំ២០០៩ ដែលត្រូវបានអនុម័តកាលពីថ្ងៃទី ២៦ ខែវិច្ឆិកា ឆ្នាំ ២០១០។

កិច្ចព្រមព្រៀងនេះបង្កើតឡើងក្នុងបំណងជំរុញកិច្ចសហប្រតិបត្តិការដ៏មានប្រសិទ្ធិភាពរវាងប្រទេសទាំងពីរក្នុងការលុបបំបាត់ឧក្រិដ្ឋកម្ម ឈរលើមូលដ្ឋានគោរពនូវអធិបតេយ្យភាពគ្នាទៅវិញទៅមក សមភាព និងផលប្រយោជន៍ទាំងសងខាង។

**ង.សន្ធិសញ្ញាស្តីពីបត្យាប័ន រវាងព្រះរាជាណាចក្រកម្ពុជា និងសាធារណរដ្ឋសង្គមនិយមវៀតណាម**

សន្ធិសញ្ញាស្តីពីបត្យាប័នរវាងព្រះរាជាណាចក្រកម្ពុជា និងសាធារណរដ្ឋសង្គមនិយមវៀតណាម ដែលបានចុះហត្ថលេខា នៅរដ្ឋធានីហាណូយ សាធារណរដ្ឋសង្គមនិយមវៀតណាមនាថ្ងៃទី ២៦ ខែ ធ្នូ ឆ្នាំ ២០១៣ ហើយដែលបានអនុម័តកាលពីថ្ងៃទី ២៦ ខែកក្កដា ឆ្នាំ ២០១៤។

សន្ធិសញ្ញានេះមានបំណងលើកកម្ពស់កិច្ចសហប្រតិបត្តិការប្រកបដោយប្រសិទ្ធភាពរវាងប្រទេសទាំងពីរក្នុងការបង្ក្រាបបទល្មើស ដោយឈរលើមូលដ្ឋានគោរពអធិបតេយ្យភាពគ្នាទៅវិញទៅមក សមភាព និងផលប្រយោជន៍រួមទាំងសងខាង តាមរយៈការចុះសន្ធិសញ្ញបត្យាប័ន។

**ច.អនុសញ្ញាស្តីពីបត្យាប័ន រវាងព្រះរាជាណាចក្រកម្ពុជា និងសាធារណរដ្ឋបារាំង**

អនុសញ្ញាស្តីពីបត្យាប័ន រវាងព្រះរាជាណាចក្រកម្ពុជា និងសាធារណរដ្ឋបារាំង ត្រូវបានព្រះរាជាណាចក្រកម្ពុជា ចុះហត្ថលេខានៅរដ្ឋធានី ប៉ារីសនៃសាធារណរដ្ឋបារាំង នាថ្ងៃទី២៦ ខែតុលា ឆ្នាំ ២០១៥ ដែលត្រូវបានអនុម័តកាលពីថ្ងៃទី៦ ខែតុលា ឆ្នាំ២០២០។

អនុសញ្ញាស្តីពីបត្យាប័នរវាងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា និងរដ្ឋាភិបាលសាធារណរដ្ឋបារាំងមាន ២៥មាត្រា បង្កើតឡើងក្នុង គោលបំណង ដើម្បីលើកកម្ពស់កិច្ចសហប្រតិបត្តិការ រវាងប្រទេសទាំង ពីរនៅក្នុងការប្រឆាំងឧក្រិដ្ឋកម្មដោយការគោរពគោលការណ៍រដ្ឋធម្មនុញ្ញរៀងៗខ្លួន អធិបតេយ្យភាព សមភាព និងផលប្រយោជន៍គ្នាទៅវិញទៅមក ព្រមទាំងជាផ្នែកមួយ នៃកិច្ចសហប្រតិបត្តិការអន្តរជាតិក្នុងការរួមចំណែកយ៉ាងសកម្មក្នុងក្របខណ្ឌច្បាប់អន្តរជាតិ ដើម្បីប្រយុទ្ធប្រឆាំងទប់ស្កាត់ឧក្រិដ្ឋកម្មឆ្លងដែន រួមមានការជួញដូរមនុស្សពិសេសស្ត្រី និងកុមារ ការប្រយុទ្ធប្រឆាំងនិងភេរវកម្ម ការសម្អាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម និងការប្រឆាំងអំពើពុករលួយ។

**ឆ.សន្ធិសញ្ញាស្តីពីបត្យាប័ន រវាងព្រះរាជាណាចក្រកម្ពុជា និងសហព័ន្ធរុស្ស៊ី**

សន្ធិសញ្ញាស្តីពីបត្យាប័ន រវាងព្រះរាជាណាចក្រកម្ពុជា និងសហព័ន្ធរុស្ស៊ី បានចុះហត្ថលេខានៅរដ្ឋធានីមូស្គូ នៃសហព័ន្ធរុស្ស៊ី នាថ្ងៃទី០១ ខែកុម្ភៈ ឆ្នាំ ២០១៧ និងត្រូវបានអនុម័តកាលពីថ្ងៃទី ១២ ខែធ្នូ ឆ្នាំ ២០១៨។

សន្ធិសញ្ញានេះមានចំនួន ២០ប្រការ ដែលបង្កើតក្នុងគោលបំណងជួយសម្រួលដល់កិច្ចសហប្រតិបត្តិការក្នុងការគ្រប់គ្រងបទល្មើសឱ្យមានប្រសិទ្ធភាពរវាងគូភាគី ពង្រឹងទំនាក់ទំនងរវាងគូភាគី តាមការចុះហត្ថលេខាលើសន្ធិសញ្ញាបត្យាប័ននេះ។

## ១.២.បត្យាប័នក្នុងករណីមិនមានសន្ធិសញ្ញា

ក្របខណ្ឌនៃបត្យាប័ននេះ សំដៅលើបត្យាប័នក្នុងករណីដែលព្រះរាជាណាចក្រកម្ពុជាធ្វើបត្យាប័នជាមួយរដ្ឋបរទេសដែលពុំមានសន្ធិសញ្ញាស្តីពីបត្យាប័នជាមួយប្រទេសកម្ពុជា។

ក្នុងការធ្វើបត្យាប័នជាមួយរដ្ឋបរទេសដែលពុំមានសន្ធិសញ្ញាបត្យាប័នជាមួយកម្ពុជា ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជាបានបញ្ញត្តអំពីបត្យាប័នសម្រាប់ធ្វើជានីតិវិធីនៃនីតិរួមទាក់ទងនឹងការធ្វើបត្យាប័នសម្រាប់ព្រះរាជាណាចក្រកម្ពុជាក្នុងករណីដែលពុំមានកិច្ចព្រមព្រៀងចែងអំពីនីតិវិធីលំអិតស្តីពីបត្យាប័ន។

ដើម្បីបង្កើតឱ្យមាននីត្យានុកូលភាពក្នុងការធ្វើបត្យាប័នក្នុងព្រះរាជាណាចក្រកម្ពុជា ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជាបានបញ្ញត្តអំពីបត្យាប័នក្នុង ជំពូកទី ២នៃគន្ថីទី៩ ដែលជានីតិវិធីដោយឡែករបស់ក្រមនីតិវិធីព្រហ្មទណ្ឌ។ បញ្ញត្តិនៃក្រមនីតិវិធីព្រហ្មទណ្ឌបានកំណត់អំពីលក្ខខណ្ឌ និងនីតិវិធីផ្សេងៗដើម្បីធ្វើបត្យាប័នដែលទាក់ទងនឹងព្រះរាជាណាចក្រកម្ពុជា។

សរុបមកនៅពេលដែលមិនមានសន្ធិសញ្ញាស្តីពីបត្យាប័នជាមួយរដ្ឋធ្វើសំណើបត្យាប័នទេ ជាគោលការណ៍ត្រូវអនុវត្តតាមនីតិវិធីរួមស្តីពីបត្យាប័នដែលមានចែងក្នុងក្រមនីតិវិធីព្រហ្មទណ្ឌ។ ដូចនេះប្រទេសមួយចំនួនដែលមិនមានសន្ធិសញ្ញាស្តីពីបត្យាប័នជាមួយកម្ពុជា បើមានការស្នើសុំធ្វើបត្យាប័នត្រូវអនុវត្តតាមលក្ខខណ្ឌដែលមានចែងក្នុងក្រមនីតិវិធីព្រហ្មទណ្ឌ។

## ១.៣.ក្របខណ្ឌនៃបត្យាប័នដែលមានចែងក្នុងច្បាប់ពិសេស

ក្របខណ្ឌនៃបត្យាប័ននេះ សំដៅលើបត្យាប័នក្នុងករណីដែលមានច្បាប់ពិសេសចែងអំពីនីតិវិធីបត្យាប័នតួយ៉ាងដូចជា ច្បាប់ស្តីពីការប្រឆាំងនឹងភេរវកម្ម និងច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀនជាដើម។

### ក.ច្បាប់ស្តីពីការប្រឆាំងនឹងភេរវកម្ម

ច្បាប់ស្តីពីការប្រឆាំងនឹងភេរវកម្ម ដែលរដ្ឋសភាបានអនុម័ត កាលពីថ្ងៃទី២៦ ខែមិថុនា ឆ្នាំ២០០៧ នាសម័យប្រជុំរដ្ឋសភាលើកទី៦ នីតិកាលទី៣ ដែលព្រឹទ្ធសភាបានយល់ស្របតាមទម្រង់ និងគតិនៃច្បាប់នេះទាំងស្រុងដោយគ្មានការកែប្រែអ្វីឡើយ កាលពីថ្ងៃទី១០ ខែកក្កដា ឆ្នាំ២០០៧ នាសម័យប្រជុំពេញអង្គលើកទី៣ នីតិកាលទី២ ហើយដែលត្រូវបានប្រកាសឱ្យប្រើដោយព្រះមហាក្សត្រ នាថ្ងៃទី២០ ខែកក្កដា ឆ្នាំ ២០០៧។

ច្បាប់នេះ មាន ១១១មាត្រា និងចែកជា ១៣ជំពូក ដោយក្នុង ជំពូកទី១២ បញ្ញត្តអំពីបត្យាប័ន និងជំនួយទៅវិញទៅមក ទាក់ទងនឹងបទល្មើសភេរវកម្ម ហើយផ្នែកទី ១ នៃជំពូកទី១២នេះចែងអំពីបត្យាប័នក្នុងគោលបំណងដើម្បីធ្វើបត្យាប័នទៅកាន់ ឬមកពីបរទេសដែលមានសន្ធិសញ្ញាបត្យាប័នជាមួយកម្ពុជា និងធ្វើបត្យាប័នទៅកាន់រដ្ឋបរទេសដែលកម្ពុជាមិនមានសន្ធិសញ្ញាបត្យាប័នជាមួយ ហើយជាបញ្ញត្តិសម្រាប់គ្រប់គ្រងក្នុងការធ្វើបត្យាប័នចំពោះបទល្មើសទាក់ទងនឹងអំពើភេរវកម្ម។

### ខ.ច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន

ច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀនដែលរដ្ឋសភាបានអនុម័ត កាលពីថ្ងៃទី២៥ ខែវិច្ឆិកា ឆ្នាំ២០១១ នាសម័យប្រជុំរដ្ឋសភាលើកទី៧ នីតិកាលទី៤ និងដែលព្រឹទ្ធសភាបានយល់ស្របតាមទម្រង់ និងគតិនៃច្បាប់នេះទាំងស្រុងដោយគ្មានការកែប្រែអ្វីឡើយ កាលពីថ្ងៃទី១៦ ខែធ្នូ ឆ្នាំ២០១១ នាសម័យប្រជុំពេញអង្គលើកទី១០ នីតិកាលទី២។

ច្បាប់នេះបង្កើតឡើងក្នុងគោលបំណង បង្ការ ទប់ស្កាត់ ប្រយុទ្ធប្រឆាំងបទល្មើសគ្រឿងញៀន ត្រួតពិនិត្យរាល់សកម្មភាពស្របច្បាប់ទាក់ទងនឹងគ្រឿងញៀននៅក្នុងព្រះរាជាណាចក្រកម្ពុជា និងធានាការអនុវត្តកាតព្វកិច្ចរបស់ព្រះរាជាណាចក្រកម្ពុជាដែលជាភាគីនៃអនុសញ្ញា និងពិធីសាររបស់អង្គការសហប្រជាជាតិដែលទាក់ទងនឹងគ្រឿងញៀន។

ផ្អែកតាមខ្លឹមសារនៃច្បាប់ស្តីពីការត្រួតពិនិត្យ គ្រឿងញៀន ជំពូកទី ៧នៃច្បាប់នេះបានចែងអំពីបត្យាប័ន និងការជួយគ្នាទៅវិញទៅមកផ្នែកច្បាប់ ដោយផ្នែកទី១នៃជំពូកនេះចែងអំពីបត្យាប័នក្នុងគោលបំណងដើម្បីធ្វើបត្យាប័ននៃអណិកជនបរទេសលើដែនដីនៃព្រះរាជាណាចក្រកម្ពុជា និងដើម្បីជាបញ្ញត្តិសម្រាប់គ្រប់គ្រងក្នុងការធ្វើបត្យាប័នចំពោះបទល្មើសទាក់ទងនឹងគ្រឿងញៀន។

## ២.លក្ខខណ្ឌនៃការធ្វើបត្យាប័ន

ដើម្បីធានានូវ នីត្យានុកូលភាព និងនិយតភាពនៃបត្យាប័ន ក្រមនីតិវិធីព្រហ្មទណ្ឌ ក៏ដូចជាកិច្ចព្រមព្រៀងបត្យាប័នបានកំណត់នូវលក្ខណ្ឌមួយចំនួនសម្រាប់ធ្វើបត្យាប័នបាន។ ដើម្បីឱ្យនីតិវិធីបត្យាប័នចាប់ផ្តើម ជាដំបូងត្រូវគោរពនូវលក្ខខណ្ឌនៃបត្យាប័នជាមុនសិន។ លក្ខខណ្ឌនៃការធ្វើបត្យាប័នត្រូវបានកំណត់ដោយក្រមនីតិវិធីព្រហ្មទណ្ឌដែលបញ្ញត្តិនៃក្រមនេះបានកំណត់នូវលក្ខខណ្ឌមួយចំនួនសម្រាប់ធ្វើបត្យាប័នមានដូចជា លក្ខខណ្ឌទាក់ទងនឹងបទល្មើស លក្ខខណ្ឌទាក់ទងនឹងបុគ្គលដែលត្រូវធ្វើបត្យាប័ន លក្ខខណ្ឌទាក់ទងនឹងទោសដាក់ពន្ធនាគារ និងលក្ខខណ្ឌទាក់ទងនឹងពាក្យសុំធ្វើបត្យាប័ន។

### ២.១.លក្ខខណ្ឌទាក់ទងនឹងបទល្មើស

បត្យាប័ន គឺសំដៅទៅដល់នីតិវិធីទាំងឡាយនៃទំនាក់ទំនងរវាងរដ្ឋ និងរដ្ឋក្នុងការផ្ទេរ និងការបញ្ជូនជនល្មើស ហើយបទល្មើសជាធាតុផ្សំសំខាន់ក្នុងនីតិវិធីបត្យាប័ន ហេតុនេះដើម្បីអាចធ្វើបត្យាប័នបានលុះត្រាតែបទល្មើសដែលត្រូវធ្វើបត្យាប័ននោះ មានចែងក្នុងច្បាប់របស់រដ្ឋដាក់សំណើផង និងមានចែងក្នុងរដ្ឋទទួលសំណើផងដែលនេះជាគោលការណ៍ទ្វិកភាពនៃបទល្មើស។

បត្យាប័នអាចធ្វើទៅបានលុះត្រាតែ អំពើដែលត្រូវចោទប្រកាន់លើ បុគ្គលដែលគេទាមទារនោះជាបទល្មើសតាមច្បាប់របស់រដ្ឋធ្វើសំណើផង និងតាមច្បាប់កម្ពុជាផងទោះបីជា :

- អំពើដែលជាបទល្មើសស្ថិតនៅក្នុងប្រភេទបទល្មើសមិនដូចគ្នា ឬ
- ឈ្មោះបទល្មើស ការប្រើបច្ចេកស័ព្ទ ឬនិយមន័យ ឬការកំណត់លក្ខណៈបទល្មើសមិនដូចគ្នា ឬ
- ធាតុផ្សំបទល្មើសនៃច្បាប់របស់រដ្ឋផ្ញើសំណើខុសគ្នាពីធាតុផ្សំបទល្មើសដែលកំណត់ដោយច្បាប់កម្ពុជាក៏ដោយ ប្រសិនបើពិចារណាទៅលើចំនួនសរុបនៃអំពើដែលត្រូវបានបង្ហាញដោយរដ្ឋផ្ញើសំណើ គឺជាការប្រព្រឹត្តបទល្មើសតាមបញ្ញត្តិនៃច្បាប់ជាធរមាននៅកម្ពុជា ។[២២]

ហេតុនេះ បត្យាប័នអាចធ្វើទៅបានលុះត្រាតែអំពើនៃការចោទប្រកាន់បុគ្គលដែលគេទាមទារនោះជាបទល្មើសដែលមានចែងច្បាប់កម្ពុជាផង និងដោយច្បាប់នៃរដ្ឋផ្ញើសំណើរផង ទោះបីជាការកំណត់នូវប្រភេទបទល្មើសផ្សេងគ្នា ឈ្មោះបទល្មើសផ្សេងគ្នា ការប្រើបច្ចេកស័ព្ទ ឬនិយមន័យ ការកំណត់លក្ខណៈបទល្មើសមិនដូចគ្នា ឬធាតុផ្សំនៃបទល្មើសនៃច្បាប់របស់រដ្ឋផ្ញើសំណើខុសគ្នានឹងកំណត់របស់ច្បាប់កម្ពុជាក្តី។

ឧទាហរណ៍៖ ក្រសួងយុត្តិធម៌បានទទួលលិខិតរបស់ក្រសួងមហាផ្ទៃដែលមានកម្មវត្ថុស្នើសុំធ្វើបត្យាប័នឈ្មោះ ក កាន់អត្តសញ្ញាណប័ណ្ណលេខ....មានទីលំនៅបច្ចុប្បន្ននៅផ្ទះលេខ...សង្កាត់បឹងសាឡាង ខណ្ឌទួលគោករាជធានីភ្នំពេញ ជានីតិជន ដោយសារបុគ្គលរូបនេះ ត្រូវបានចោក្រមស៊ើបសួរនៃសាលាដំបូងរាជធានីភ្នំពេញចេញដីកាបង្គាប់ឱ្យចាប់ខ្លួន ចុះថ្ងៃទី១១ ខែកក្កដា ឆ្នាំ២០១៧ ពីបទ ឆបោក តាម មាត្រា ៣៧៧ និង៣៧៨ នៃក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ប្រព្រឹត្តនៅរាជធានីភ្នំពេញ កាលពីឆ្នាំ២០១៣។

កាលពីថ្ងៃទី៣១ ខែមករា ឆ្នាំ២០១៨ ការិយាល័យនគរបាលអន្តរជាតិទីក្រុងវៀងច័ន្ទ ប្រទេសឡាវ បានជូនដំណឹងអំពីការចាប់ខ្លួន ឈ្មោះ ក កាន់លិខិតឆ្លងដែនលេខ..........ដែលត្រូវបានចាប់ខ្លួនកាលពីថ្ងៃទី២៩ ខែមីនា ឆ្នាំ២០១៧ ពីបទឆបោកប្រជាជនឡាវ តាមបញ្ញត្ត មាត្រា ១២០ នៃក្រមព្រហ្មទណ្ឌឡាវ និងបានឃុំខ្លួនចាប់ពីថ្ងៃទី០៦ ខែមេសា ឆ្នាំ២០១៧ ដល់បច្ចុប្បន្ននៅពន្ធនាគារ PHONTONG ទីក្រុងវៀងច័ន្ទ ប្រទេសឡាវ។ ដោយហេតុថាជនជាប់ចោទបានប្រព្រឹត្តបទល្មើសនៅកម្ពុជា ដោយក្រុមហ៊ុន EBC និងមានដីកាបង្គាប់ឱ្យចាប់ខ្លួនរបស់សាលាដំបូងរាជធានីភ្នំពេញ។ ដូចនេះ ក្រសួងមហាផ្ទៃស្នើសុំធ្វើបត្យាប័នជនត្រូវចោទរូបនេះពីប្រទេសឡាវយកមកផ្តន្ទាទោសតាមច្បាប់ជាធរមាននៅព្រះរាជាណាចក្រកម្ពុជា។

ពាក់ព័ន្ធនឹងករណីនេះ ពិនិត្យឃើញថា ព្រះរាជាណាចក្រកម្ពុជា និងប្រទេសឡាវ មានសន្ធិសញ្ញារវាងព្រះរាជាណាចក្រកម្ពុជា និងសាធារណៈរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ ស្តីពីបត្យាប័ន ហើយជនត្រូវចោទឈ្មោះ ក មានសញ្ជាតិខ្មែរ ត្រូវបានចៅក្រមស៊ើបសួរនៃសាលាដំបូងរាជធានីភ្នំពេញចុះថ្ងៃទី១១ ខែកក្កដា ឆ្នាំ២០១៧ ពីបទឆបោក តាម មាត្រា ៣៧៧ និងមាត្រា៣៧៨ នៃក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ប្រព្រឹត្ត

[២២] ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៨០៧/០២៤, ១០ សីហា ២០០៧, មាត្រា ៥៦៩

នៅរាជធានីភ្នំពេញ កាលពីឆ្នាំ២០១៣ ដែលត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ៦ (ប្រាំមួយ) ខែ ទៅ ៣ (បី) ឆ្នាំ ហើយបទល្មើសនេះ ក៏ជាបទឆបោក តាមបញ្ញត្តិមាត្រា ១២០ នៃក្រមព្រហ្មទណ្ឌឡាវផងដែរ និងឃុំខ្លួនចាប់ពីថ្ងៃទី០៦ ខែមេសា ឆ្នាំ២០១៧ ដល់បច្ចុប្បន្ននៅពន្ធនាគារ PHONTONG ទីក្រុងវៀងច័ន្ទ ប្រទេសឡាវ ដោយអនុលោមតាមប្រការទី១ និងទី២ កថាខណ្ឌទី១ នៃសន្ធិសញ្ញា។[១២]

## ២.២.លក្ខខណ្ឌទាក់ទងនឹងបុគ្គលដែលត្រូវធ្វើបត្យាប័ន

លក្ខខណ្ឌដែលទាក់ទងនឹងបុគ្គលដែលត្រូវធ្វើបត្យាប័នសំដៅលើ បុគ្គលដែលត្រូវទទួលខុសត្រូវក្នុងយន្តការនៃការប្រព្រឹត្តបទល្មើសពោល គឺសំដៅលើចារីនៃបទល្មើសផ្ទាល់ ហើយក្រៅពីបទល្មើសដែលប្រព្រឹត្តដោយចារីផ្ទាល់ ការប៉ុងប៉ងប្រព្រឹត្តបទល្មើស និងការសមគំនិត ក៏អាចក្លាយជាកម្មវត្ថុនៃបត្យាប័នដែរ។

ប្រសិនបើអំពើដែលត្រូវចោទប្រកាន់តាមច្បាប់នៃរដ្ឋធ្វើសំណើជាការប៉ុនប៉ងប្រព្រឹត្តបទល្មើស បត្យាប័នអាចធ្វើទៅបានលុះត្រាតែ ការប៉ុងប៉ងនៃការប្រព្រឹត្តបទល្មើសនោះត្រូវផ្តន្ទាទោសតាមច្បាប់កម្ពុជាដែរ។

បទប្បញ្ញត្តិនៃមាត្រានេះ ត្រូវយកមកអនុវត្តផងដែរលើករណីសមគំនិត។[១៣]

ដើម្បីឱ្យបត្យាប័នអាចធ្វើចំពោះការប៉ុនប៉ងនិងការសមគំនិត គឺត្រូវអនុវត្តដូចគ្នានឹងលក្ខខណ្ឌនៃអំពើល្មើសផងដែរ ពោលគឺត្រូវយកគោលការណ៍ទ្វិកភាពធ្វើភាពនៃបទល្មើសយកមកអនុវត្តផងដែរ មានន័យថា លុះត្រាច្បាប់ចំពោះរដ្ឋដាក់សំណើធ្វើការផ្តន្ទាទោសចំពោះការប៉ុនប៉ង ហើយរដ្ឋទទួលសំណើក៏ធ្វើការផ្តន្ទាទោសចំពោះការប៉ុងប៉ងទើបបត្យាប័នអាចធ្វើទៅលើអំពើប៉ុនប៉ងបាន។

ចំពោះការសមគំនិតក៏ដូចគ្នាដែរ បត្យាប័នអាចធ្វើទៅលើអ្នកសមគំនិតបានលុះត្រាតែ បទល្មើសនៅក្នុងរដ្ឋដាក់សំណើ អ្នកសមគំនិតក៏ត្រូវផ្តន្ទាទោស ហើយបទល្មើសដដែលនោះក្នុងរដ្ឋទទួលសំណើ អ្នកសមគំនិតក៏ត្រូវផ្តន្ទាទោស។

## ២.៣.លក្ខខណ្ឌទាក់ទងនឹងទីកន្លែងប្រព្រឹត្តបទល្មើស

ជាធម្មតារដ្ឋនីមួយៗពុំដែលធ្វើបត្យាប័នបញ្ជូនពលរដ្ឋសាមីរបស់ខ្លួន ឱ្យទៅអាជ្ញាធរនៃប្រទេសផ្សេងយកទៅវិនិច្ឆ័យសេចក្តី ឬអនុវត្តទោសនោះទេ លើកលែងតែមានសន្ធិសញ្ញាអន្តរជាតិជាក់លាក់ណាមួយបញ្ញត្តផ្សេងពីនេះ ។

[១២] កំណត់បង្ហាញរឿងរបស់ក្រសួងយុត្តិធម៌ស្តីពី សំណើសុំបត្យាប័នពីប្រទេសឡាវ

[១៣] ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៨០៧/០២៤, ១០ សីហា ២០០៧, មាត្រា ៥៧០

ជាក់ស្តែង ក្រមនីតិវិធីព្រហ្មទណ្ឌពុំមានបញ្ញត្តិចែងច្បាស់ពីការបដិសេធមិនធ្វើបត្យាប័នពលរដ្ឋខ្មែរនោះទេ ក៏ប៉ុន្តែតាមរយៈខ្លឹមសារនៃបទប្បញ្ញត្តិមួយចំនួនអាចឱ្យបកស្រាយបានថា ការធ្វើបត្យាប័នពលរដ្ឋខ្មែរឱ្យទៅប្រទេសដទៃមិនអាចនឹងធ្វើបានទេ។

ព្រះរាជាណាចកកម្ពុជាអាចយល់ព្រមប្រគល់ដល់រដ្ឋបរទេស នូវអាណិកជនបរទេសដែលស្នាក់នៅលើដែនដីកម្ពុជា ហើយដែលជាកម្មវត្ថុនៃ នីតិវិធីចោទប្រកាន់តាមផ្លូវតុលាការនៅក្នុងរដ្ឋនេះ ឬត្រូវបានផ្តន្ទាទោសដោយដាក់ពន្ធនាគារដោយតុលាការនៃរដ្ឋនេះ។[១៤]

ការប្រើប្រាស់ពាក្យ “អាណិកជនបរទេស ” នៅក្នុងបញ្ញត្តិខាងលើនេះនាំឱ្យមានការសន្និដ្ឋានថាបត្យាប័នដែលមានចែងនៅក្នុងក្រមនីតិវិធីព្រហ្មទណ្ឌអាចធ្វើបានសម្រាប់តែជនបរទេស ពោលគឺបុគ្គលដែលពុំមានសញ្ញាតិខ្មែរ។

លើសពីនេះទៅទៀត អនុសញ្ញាបត្យាប័នរវាងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា និងរដ្ឋាភិបាលនៃសាធារណរដ្ឋបារាំងបានហាមឃាត់ការធ្វើបត្យាប័នបុគ្គលដែលមានសញ្ជាតិនៃរដ្ឋទទួលសំណើ។

ការកំណត់សញ្ជាតិត្រូវធ្វើឡើងនៅកាលបរិច្ឆេទនៃការទទួលបានសំណើធ្វើបត្យាប័ន។[១៥]

ជារួមមក ទាំងក្រមនីតិវិធីព្រហ្មទណ្ឌ និងកិច្ចព្រមព្រៀងបត្យាប័នបានហាមឃាត់ក្នុងការធ្វើបត្យាប័នប្រជាពលរដ្ឋខ្មែរទៅប្រទេសដទៃដែលស្របនឹងគោលការណ៍ជាមូលដ្ឋានដែលមានចែងក្នុងមាត្រា ៣៣ នៃរដ្ឋធម្មនុញ្ញ គឺហាមឃាត់មិនឱ្យធ្វើបត្យាប័នរដ្ឋសាមីឡើយ។

មិនត្រឹមតែប៉ុណ្ណោះ ប្បញ្ញតិនៃមាត្រា ៥៧២ នៃក្រមនីតិវិធីព្រហ្មទណ្ឌបានកំណត់ថា កាលណាអំពើដែលត្រូវចោទប្រកាន់ចំពោះបុគ្គលដែលគេទាមទារបានប្រព្រឹត្តនៅលើទឹកដីនៃរដ្ឋធ្វើសំណើ បត្យាប័នអាចធ្វើទៅបានទោះបីជាបុគ្គលដែលគេទាមទារមិនមានសញ្ជាតិដូចរដ្ឋស្នើសុំក៏ដោយចំពោះបទល្មើស ដែលប្រព្រឹត្តក្រៅដែនដីនៃរដ្ឋធ្វើសំណើបត្យាប័នអាចធ្វើទៅបានលុះត្រាតែបុគ្គលដែលគេទាមទារនោះមានសញ្ជាតិដូចរដ្ឋដែលធ្វើសំណើ។ ផ្អែកតាមបញ្ញត្តិនេះ បត្យាប័នអាចធ្វើទៅបាន លុះត្រាតែបុគ្គលដែលគេទាមទារ មានសញ្ជាតិរបស់រដ្ឋធ្វើសំណើកាលបើអំពើដែលត្រូវចោទប្រកាន់ត្រូវបានប្រព្រឹត្តនៅក្រៅដែនដីនៃរដ្ឋធ្វើសំណើ ក៏ប៉ុន្តែក្នុងករណីដែលអំពើដែលត្រូវបានចោទប្រកាន់កើតឡើងនៅលើទឹកដីនៃរដ្ឋធ្វើសំណើមិនចាំបាច់មានលក្ខខណ្ឌសញ្ជាតិដូចខាងលើឡើយ ។

---

[១៤] ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៨០៧/០២៤, ១០ សីហា ២០០៧, មាត្រា ៥៦៦

[១៥] អនុសញ្ញាស្តីពីបត្យាប័នរវាងព្រះរាជាណាចក្រកម្ពុជា និងសាធារណរដ្ឋបារាំង, នស/រកម/១១២០/០២៦, ១៤ វិច្ឆិកា ២០២០ , មាត្រា៦

ឧទាហរណ៍៖ អាជ្ញាធរនៃប្រទេសកម្ពុជា បានធ្វើសំណើសុំបត្យាប័នលើ លោក ដាយរិក ដែលមានសញ្ជាតិអៀរឡង់ ដោយសារតែ លោក ដាយរិក បានប្រព្រឹត្តបទល្មើសនៅក្នុងប្រទេសម៉ិចសិក ។ នៅក្នុងស្ថានភាពបែបនេះ អនុវត្តតាម មាត្រា ៥៧២ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ការធ្វើបត្យាប័ន លោក ដាយរិក មកកាន់ប្រទេសកម្ពុជា មិនអាចធ្វើទៅបានឡើយពីព្រោះថា លោក ដាយរិក មិនមានសញ្ជាតិកម្ពុជា ហើយបទល្មើសក៏មិនត្រូវបាន ប្រព្រឹត្តនៅលើទឹកដីនៃប្រទេសកម្ពុជាដែរ ។ ម្យ៉ាងវិញទៀត អាជ្ញាធរនៃប្រទេសកម្ពុជាបានធ្វើសំណើសុំបត្យាប័នលើលោក ដាយរិក ដែលមានសញ្ជាតិអាមេរិក ដោយសារតែ លោក ដាយរិក បានប្រព្រឹត្តបទល្មើសនៅក្នុងប្រទេសកម្ពុជា។ ក្នុងករណីនេះតាមមាត្រា ៥៧២ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ការធ្វើបត្យាប័នលោក ដាយរិក ទៅកាន់ប្រទេសកម្ពុជាអាចត្រូវបានអនុញ្ញាត ។

## ២.៤.លក្ខខណ្ឌទាក់ទងនឹងទោសដាក់ពន្ធនាគារ

ដោយសារតែមានការផ្តន្ទាទោសទៅលើបទល្មើសខុសៗគ្នាតាមច្បាប់នៃប្រទេសនីមួយៗ ហើយមានប្រទេសខ្លះនៅបន្តរក្សានូវទោសប្រហារជីវិតទៀតនោះទើបទោសដាក់ពន្ធនាគារជាលក្ខខណ្ឌសំខាន់មួយក្នុងការធ្វើបត្យាប័ន។

បត្យាប័នអាចធ្វើទៅបានលុះត្រាតែអំពើដែលត្រូវចោទប្រកាន់លើបុគ្គលដែលគេទាមទារនោះមានកម្រិតអតិបរមានៃទោសដាក់ពន្ធនាគារយ៉ាងតិចស្មើនឹង២ឆ្នាំ តាមច្បាប់នៃរដ្ឋធ្វើសំណើ។ ប៉ុន្តែបត្យាប័នអាចធ្វើទៅបានប្រសិនបើបុគ្គលដែលគេទាមទារនោះត្រូវបានតុលាការនៃរដ្ឋធ្វើសំណើផ្តន្ទាទោសដាក់ពន្ធនាគារយ៉ាងតិចបំផុត ៦ខែ ហើយសេចក្តីសម្រេចនោះបានចូលជាស្ថាពរទោះជាទោសដែលបានកំណត់នោះមានថិរវេលាប៉ុន្មានក៏ដោយ ។[១៦]

ក្រៅពីក្រមនីតិវិធីព្រហ្មទណ្ឌ កិច្ចព្រមព្រៀងបត្យាប័នបានកំណត់ពីលក្ខខណ្ឌទាក់ទងនឹងទោសដាក់ពន្ធនាគារក្នុងការធ្វើបត្យាប័ននេះដូចគ្នានឹងក្រមនីតិវិធីដែរ លើកលែងតែសន្ធិសញ្ញាបត្យាប័នរវាង ព្រះរាជាណាចក្រកម្ពុជា និងសាធារណៈរដ្ឋប្រជាមានិតចិន ដែលបានកំណត់ថា បទល្មើសដែលអាចធ្វើបត្យាប័នបាន គឺជាបទល្មើសដែលអាចផ្តន្ទាទោសតាមធរមាននៃច្បាប់របស់ភាគីចុះកិច្ចព្រមព្រៀងទាំងពីរដោយ ការដាក់ពន្ធនាគារ ឬដោយរូបភាពផ្សេងទៀតនៃការឃុំឃាំងសំរាប់រយៈពេលលើសពីមួយឆ្នាំឡើងទៅ ឬការផ្តន្ទាទោសណាមួយដែលធ្ងន់ជាងនេះ ។

[១៦] ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៨០៧/០២៤, ១០ សីហា ២០០៧, មាត្រា ៥៧១

### ២.៥.លក្ខខណ្ឌទាក់ទងនឹងពាក្យសុំធ្វើបត្យាប័ន

បត្យាប័នអាចធ្វើទៅបាន លុះត្រាតែរដ្ឋធ្វើសំណើសន្យាថា មិនធ្វើការចោទប្រកាន់បទល្មើសណាមួយផ្សេងក្រៅពីបទល្មើសដែលចែងក្នុងពាក្យសុំធ្វើបត្យាប័ននោះទេ ហើយកាលណាបទល្មើសនោះបានប្រព្រឹត្តមុនពេលចាប់ខ្លួនបុគ្គលដែលគេទាមទារនោះ ក៏ប៉ុន្តែការធ្វើការចោទប្រកាន់អាចធ្វើទៅបានលុះត្រាតែមានការយល់ព្រមដោយកម្ពុជា ។[១៧]

## ៣.មោឃភាពនៃបត្យាប័ន

ក្នុងករណីដែលព្រះរាជាណាចក្រកម្ពុជាជារដ្ឋដាក់សំណើ នៅពេលដែលរដ្ឋទទួលសំណើបានយល់ព្រមធ្វើបត្យាប័នបុគ្គលដែលប្រទេសកម្ពុជាទាមទារឱ្យធ្វើបត្យាប័នបុគ្គលនេះនឹងត្រូវបញ្ជូនឱ្យមកកាន់ប្រទេសកម្ពុជាវិញ។ ក្រោយពីបុគ្គលដែលត្រូវធ្វើបត្យាប័នបានមកដល់ប្រទេសកម្ពុជា ក្រមនីតិវិធីព្រហ្មទណ្ឌផ្តល់សិទ្ធិឱ្យបុគ្គលដែលត្រូវបានធ្វើបត្យាប័នដើម្បីដាក់ពាក្យបណ្តឹងសុំមោឃភាពនៃបត្យាប័នទៅសភាស៊ើបសួរនៃសាលាឧទ្ធរណ៍ភ្នំពេញ ក្នុងរយៈពេល ១៥ថ្ងៃ។[១៨]

### ៣.១.បណ្តឹងមោឃភាព

បណ្តឹងមោឃភាពនៃបត្យាប័នជាបណ្តឹងដែលធ្វើឡើងដោយបុគ្គលដែលត្រូវបានធ្វើបត្យាប័នសុំមោឃភាពនីតិវិធីនៃការធ្វើបត្យាប័នរបស់រដ្ឋបរទេសនៅចំពោះមុខសភាស៊ើបសួរនៃសាលាឧទ្ធរណ៍ភ្នំពេញ។

ចំពោះនីតិវិធីលើបណ្តឹងមោឃភាពនៃបត្យាប័ននេះត្រូវធ្វើឡើងនៅចំពោះមុខសភាស៊ើបសួរ ដោយសភាស៊ើបសួរត្រូវធ្វើការសម្រេចសេចក្តី ក្រោយពីបានស្តាប់ចម្លើយរបស់បុគ្គលដែលត្រូវបានធ្វើបត្យាប័ន សេចក្តីសន្និដ្ឋានសុំរបស់អគ្គព្រះរាជអាជ្ញា និងសេចក្តីសន្និដ្ឋានការពាររបស់មេធាវី ។[១៩]

### ៣.២.អនុភាពមិនផ្អាកនៃបណ្តឹងសុំមោឃភាព

ក្នុងនីតិវិធីបត្យាប័ន ទោះបីជាមានបណ្តឹងសុំមោឃភាពនៃបត្យាប័នដើម្បីទាមទារឱ្យពិនិត្យអំពីនិយតភាពនៃនីតិវិធីបត្យាប័នក៏ដោយក៏បណ្តឹងនោះពុំមានអនុភាពផ្អាកនីតិវិធីចោទប្រកាន់ដែលកំពុងធ្វើទៅលើបទល្មើសដែលជាកម្មវត្ថុនៃបត្យាប័នឡើយ។ ពាក្យសុំមោឃភាពនៃបត្យាប័នមិនផ្អាកនីតិវិធីចោទប្រកាន់ដែលកំពុងធ្វើទៅលើជនដែលត្រូវធ្វើបត្យាប័នឡើយ។[២០]

---

[១៧] ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៨០៧/០២៤, ១០ សីហា ២០០៧, មាត្រា ៥៧៧

[១៨] ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៨០៧/០២៤, ១០ សីហា ២០០៧,មាត្រា ៥៩០

[១៩] ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៨០៧/០២៤, ១០ សីហា ២០០៧, មាត្រា ៥៩១

[២០] ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៨០៧/០២៤, ១០ សីហា ២០០៧, មាត្រា ៥៩២

### ៣.៣.អនុភាពនៃមោឃកម្មចំពោះបត្យាប័ន

ក្រោយសភាស៊ើបសួរពិនិត្យពីនិយតភាពនៃបត្យាប័នហើយ ប្រសិនបើសភាស៊ើបសួរសម្រេចបដិសេធនីតិវិធីបត្យាប័ននោះ បត្យាប័ននឹងត្រូវចាត់ទុកជាមោឃៈ។

ប្រសិនបើបត្យាប័នត្រូវបានចាត់ទុកជាមោឃៈដោយសេចក្តីសម្រេចជាស្ថាពររបស់សភាស៊ើបសួរនីតិវិធីចោទប្រកាន់ដែលកំពុងប្រព្រឹត្តទៅត្រូវបញ្ចប់បុគ្គលដែលត្រូវបានធ្វើបត្យាប័នត្រូវបានដោះលែងឱ្យមានសេរីភាពវិញ និងមានលទ្ធភាពចាកចេញដោយសេរីពីដែនដីកម្ពុជា។

ប៉ុន្តែលុះផុតរយៈពេល ៣០(សាមសិប)ថ្ងៃ គិតចាប់ពីថ្ងៃដោះលែងឱ្យមានសេរីភាពបុគ្គលដែលត្រូវ បានធ្វើបត្យាប័នអាចត្រូវបានគេចាប់ខ្លួនម្តងទៀតនៅលើដែនដីកម្ពុជា និងត្រូវជាកម្មវត្ថុនៃនីតិវិធីចោទប្រកាន់ជាថ្មីចំពោះអំពើដែលនាំឱ្យមានការធ្វើបត្យាប័នបុគ្គលនេះបាន។[៧១]

[៧១] ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៨០៧/០២៤, ១០ សីហា ២០០៧, មាត្រា ៥៩៣

# ជំពូកទី ៣
# នីតិវិធីបញ្ញាប័ន

# ជំពូកទី ៣
# នីតិវិធីបត្យាប័ន

ការធ្វើបត្យាប័ន គឺត្រូវតែពឹងផ្អែកលើឆន្ទៈជួយគ្នាទៅវិញទៅមក និងមនោសញ្ចេតនារបស់ប្រទេសជាដៃគូ ដើម្បីបង្ក្រាបបទល្មើសដែលកើតមានលើទឹកដីរបស់ខ្លួន ព្រមទាំងធានាបាននូវគុណភាពនៃការធ្វើបត្យាប័នប្រកបដោយភាតរភាព និងនិរន្តរភាព។ បន្ទាប់ពីលក្ខខណ្ឌនៃបត្យាប័នត្រូវបានបំពេញរួចរាល់ហើយ អាជ្ញាធរមានសមត្ថកិច្ចធ្វើបត្យាប័នអាចផ្ដើមនីតិវិធីនៃការធ្វើបត្យាប័នបាន។ ចំពោះព្រះរាជាណាចក្រកម្ពុជា នីតិវិធីនៃការធ្វើបត្យាប័នត្រូវបានបែងចែងជាពីរអាស្រ័យលើករណីដែលកម្ពុជា ជារដ្ឋទទួលសំណើឬកម្ពុជាជារដ្ឋដាក់សំណើ។

ប៉ុន្តែទោះបីជាលក្ខខណ្ឌនៃការធ្វើបត្យាប័នត្រូវបានបំពេញក៏ដោយក៏ព្រះរាជាណាចក្រកម្ពុជាបានកំណត់នូវគោលការណ៍មួយចំនួនហាមមិនឱ្យធ្វើបត្យាប័នឡើយ។

## ១.គោលការណ៍កម្រិតក្នុងការធ្វើបត្យាប័ន

### ១.១.អំពើដែលមានលក្ខណៈនយោបាយ

អំពើដែលអាចជាកម្មវត្ថុនៃបត្យាប័ន លុះត្រាតែអំពើនោះជាបទល្មើសនៃនីតិរូម ពោលជាបទល្មើសនៃនីតិព្រហ្មទណ្ឌ។ ហេតុនេះអំពើដែលមានលក្ខណៈជានយោបាយអំពើដែលមានលក្ខណៈជាការរើសអើងនិន្នាការពូជសាសន៍ឬក៏សាសនានិងមិនអាចជាកម្មវត្ថុនៃបត្យាប័នបានទេ។ ហើយក្រមនីតិវិធីព្រហ្មទណ្ឌបានកំណត់ថាមិនចាត់ទុកជាបទល្មើសនយោបាយទេចំពោះអំពើហិង្សាដែលធ្វើឱ្យមានគ្រោះថ្នាក់ដល់ជីវិតដល់បូរណភាពខាងរូបកាយ ឬដល់សេរីភាពបុគ្គល។[៦២] ដូច្នេះអំពើហិង្សាដែលធ្វើឱ្យមានគ្រោះថ្នាក់ដល់ជីវិតដល់បូរណភាព រូបកាយ ឬសេរីភាពបុគ្គលនេះជាបទល្មើសនៃនីតិរូម។ ម្យ៉ាងវិញទៀតច្បាប់ស្ដីពីការប្រឆាំងភេរវកម្មថ្មីបានកំណត់ថាថាមិនអាចចាត់ទុកជា អំពើនយោបាយ ឬបទល្មើសយោបាយបានទេអំពើហិង្សាដែលបានប្រព្រឹត្តទៅលើប្រមុខរដ្ឋប្រមុខរាជរដ្ឋាភិបាល ឬក្រុមគ្រួសាររបស់គាត់ដូច្នេះ ការដែលអំពើហិង្សាទៅលើប្រមុខរដ្ឋឬប្រមុខរដ្ឋាភិបាល ឬក្រុមគ្រួសាររបស់គាត់ក៏មិនអាចជាកម្មវត្ថុនៃការចាត់ថាជាបទនយោបាយ។ ចំណែកឯកិច្ចព្រមព្រៀងបត្យាប័នកំណត់ថាអំពើដែលមានលក្ខខណៈនយោបាយជា មូលដ្ឋានដាច់ខាតក្នុងការបដិសេធក្នុងការធ្វើបត្យាប័ន ពោលគឺបត្យាប័នមិនអាចធ្វើទៅលើអំពើដែលមានលក្ខខណៈនយោបាយបានឡើយ។[៦៣]

ឧទាហរណ៍៖ បន្ទាប់ពីមានសំណើជាផ្លូវការពីភាគីថៃ ប្រទេសកម្ពុជាបានបដិសេធមិនធ្វើបត្យាប័នលោក ថាក់ស៊ីន ស៊ីណាវ៉ាត់ ។ រដ្ឋាភិបាលកម្ពុជាបានច្រានចោលសំណើជាផ្លូវការរបស់រដ្ឋាភិបាលថៃដែលបាន

---

[៦២] ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៨០៧/០២៤, ១០ សីហា ២០០៧, មាត្រា ៥៧៣

[៦៣] កិច្ចព្រមព្រៀងស្តីពីបត្យាប័ន រវាងព្រះរាជាណាចក្រកម្ពុជា និងសាធារណរដ្ឋកូរ៉េ, នស/រកម/០១១១/០០១, ០៦ មករា ២០១១, មាត្រា៣

ស្នើសុំធ្វើបត្យាប័នលោកថាក់ ស៊ីនស៊ីណាវ៉ាត់ ទៅកាន់ប្រទេសថៃ ដោយចាត់ទុកថា លោក ថាក់ស៊ីន ជាជនរងគ្រោះផ្នែកនយោបាយ។ តាមរយៈលោក Chalothorn Phaovibul ភារធារីស្ថានទូតថៃប្រចាំប្រទេសកម្ពុជាបានដាក់លិខិតមួយច្បាប់ស្ដីពីការសុំធ្វើបត្យាប័ន លោក ថាក់ ស៊ីនស៊ីណាវ៉ាត់ ទៅកាន់ប្រទេសថៃវិញ ក្រោយពីលោកបានមកដល់ប្រទេសកម្ពុជា ដើម្បីបំពេញតួនាទីរបស់លោកជាទីប្រឹក្សារដ្ឋាភិបាល ទទួលបន្ទុកសេដ្ឋកិច្ច និងជាទីប្រឹក្សារបស់ លោកនាយករដ្ឋមន្ត្រី ហ៊ុន សែន។ លោកនាយករដ្ឋមន្ត្រី ហ៊ុន សែន បានថ្លែងប្រាប់ទូរទស្សន៍ជាតិ និង អន្តរជាតិហើយត្រូវបានទូរទស្សន៍ជាតិកម្ពុជាចាក់ផ្សាយថា លោកនាយករដ្ឋមន្ត្រី ហ៊ុន សែន បានបញ្ជាក់ថាកម្ពុជាមិនធ្វើបត្យាប័នលោកថាក់ស៊ីនទៅកាន់ប្រទេសថៃវិញ ហើយបានបញ្ជូនត្រឡប់ទៅវិញនូវលិខិតបដិសេធរបស់កម្ពុជា អំពីការមិនបញ្ជូន។ នៅក្នុងលិខិតជាផ្លូវការរបស់ក្រសួងការបរទេសកម្ពុជា ឆ្លើយតបទៅនឹងលិខិតកំណត់ការទូតរបស់ក្រសួងការបរទេសថៃបានបញ្ជាក់ថាយោងតាមមាត្រា៣នៃសន្ធិសញ្ញាបត្យាប័នរវាងប្រទេសកម្ពុជា និងប្រទេសថៃ រដ្ឋាភិបាលកម្ពុជាបានចាត់ទុក ការកាត់ទោសលោក ថាក់ស៊ីន ស៊ីណាវ៉ាត់ និងដំណើរការច្បាប់ប្រឆាំងនឹងគាត់ គឺជាការប្រព្រឹត្តទៅដោយមូលហេតុនយោបាយ។ នៅក្នុងលិខិតដដែលបាន បញ្ជាក់ទៀតថាដោយយោងទៅលើភាពជាក់ស្ដែងយ៉ាងច្បាស់លាស់ដូចខាងលើនេះហើយទើបរដ្ឋាភិបាលកម្ពុជាមិនអាចចាប់ខ្លួនជាបណ្ដោះអាសន្ន ឬក៏ធ្វើបត្យាប័នលោក ថាក់ស៊ីន ស៊ីណាវ៉ាត់ បានទេ។[៧៤]

## ១.២.អំពើដែលត្រូវបានប្រព្រឹត្តលើដែនដីនិងដែលត្រូវបានផ្ដន្ទាទោសជាស្ថាពររួចហើយ

គោលការណ៍មិនជំនុំជម្រះពីរដងលើរឿងតែមួយ ជាគោលការណ៍ដ៏សំខាន់មួយនៅក្នុងរឿងព្រហ្មទណ្ឌហើយ ត្រូវបានទទួលស្គាល់យ៉ាងជាក់ច្បាស់ដោយមាត្រា១៤ កថាខណ្ឌទី៧ នៃកតិកាសញ្ញាអន្តរជាតិស្ដីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ ។ ការអនុវត្តគោលការណ៍នេះក៏ត្រូវបានទាញចេញពីការបកស្រាយ មាត្រា ១២ នៃក្រមនីតិវិធីព្រហ្មទណ្ឌ និងមាត្រា ២៣ នៃក្រមព្រហ្មទណ្ឌផងដែរ។

បត្យាប័នមិនអាចធ្វើបានទេ កាលណាអំពើដែលត្រូវចោទប្រកាន់បានប្រព្រឹត្តនៅលើដែនដីកម្ពុជា ហើយត្រូវបានជំនុំជម្រះជាស្ថាពររួចហើយនៅកម្ពុជា ។[៧៥]

ជាការសមហេតុផលហើយថា ប្រសិនបើប្រទេសកម្ពុជាដែលជារដ្ឋទទួលសំណើបានជំនុំជម្រះជាស្ថាពរលើបទល្មើស ដែលជាកម្មវត្ថុនៃសំណើ បត្យាប័ននោះគឺមានន័យថា អំពើរបស់បុគ្គលដែលគេទាមទារត្រូវបានតុលាការធ្វើការវិនិច្ឆ័យរួចទៅហើយ ដូច្នេះសំណើសុំធ្វើបត្យាប័នក៏មិនមានអត្ថន័យអ្វីទៀតដែរ ។

---

[៧៤] ដកស្រង់ចេញពីគេហទំព័រ វីអូអេ, រាយការណ៍ដោយៈ លោក ហេងរស្មី

[៧៥] ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៨០៧/០២៤, ១០ សីហា ២០០៧, មាត្រា ៥៧៤

ម្យ៉ាងវិញទៀត បើសិនបើប្រទេសកម្ពុជាយល់ព្រមធ្វើបត្យាប័នបុគ្គលនេះទៅឱ្យរដ្ឋធ្វើសំណើនោះ គឺបានសេចក្តីថានឹងអនុញ្ញាតឱ្យមានការជំនុំជម្រះជាលើកទីពីរចំពោះអំពើដែលត្រូវបានវិនិច្ឆ័យដោយតុលាការកម្ពុជារួចទៅហើយ ។

## ១.៣.ការរលត់បណ្តឹងអាជ្ញា

ជាគោលការណ៍បណ្តឹងអាជ្ញាត្រូវបានរលត់ដោយមូលហេតុមួយចំនួនដែលបានកំណត់ដោយក្រមនីតិវិធីព្រហ្មទណ្ឌ។

ក្រមនីតិវិធីព្រហ្មទណ្ឌបានបញ្ញត្តថា មូលហេតុនៃការរលត់បណ្តឹងអាជ្ញាមានដូចតទៅៈ

- មរណភាពរបស់ជនល្មើស
- ការលើកលែងទោសជាទូទៅ
- ផុតអាជ្ញាយុកាលនៃបទល្មើស
- និរាករណ៍នៃច្បាប់ព្រហ្មទណ្ឌ
- អាជ្ញាអស់ជំនុំ។

កាលណាបណ្តឹងអាជ្ញាត្រូវផុតរលត់ហើយ ការចោទប្រកាន់ខាងបទល្មើសព្រហ្មទណ្ឌមិនអាចចាប់ផ្តើម ឬត្រូវតែបញ្ចប់។[២៦]

ផ្អែកតាមបញ្ញត្តិខាងលើ កាលណាមូលហេតុទាំងឡាយដែលមានចែងក្នុង មាត្រា ៧ បានកើតឡើង នោះនាំឱ្យបណ្តឹងអាជ្ញាត្រូវផុតរលត់ ហើយនាំឱ្យការចោទប្រកាន់ខាងបទល្មើសព្រហ្មទណ្ឌមិនអាចចាប់ផ្តើម ឬត្រូវតែបញ្ចប់។ ដូចគ្នាផងដែរចំពោះរឿងបត្យាប័ន កាលណាបណ្តឹងអាជ្ញាត្រូវរលត់ នីតិវិធីបត្យាប័នក៏មិនអាចចាប់ផ្តើមបានផងដែរ។

បត្យាប័នមិនអាចធ្វើបានទេ នៅក្នុងករណីដែលបណ្តឹងអាជ្ញាបានផុតរលត់តាមច្បាប់របស់រដ្ឋធ្វើសំណើ ។ កាលណាអំពើដែលត្រូវចោទប្រកាន់បានប្រព្រឹត្តនៅលើដែនដីកម្ពុជា បត្យាប័នមិនអាចធ្វើបានទេ នៅក្នុងករណី ដែលបណ្តឹងអាជ្ញាត្រូវបានផុតរលត់តាមច្បាប់កម្ពុជា ។[២៧]

អាស្រ័យហេតុនេះហើយនីតិវិធីនៃការធ្វើបត្យាប័នមិនអាចចាប់ផ្តើមធ្វើបានឡើយ ក្នុងករណីដែលមូលហេតុទាំងឡាយខាងក្រោមនេះបានកើតឡើងៈ

---

[២៦] ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៨០៧/០២៤, ១០ សីហា ២០០៧, មាត្រា ៧

[២៧] ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៨០៧/០២៤, ១០ សីហា ២០០៧, មាត្រា ៥៧៥

**ក.មរណភាពនៃជនល្មើស**

មរណភាពនៃជនល្មើស សំដៅទៅលើការស្លាប់បាត់បង់ជីវិតរបស់បុគ្គលដែលបានប្រព្រឹត្តបទល្មើស។ ក្នុងរឿងរដ្ឋប្បវេណីច្បាប់បានអនុញ្ញាតឱ្យមានការទទួលខុសត្រូវផ្នែករដ្ឋប្បវេណីរបស់អ្នកដទៃបាន។

ប៉ុន្តែចំពោះការទទួលខុសត្រូវព្រហ្មទណ្ឌរបស់រូបវន្តបុគ្គលវិញផ្អែកតាមគោលការណ៍ឯកត្តកម្មនៃការទទួលខុសត្រូវព្រហ្មទណ្ឌ គឺបុគ្គលម្នាក់ៗត្រូវទទួលខុសត្រូវព្រហ្មទណ្ឌតែ ចំពោះអំពើលខ្លួនបានប្រព្រឹត្តប៉ុណ្ណោះ។

អាស្រ័យហេតុនេះមរណភាពរបស់ជនល្មើសនាំឱ្យរលត់នូវការទទួលខុសត្រូវព្រហ្មទណ្ឌជាហេតុធ្វើឱ្យមរណភាពរបស់ជនល្មើសជាហេតុមួយដែលនាំឱ្យរលត់បណ្តឹងអាជ្ញាហើយក៏ធ្វើឱ្យនីតិវិធីបត្យាប័នក៏មិនអាចចាប់ផ្តើមបានដែរ។

**ខ.ការផុតអាជ្ញាយុកាល**

អាជ្ញាយុកាលនៃបទល្មើស គឺជារយៈពេលដែលកំណត់ដោយច្បាប់ ចំពោះអនុភាពនៃបណ្តឹងអាជ្ញាដែល ចោទប្រកាន់ពីបទល្មើសដែលក្នុងករណីដែលផុតរយៈពេលកំណត់នេះនោះព្រះរាជអាជ្ញា ពុំអាចធ្វើការចោទ ប្រកាន់បានទេ។

ក្រមនីតិវិធីព្រហ្មទណ្ឌ ចែងថា លើកលែងតែបទប្បញ្ញត្តិនៃមាត្រា ៩ នៃក្រមនេះ ចេញចិរវេលានៃអាជ្ញាយុកាលនៃបណ្តឹងអាជ្ញាមានដូចជា៖

- ១៥ (ដប់ប្រាំ) ឆ្នាំ ចំពោះបទឧក្រិដ្ឋ
- ៥ (ប្រាំ) ឆ្នាំ ចំពោះបទមជ្ឈិម
- ១ (មួយ) ឆ្នាំ ចំពោះបទលហុ។[២៨]

ផ្អែកតាមបញ្ញត្តិខាងលើ អាជ្ញាយុកាលនៃបទល្មើសត្រូវបានកំណត់ទៅតាមទម្ងន់នៃបទល្មើសពោល គឺអាជ្ញាយុកាលនៃបទឧក្រិដ្ឋមានចិរវេលា ១៥ឆ្នាំ អាជ្ញាយុកាលនៃបទមជ្ឈិមចិរវេលា ៥ឆ្នាំ និងអាជ្ញាយុកាលនៃបទលហុមានចិរវេលា ១ឆ្នាំហើយការកំណត់ អាជ្ញាយុកាលនៃបទល្មើសនេះ ពុំមានអនុភាពឡើយចំពោះបទឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ បទឧក្រិដ្ឋសង្គ្រាម និងបទឧក្រិដ្ឋប្រឆាំងមនុស្សជាតិ។

**គ.ការលើកលែងទោសទូទៅ**

ការលើកលែងទោសជាទូទៅ គឺជាវិធានការនីតិកម្មដែលមានគោលដៅលុបចោលនូវចរិត លក្ខណៈជាបទល្មើសនៃអំពើមួយចំនួន។ ស្របជាមួយគ្នានេះដែរគួរកត់សម្គាល់ថា ការលើកលែងទោសជាទូទៅស្ថិតនៅក្នុង

[២៨] ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៨០៧/០២៤, ១០ សីហា ២០០៧, មាត្រា ១០

អំណាចរបស់អង្គការនីតិប្បញ្ញត្តិ ដោយផ្អែកតាមមាត្រា ៩០ថ្មី នៃរដ្ឋធម្មនុញ្ញ ឆ្នាំ១៩៩៣។ ដោយឡែក ក្រមព្រហ្មទណ្ឌ បានបញ្ញត្តពីករណីនៃការលើកលែងទោសជាទូទៅចាប់ ពីមាត្រា ១៤៩ រហូតដល់មាត្រា ១៥១។

ការលើកលែងទោសជាទូទៅត្រូវមានអនុភាពដោយច្បាប់ស្តីពីការលើកលែងទោសជាទូទៅអាចត្រូវបានអនុម័តដោយសារតែមានមូលហេតុចាំបាច់ច្រើនយ៉ាងដូចជាដើម្បីកុំឱ្យមានចំនួនទណ្ឌិតក្នុងពន្ធនាគារច្រើនខ្លាំងពេកឬក៏ក្នុងឱកាសដែលមានហេតុការណ៍ដ៏សំខាន់ណាមួយនៅក្នុងប្រទេស។ល។ លើសពីនេះទៅទៀតច្បាប់ស្តីពីការលើកលែងទោសជាទូទៅអាចមានកម្មវត្ថុពាក់ព័ន្ធទាំងទោសព្រហ្មទណ្ឌអានុភាពលុបបំបាត់ចោលទាំងស្រុងនូវទណ្ឌកម្មដែលពាក់ព័ន្ធទាំងអស់ដូចនេះការលើកលែងទោសជាទូទៅមានអានុភាព ចំពោះអំពើល្មើសដែលទទួលបាននូវការលើកលែងទោសហើយនៅមិនទាន់ត្រូវបានវិនិច្ឆ័យដោយតុលាការនៅឡើយបណ្តឹងអាជ្ញាត្រូវតែរលត់ហើយតុលាការមិនអាចសម្រេចផ្តន្ទាទោសលើចារីបានឡើយ។ ហើយប្រសិនបើមានការផ្តន្ទាទោសជាស្ថាពរហើយក៏ការផ្តន្ទាទោសទាំងអស់ត្រូវទុកជាឥតបានការដោយមិនអាចយកមកអនុវត្តបានឡើយ។ មួយវិញទៀតបើទណ្ឌិតកំពុងតែរងទោសដាក់ក្នុងពន្ធនាគារទណ្ឌិតនឹងត្រូវទទួលបានការដោះលែងឱ្យមានសេរីភាពឡើងវិញភ្លាម។

ហេតុដូច្នេះចំពោះការលើកលែងទោសដែលនាំឱ្យមានការរលត់បណ្តឹងអាជ្ញាសំដៅទៅលើការលើកលែងទោសដោយការធ្វើច្បាប់ដែលអនុម័តដោយរដ្ឋសភាសម្រាប់លើកលែងទោស ឬលុបចោលនូវប្រភេទបទល្មើសណាមួយដែលនាំឱ្យបណ្តឹងអាជ្ញាដែលកំពុងដំណើរការក្នុងនីតិវិធីត្រូវរលត់ ។

**ឃ.និរាករណ៍នៃច្បាប់ព្រហ្មទណ្ឌ**

និរាករណ៍ គឺជាការលុបចោលនូវវិធានច្បាប់ រឺបទបញ្ញាលែងអោយមានអនុភាពអនុវត្តបន្តទៅទៀត។ ចំពោះនិរាករណ៍ច្បាប់ព្រហ្មទណ្ឌ គឺជាការលុបចោលនូវវិធានច្បាប់ព្រហ្មទណ្ឌលែងអោយមាន អនុភាពអនុវត្តតទៅទៀត។

ផ្អែកតាមគោលការណ៍នីត្យានុកូលនៃច្បាប់ព្រហ្មទណ្ឌ ច្បាប់គឺជាកត្តាចាំបាច់ក្នុងរឿងព្រហ្មទណ្ឌ ព្រោះមានតែច្បាប់ទេ ដែលចែងអំពីបទល្មើស និងដាក់ទោសទណ្ឌទៅលើអំពើដែលជាបទល្មើសនោះ។

អាស្រ័យហេតុនេះ ក្រោយពេលដែលក្រមព្រហ្មទណ្ឌត្រូវបាននិរាករណ៍នោះនឹងពុំមានគោលការណ៍ណាមួយដែលចែងអំពើបទល្មើសទៀតឡើយ ដែលធ្វើឱ្យបានបាត់បង់ នីត្យានុកូលភាពនៃបទល្មើសនាំឱ្យអំពើដែលជាបទល្មើសលែងត្រូវបានកំណត់ថាជា បទល្មើសទៀតហើយ មានន័យថាប្រសិនបើច្បាប់ដែលចែងពីបទល្មើសនោះត្រូវបាននិរាករណ៍ ពោលគឺអំពើដែលបានប្រព្រឹត្តដោយជនល្មើសនោះលែងត្រូវបានកំណត់ថាជាបទល្មើសនៅក្នុងក្រមព្រហ្មទណ្ឌតទៅទៀតហើយជាហេតុធ្វើឱ្យបណ្តឹង អាជ្ញាត្រូវរលត់ដោយសារមូលហេតុនេះផងដែរ។

**ខ.អាជ្ញាអស់ជំនុំ**

អាជ្ញាអស់ជំនុំ ជាគោលការណ៍មួយសំខាន់ដែលមានចែងក្នុងក្រមនីតិព្រហ្មទណ្ឌ។ ដោយអនុវត្ត គោលការណ៍នៃអាជ្ញាអស់ជំនុំ ជនណាដែលត្រូវតុលាការសម្រេចឱ្យរួចខ្លួនជាស្ថាពររួចហើយ ជននោះមិន អាចត្រូវចោទប្រកាន់ទៀតទេចំពោះអំពើដដែល ទោះបីជាក្រោមការកំណត់ឈ្មោះបទល្មើសថ្មីផ្សេងក៏ដោយ។[២៩]

អាស្រ័យហេតុនេះ ប្រសិនបើជនជាប់ចោទត្រូវបានតុលាការសម្រេច ឱ្យរួចខ្លួនជាស្ថាពរតាមរយៈ សាលក្រម ឬសាលដីកាណាមួយហើយ ជនជាប់ចោទនោះមិនអាចត្រូវបានចោទប្រកាន់ទៀតទេចំពោះអំពើ ដដែល ទោះបីជាមានការចោទប្រកាន់នោះ ក្រោមការកំណត់ឈ្មោះបទល្មើសថ្មីផ្សេងទៀតក៏ដោយ។

ផ្អែកតាមគោលការណ៍ខាងលើចំពោះរឿងបត្យាប័នវិញ នីតិវិធីបត្យាប័នមិនអាចចាប់ផ្ដើមបានឡើយ បើយល់ឃើញថាការបញ្ជូនជននោះទៅត្រូវបានតុលាការនៃប្រទេសស្នើសុំផ្ដន្ទាទោសប្រហារជីវិត ឬប្រសិនបើ យល់ឃើញថាការបញ្ជូនជននោះទៅត្រូវបានជំនុំជម្រះដោយតុលាការពិសេសនៃប្រទេសដាក់សំណើ។

[២៩] ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៨០៧/០២៤, ១០ សីហា ២០០៧, មាត្រា ១២

## ២.នីតិវិធីបត្យាប័នក្នុងករណីដែលព្រះរាជាណាចក្រកម្ពុជាជារដ្ឋទទួលសំណើ

ក្នុងនីតិវិធីបត្យាប័ន ក្រោយលក្ខខណ្ឌទាំងអស់នៃបត្យាប័នត្រូវបានបំពេញ រដ្ឋបរទេសដែលដាក់សំណើត្រូវចាប់ផ្តើមដំណើរការធ្វើបត្យាប័ន។

ក្នុងករណីដែលព្រះរាជាណាចក្រកម្ពុជាជារដ្ឋទទួលសំណើនីតិវិធីបត្យាប័ន ចាប់ផ្តើមឡើងដោយសារតែមានពាក្យសុំធ្វើបត្យាប័ន និងបញ្ជូនទៅវិញដោយមានការប្រគល់បុគ្គលដែលគេទាមទារ ទៅរដ្ឋធ្វើសំណើដើម្បីធ្វើការចោទប្រកាន់ ឬជំនុំជម្រះ ឬអនុវត្តទោស។

ក្រមនីតិវិធីព្រហ្មទណ្ឌបានកំណត់អំពីនីតិវិធីបត្យាប័នក្នុងករណីដែលព្រះរាជាណាចក្រកម្ពុជា ជារដ្ឋទទួលសំណើមានដូចជា នីតិវិធីពាក់ព័ន្ធនឹងពាក្យសុំ នីតិវិធីចាប់ខ្លួន និងការឃុំខ្លួនចំពោះបុគ្គលដែលគេទាមទារ និងនីតិវិធីនៅដំណាក់កាលសភាស៊ើបសួរ។

### ២.១.នីតិវិធីពាក់ព័ន្ធនឹងពាក្យសុំ

ចំពោះនីតិវិធីពាក់ព័ន្ធនឹងពាក់សុំធ្វើបត្យាប័នរបស់រដ្ឋបរទេសដែលធ្វើសំណើមានដូចជា ការបញ្ជាក់ថាត្រឹមត្រូវចំពោះពាក្យសុំធ្វើបត្យាប័ន បន្ទាប់មកត្រូវធ្វើការបញ្ជូនបត្យាប័ន។ ចំពោះនីតិវិធីក្នុងការ បញ្ជាក់ថាត្រឹមត្រូវ ចំពោះពាក្យសុំធ្វើបត្យាប័ន និងការបញ្ជូនបត្យាប័នត្រូវបានកំណត់ក្នុង មាត្រា ៥៧៩ និង ៥៨០ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។ ក្រមនីតិវិធីព្រហ្មទណ្ឌបានកំណត់អំពីការបញ្ជាក់ថាត្រឹមត្រូវចំពោះពាក្យសុំធ្វើបត្យាប័នដោយបានបញ្ញត្តថាគ្រប់ពាក្យសុំធ្វើបត្យាប័នត្រូវតែជូនរដ្ឋាភិបាលកម្ពុជាតាមផ្លូវទូត ពាក្យសុំនេះត្រូវមានលិខិតបញ្ជាក់ភស្តុតាងអមជាមួយផង ។

លិខិតបញ្ជាក់ភស្តុតាងត្រូវមាន :

- ឯកសារដែលមានលក្ខណៈគ្រប់គ្រាន់ក្នុងការកំណត់អត្តសញ្ញាណបុគ្គលដែលគេទាមទារ
- របាយការណ៍អំពីអង្គហេតុដែលត្រូវចោទប្រកាន់លើបុគ្គលដែលគេទាមទារ
- អត្ថបទច្បាប់ដែលអនុវត្តទៅលើអំពើនោះ និងទោសដែលត្រូវទទួលរង
- លិខិតចម្លងនៃសេចក្តីសម្រេចផ្តន្ទាទោសប្រសិនបើមាន ។

ឯកសារទាំងអស់ត្រូវចុះហត្ថលេខាបោះត្រាជាផ្លូវការ និងបិទស្រោម ហើយប្រសិនបើមិនមែនជាភាសាខ្មែរបារាំង ឬអង់គ្លេសត្រូវតែភ្ជាប់មកជាមួយនូវឯកសារបកប្រែជាភាសាមួយ នៃភាសាទាំងបីនេះដោយមានសេចក្តីបញ្ជាក់ផង។ [៣០]

[៣០] ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៨០៧/០២៤, ១០ សីហា ២០០៧, មាត្រា ៥៧៩

ចំពោះនីតិវិធីនៅពេលមានលក្ខខណ្ឌគ្រប់គ្រាន់អស់ហើយ រដ្ឋដែលស្នើសុំត្រូវដាក់ពាក្យសុំ ធ្វើបត្យាប័ននេះមកព្រះរាជាណាចក្រកម្ពុជាតាមផ្លូវទូត គឺមានន័យថាត្រូវដាក់មកតាមរយៈក្រសួងការបរទេសនៃព្រះរាជាណាចក្រកម្ពុជានៅក្នុងពាក្យសុំនេះត្រូវមានលិខិតបញ្ជាក់អំពីភស្តុតាងលិខិតបញ្ជាក់ភស្តុតាងដែលមានឯកសារបួនសំខាន់នៅក្នុង មាត្រា ៥៧៩ គឺបានបញ្ជាក់ថាឯកសារទីមួយគឺឯកសារដែលមានលក្ខណៈគ្រប់គ្រាន់ក្នុងការកំណត់អត្តសញ្ញាណបុគ្គលដែលគេទាមទារ ទីពីរគឺបាយការណ៍អំពីអង្គហេតុដែលត្រូវចោទ ប្រកាន់ទៅលើបុគ្គលដែលគេទាមទារ ទីបីគឺអត្ថបទច្បាប់ដែលអនុវត្តទៅលើអំពើនោះ និងទោសដែលត្រូវទទួលរង និងទីបួនលិខិតចម្លងនៃសេចក្តីសម្រេចផ្តន្ទាទោសប្រសិនបើមាន។ ឯកសារទីបួន ជាឯកសារក្នុង ករណីដែលមានការផ្តន្ទាទោសរួចហើយទេ ប៉ុន្តែករណីខ្លះមិនទាន់ផ្តន្ទាទោសទេទើបតែដំណើរការនីតិវិធីនៃការចោទប្រកាន់ដូច្នេះឯកសារទីបួនពេលខ្លះ គឺមិនចាំបាច់មានទេដោយសារតែមិនទាន់សម្រេចសេចក្តីផ្តន្ទាទោស។ ពេលដែលមានឯកសារទាំងអស់ឯកសារត្រូវមានចុះហត្ថលេខាបោះត្រាជាផ្លូវការហើយមានបិទស្រោម ហើយភាសាដែលត្រូវប្រើប្រាស់នៅក្នុងការធ្វើបត្យាប័ននេះ គឺត្រូវប្រើប្រាស់នូវភាសាខ្មែរ ឬប្រើប្រាស់នូវ ភាសាបារាំង ឬភាសាអង់គ្លេសក្នុងករណីមិនឯកសារទាំងអស់ មិនមានភាសាណាមួយនៅក្នុង ចំណោមភាសាទាំងបី ដែលត្រូវមានការបកប្រែហើយមានការបញ្ជាក់អមមកជាមួយផង។

នៅពេលដែលបញ្ជូនមកដល់ក្រសួងការបរទេស ឯកឧត្តមរដ្ឋមន្ត្រីក្រសួងការបរទេសត្រូវតែបញ្ជូនពាក្យសុំនេះមករដ្ឋមន្ត្រីក្រសួងយុត្តិធម៌ រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ពិនិត្យផ្ទៀងផ្ទាត់មើលនិយតនៃការស្នើសុំធ្វើបត្យាប័ននេះហើយគាត់បញ្ជូន ពាក្យសុំនេះទៅឯកឧត្តមអគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ភ្នំពេញ។[៣១]

## ២.២.នីតិវិធីចាប់ខ្លួន និងការឃុំខ្លួនចំពោះបុគ្គលដែលគេទាមទារ

ក្នុងករណីពេលខ្លះ រដ្ឋស្នើសុំអាចសុំចាប់បុគ្គលដែលទាមទារមុនតែម្តង ទោះបីជាពាក្យបណ្តឹងសុំធ្វើបត្យាប័នមិនទាន់បញ្ជូនមកក៏ដោយដើម្បីរារាំងកុំឱ្យបុគ្គលដែលគេទាមទារនោះលួចរត់បាត់ ឬក៏រត់គេចទៅណាបាន។

ក្នុងករណីបន្ទាន់ពាក្យសុំឱ្យចាប់ខ្លួនបណ្តោះអាសន្ន អាចធ្វើមុនពាក្យសុំឱ្យធ្វើបត្យាប័នដែលមានចែងនៅក្នុងមាត្រា ៥៧៩ (ការបញ្ជាក់ថាត្រឹមត្រូវចំពោះពាក្យសុំធ្វើបត្យាប័ន) នៃក្រមនេះ។ ពាក្យសុំឱ្យចាប់ខ្លួនបណ្តោះអាសន្ន ដែលមានគោលដៅរារាំងការគេចខ្លួនបុគ្គលដែលគេទាមទារមិនតម្រូវឱ្យគោរពទម្រង់បែបបទដោយឡែកឡើយ។

[៣១] ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៨០៧/០២៤, ១០ សីហា ២០០៧, មាត្រា ៥៨០

បុគ្គលដែលត្រូវស្ថិតនៅក្រោមនីតិវិធីនៃការចាប់ខ្លួនបណ្តោះអាសន្ន ត្រូវតែបានដោះលែងឱ្យមានសេរីភាពឡើងវិញដោយឯកឯង ប្រសិនបើរាជរដ្ឋាភិបាលពុំបានទទួលឯកសារទាំងឡាយដូចដែលមានចែងនៅក្នុងមាត្រា ៥៧៩ (ការបញ្ជាក់ថាត្រឹមត្រូវចំពោះពាក្យសុំធ្វើបត្យាប័ន) នៃក្រមនេះក្នុងរយៈពេល ២ (ពីរ) ខែ គិតពីថ្ងៃចាប់ខ្លួនទេនោះ ។[៣២]

ចំពោះនីតិវិធីនៅក្នុងការប្តឹងសុំចាប់ខ្លួននេះ ព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ជាអ្នកមានសិទ្ធិនៅក្នុងការចេញបញ្ជាឱ្យចាប់ហើយឃុំតែម្តង។

ផ្អែកតាមបញ្ញត្តិនៃក្រមនីតិវិធីព្រហ្មទណ្ឌបានកំណត់ថា អគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍នៅភ្នំពេញអាចចេញបញ្ជាឱ្យចាប់ និងឃុំខ្លួនបុគ្គលដែលគេទាមទារ

បញ្ជានេះមានចុះនិទ្ទេសដូចតទៅ :

- អត្តសញ្ញាណនៃបុគ្គលដែលគេតាមទារ
- ការយោងនៃពាក្យសុំឱ្យចាប់ខ្លួនជាបណ្តោះអាសន្នរបស់រដ្ឋបរទេស
- ឈ្មោះ និងឋានៈរបស់ចៅក្រមដែលចេញបញ្ជានេះ ។

បញ្ជានេះត្រូវមានចុះកាលបរិច្ឆេទ និងចុះហត្ថលេខាដោយអគ្គព្រះរាជអាជ្ញា និងមានបោះត្រាផង ។

បញ្ជាឱ្យចាប់ និងឃុំខ្លួនមានអានុភាពអនុវត្តនៅលើដែនដីកម្ពុជាទាំងមូល ។[៣៣]

ផ្អែកតាមបញ្ញត្តិខាងលើ ដើម្បីឱ្យព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ជាអាចចេញបញ្ជាឱ្យចាប់ខ្លួនបានត្រូវបំពេញនូវចំណុចបីគឺ ទីមួយ ត្រូវមានអត្តសញ្ញាណរបស់ជនដែលគេទាមទារឱ្យចាប់ ទីពីរត្រូវមានពាក្យសុំពីរដ្ឋដែលស្នើសុំឱ្យសំណើររបស់រដ្ឋស្នើសុំឱ្យចាប់ និងទីបីត្រូវចុះហត្ថលេខាទៅលើលិខិត និងមានបោះត្រាច្បាស់លាស់។ ក្នុងកំឡុងពេលពីរខែប្រសិនបើរដ្ឋដែលស្នើសុំមិនបានបំពេញឯកសារដូចដែលមានចែងនៅក្នុងមាត្រា ៥៧៩ទេបុគ្គលដែលគេទាមទារដែលត្រូវបានចាប់ខ្លួនហើយត្រូវដោះលែងឱ្យមានសេរីភាពវិញ។

## ២.៣.នីតិវិធីនៅដំណាក់កាលសភាស៊ើបសួរ

ក្រោយពីសំណើធ្វើបត្យាប័ន ត្រូវបានពិនិត្យផ្ទៀងផ្ទាត់មើលនិយតនៃការស្នើសុំធ្វើបត្យាប័ននោះដោយរដ្ឋមន្ត្រីក្រសួងយុត្តិធម៌រួចហើយ រដ្ឋមន្ត្រីក្រសួងយុត្តិធម៌បញ្ជូនពាក្យសុំនេះទៅអគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ដើម្បីប្រគល់សមត្ថកិច្ចបន្តជូនសភាស៊ើបសួរ។ សភាស៊ើបសួរមានសមត្ថកិច្ចជាអ្នកផ្តល់យោបល់លើបត្យាប័ន។

---

[៣២] ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៨០៧/០២៤, ១០ សីហា ២០០៧, មាត្រា ៥៨១

[៣៣] ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៨០៧/០២៤, ១០ សីហា ២០០៧, មាត្រា ៥៨២

ដោយផ្អែកតាមបញ្ញត្តិដែលមានចែងក្នុង ក្រមនីតិវិធីព្រហ្មទណ្ឌ សភាស៊ើបសួរផ្តល់យោបល់មិនយល់ព្រម ប្រសិនបើយល់ឃើញថាលក្ខខណ្ឌច្បាប់នៃបត្យាប័នមិនត្រូវបានបំពេញទេ។

ផ្អែកតាមបញ្ញត្តិខាងលើ សភាស៊ើបសួរមានតួនាទីយ៉ាងសំខាន់ក្នុងការផ្តល់យោបល់លើបត្យាប័នពោល គឺមុននឹងសម្រេចបង្គាប់ឱ្យធ្វើបត្យាប័នរាជរដ្ឋាភិបាលកម្ពុជាចាំបាច់ត្រូវតែទទួលយោបល់ ពីសាលាជម្រះក្តីជាមុនសិន ។

សភាស៊ើបសួរត្រូវធ្វើការពិភាក្សាដេញដោលនៅក្នុងបន្ទប់សម្ងាត់ដោយស្តាប់ចម្លើយរបស់បុគ្គលដែលគេទាមទារ សេចក្តីសន្និដ្ឋានសុំរបស់អគ្គព្រះរាជអាជ្ញា និងសេចក្តីសន្និដ្ឋានការពាររបស់មេធាវីការពារ ។ បន្ទាប់មកសភាស៊ើបសួរផ្តល់យោបល់លើបញ្ហាបត្យាប័នដោយចេញជាសាលដីកាដែលមានសំអាងហេតុស្តីពីពាក្យសុំធ្វើបត្យាប័ននេះ ។[៣៤] ការផ្តល់យោបល់នេះអាចជាការផ្តល់យោបល់យល់ព្រម ឬមិនយល់ព្រមឱ្យធ្វើបត្យាប័ន។ ប៉ុន្តែសាលដីការបស់សភាស៊ើបសួរដែលផ្តល់យោបល់លើបញ្ហាបត្យាប័ននៅតែអាចត្រូវប្តឹងសាទុក្ខទៅតុលាការកំពូលក្នុងរយៈពេល ៥ថ្ងៃ។ កាលណាសាលដីកាផ្តល់យោបល់បានចូលជាស្ថាពរហើយសាលដីកានេះត្រូវតែជូនដំណឹងភ្លាមដល់ រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ ។ យោបល់របស់សាលាជម្រះក្តីលើបញ្ហានេះ មានអានុភាពចងជាកាតព្វកិច្ចដល់រាជរដ្ឋាភិបាលបានសេចក្តីថាប្រសិនបើជាយោបល់មិនយល់ព្រមឱ្យធ្វើបត្យាប័ននោះរាជរដ្ឋាភិបាលមិនអាចបង្គាប់ឱ្យធ្វើបត្យាប័នទេហើយ បុគ្គលដែលគេទាមទារនឹងត្រូវដោះលែងឱ្យមានសេរីភាពឡើងវិញភ្លាម ។

ក៏ប៉ុន្តែផ្ទុយទៅវិញបើសិនបើជា យោបល់យល់ព្រមឱ្យធ្វើបត្យាប័នវិញ រដ្ឋមន្ត្រីក្រសួងយុត្តិធម៌បញ្ជូនរឿងនេះទៅរាជរដ្ឋាភិបាល ដើម្បីចេញអនុក្រឹត្យបង្គាប់ឱ្យធ្វើបត្យាប័នចំពោះបុគ្គលដែលគេទាមទារ។

## ២.៤.នីតិវិធីក្រោយផ្តល់បត្យាប័ន

ប្រសិនបើសភាស៊ើបសួរបញ្ចេញយោបល់យល់ព្រម រដ្ឋមន្ត្រីក្រសួងយុត្តិធម៌អាចបញ្ជូនរឿង នេះទៅរាជរដ្ឋាភិបាល ដើម្បីចេញអនុក្រឹត្យបង្គាប់ឱ្យធ្វើបត្យាប័នចំពោះបុគ្គលដែលគេទាមទារនោះ ។ កាលណាបត្យាប័នត្រូវបានបង្គាប់ បុគ្គលដែលគេទាមទារត្រូវបានប្រគល់ឱ្យដល់រដ្ឋធ្វើសំណើ ។ សោហ៊ុយក្នុងការធ្វើបត្យាប័នជាបន្ទុករបស់រដ្ឋធ្វើសំណើ ។ នៅពេលដែលបុគ្គល ដែលគេទាមទារនោះចាកចេញផុតពីដែនដីកម្ពុជា ក្បួនការពារត្រូវទទួលខុសត្រូវដោយរដ្ឋធ្វើសំណើ ។ ប្រសិនបើរដ្ឋធ្វើសំណើ មិនបានចាប់ផ្តើមនីតិវិធីធ្វើមាតុភូមិនិវត្តន៍នៅក្នុងរយៈពេល ៣០(សាមសិប) ថ្ងៃ បន្ទាប់ពីការជូនដំណឹងអំពីអនុក្រឹត្យបង្គាប់ឱ្យធ្វើបត្យាប័នទេ បុគ្គលដែលគេទាមទារត្រូវបានដោះលែងឱ្យមានសេរីភាពវិញ ។[៣៥]

---

[៣៤] ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៨០៧/០២៤, ១០ សីហា ២០០៧, មាត្រា ៥៨៥

[៣៥] ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៨០៧/០២៤, ១០ សីហា ២០០៧, មាត្រា ៥៨៩

## ៣.នីតិវិធីបត្យាប័នក្នុងករណីដែលព្រះរាជាណាចក្រកម្ពុជាជារដ្ឋដាក់សំណើ

ក្រៅពីនីតិវិធីនៃការធ្វើបត្យាប័នដែលព្រះរាជាណាចក្រកម្ពុជាជារដ្ឋទទួលសំណើព្រះរាជាណាចក្រកម្ពុជាក៏អាចធ្វើបត្យាប័នចំពោះរដ្ឋបរទេសទៅលើប្រជាពលរដ្ឋខ្មែរ ឬជនបរទេសដែលបានប្រព្រឹត្តបទល្មើសលើដែនដីនៃព្រះរាជាណាចក្រកម្ពុជា ក្រោយមកជនល្មើសបានរត់ទៅប្រទេសដទៃ។

ទោះបីជាក្រមនីតិវិធីព្រហ្មទណ្ឌមិនបានចែងយ៉ាងជាក់លាក់អំពីការចាប់ផ្តើម នីតិវិធីបត្យាប័ននៅប្រទេសកម្ពុជាក៏ដោយ ប៉ុន្តែយើងអាចសន្និដ្ឋានបានថានីតិវិធីនេះប្រាកដជាចាប់ផ្តើមដោយពាក្យសុំធ្វើបត្យាប័ន និងការបញ្ជូនពាក្យសុំតាមផ្លូវទូត ដូចក្នុងករណីដែលប្រទេសកម្ពុជាដើរតួនាទីជារដ្ឋទទួលសំណើដែរ។[៣៦]

ចំពោះការពិនិត្យ និងការសម្រេចលើពាក្យសុំធ្វើបត្យាប័នដែលស្នើដោយប្រទេសកម្ពុជា គឺអាស្រ័យទៅលើសន្ធិសញ្ញាអន្តរជាតិ និងច្បាប់ជាតិរបស់រដ្ឋដែលបានទទួលសំណើពីប្រទេសកម្ពុជា។ នៅពេលដែលរដ្ឋទទួលសំណើបានយល់ព្រមធ្វើបត្យាប័នបុគ្គលដែលប្រទេសកម្ពុជាទាមទារឱ្យធ្វើបត្យាប័នបុគ្គលនេះនឹងត្រូវបញ្ជូនឱ្យមកកាន់ប្រទេសកម្ពុជាវិញ ។

### ៣.១.សំណើបត្យាប័ន

ចំពោះពាក្យសុំធ្វើបត្យាប័នក្នុងករណីដែលកម្ពុជាជារដ្ឋដាក់សំណើត្រូវបានកំណត់ដោយកិច្ចព្រមព្រៀងស្តីពីបត្យាប័ន រវាងកម្ពុជា-កូរ៉េ ព្រមទាំងសន្ធិសញ្ញា និងអនុសញ្ញាស្តីពីបត្យាប័នរបស់កម្ពុជា។

កិច្ចព្រមព្រៀងស្តីពីបត្យាប័ន រវាងកម្ពុជា-កូរ៉េ បានកំណត់ថា៖

១. សំណើបត្យាប័នត្រូវធ្វើជាលាយលក្ខណ៍អក្សរ ហើយត្រូវភ្ជាប់មកជាមួយនូវ៖

ក. ឯកសារ សេចក្តីបញ្ជាក់ ឬព័ត៌មានផ្សេងទៀត ដែលពិពណ៌នាអំពីអត្តសញ្ញាណប្រសិនបើមាន រួមបញ្ចូលទាំងការពិពណ៌នាអំពីប្រវត្តិសង្ខេប រូបថត និង/ឬស្នាមមេដៃ សញ្ញាតិ និងទីកន្លែងស្នាក់នៅប្រហាក់ប្រហែលរបស់ជនដែលត្រូវស្នើសុំ។

ខ. សេចក្តីបញ្ជាក់លើអង្គហេតុនៃសំណុំរឿង រួមបញ្ចូលទាំងពេលវេលា និងទីកន្លែងប្រព្រឹត្តបទល្មើស និងប្រវត្តិនីតិវិធីនៃសំណុំរឿង។

គ.សេចក្តីបញ្ជាក់អំពីច្បាប់ដែលពិពណ៌នាអំពីធាតុផ្សំសំខាន់ៗ និងការកំណត់នៃបទល្មើស។

ឃ. សេចក្តីបញ្ជាក់អំពីច្បាប់ដែលពិពណ៌នាអំពីការដាក់ទណ្ឌកម្មចំពោះបទល្មើស។

ង.សេចក្តីបញ្ជាក់អំពីច្បាប់ដែលទាក់ទងនឹងការកំណត់ពេលនៃការចោទប្រកាន់ ឬការអនុវត្តទណ្ឌកម្មចំពោះបទល្មើស។

---

[៣៦] លោក រុន ពណ្ណារិទ្ធ,សៀវភៅ ស្តីពី នីតិព្រហ្មទណ្ឌទូទៅ បោះពុម្ព ឆ្នាំ២០១១, ទំព័រ ១៥៧

ច. ឯកសារ សេចក្ដីបញ្ជាក់ ឬព័ត៌មានផ្សេងទៀតដែលបញ្ជាក់នៅក្នុងកថាខណ្ឌ២ ឬ៣នៃមាត្រានេះ ប្រសិនបើមាន។

២. សំណើបត្យាប័នទាក់ទងនឹងជនដែលត្រូវស្នើសុំ ដើម្បីចោទប្រកាន់ ត្រូវភ្ជាប់ជាមួយផងដែរនូវៈ

ក. សេចក្ដីចម្លងនៃដីកាចាប់ខ្លួនឬដីកាឃុំខ្លួន ចេញដោយចៅក្រមឬអាជ្ញាធរមានសមត្ថកិច្ចតុលាការដទៃទៀត របស់ភាគីដាក់សំណើ។

ខ.ព័ត៌មានដែលបញ្ជាក់ថាបុគ្គលដែលស្នើសុំបត្យាប័ន គឺជាបុគ្គលដែលមានដីកាចាប់ខ្លួន ឬដីកាឃុំខ្លួន។

គ. សេចក្ដីបញ្ជាក់នៃអំពើឬការខកខានដែលបានចោទប្រកាន់បង្កើតបានជាបទល្មើស និងភស្តុតាងគាំទ្រដែលអាចផ្តល់នូវមូលដ្ឋានត្រឹមត្រូវ គួរឱ្យសង្ស័យថា បុគ្គលដែលត្រូវធ្វើបត្យាប័នបានប្រព្រឹត្តបទល្មើសដែលបត្យាប័នត្រូវបានស្នើឡើង។

៣. កាលណាសំណើបត្យាប័នទាក់ទងនឹងជនដែលត្រូវបានរកឃើញនូវពិរុទ្ធ សំណើនេះក៏ត្រូវភ្ជាប់មកជាមួយផងដែរនូវៈ

ក.សេចក្ដីចម្លងសាលក្រម/សាលដីកាចេញដោយតុលាការនៃភាគីដាក់សំណើដែលកំណត់អំពីការកាត់ទោសនិងទោសដល់បានដាក់អង្គហេតុដែលទោសអាចអនុវត្តបាននិងបរិបទដែលទោសនៅមិនទាន់ទទួល។

ខ.សេចក្ដីចម្លងនៃដីកាចាប់ខ្លួន ឬសេចក្ដីបញ្ជាក់ថា បុគ្គលជាកម្មវត្ថុនៃការឃុំខ្លួន ផ្អែកលើមូលដ្ឋាននៃសាលក្រម/សាលដីកាកាត់ទោស។

គ. ព័ត៌មានដែលបញ្ជាក់ថា បុគ្គលដែលស្នើបត្យាប័ន គឺជាបុគ្គលដែលមានពិរុទ្ធ។

ឃ. សេចក្ដីបញ្ជាក់នៃអំពើ ឬការខកខានដែលអាចបង្កើតបានជាបទល្មើសដែលបុគ្គលនោះត្រូវបានរកឃើញថាមានពិរុទ្ធ។

ង. សេចក្ដីបញ្ជាក់ទាក់ទងនឹងមធ្យោបាយតាមផ្លូវច្បាប់ ដែលកើតមានចំពោះបុគ្គលដើម្បីរៀបចំការការពារខ្លួនរបស់គេ ឬក៏ចាត់ឱ្យមានការកាត់ក្តីសាឡើងវិញ ដោយមានវត្តមានបុគ្គលនោះប្រសិនបើបុគ្គលត្រូវផ្តន្ទាទោសចំពោះបទល្មើសណាមួយ ពុំមានវត្តមាន។

៤. រាល់ឯកសារទាំងឡាយដែលភាគីដាក់សំណើបញ្ជូនមក អនុលោមតាមបទប្បញ្ញត្តិនៃ កិច្ចព្រមព្រៀងនេះត្រូវចុះហត្ថលេខា ឬបោះត្រាជាផ្លូវការនិងភ្ជាប់មកជាមួយនូវអត្ថបទបកប្រែជាភាសានៃភាគីទទួលសំណើ ឬជាភាសាអង់គ្លេស។[៣៧]

---

[៣៧] កិច្ចព្រមព្រៀងស្តីពីបត្យាប័ន រវាងព្រះរាជាណាចក្រកម្ពុជា និងសាធារណរដ្ឋកូរ៉េ, នស/រកម/០១១១/០០១, ០៦ មករា ២០១១, មាត្រា៧

ចំណែកឯការបញ្ជូនសំណើបត្យាប័នវិញ ត្រូវអនុលោមតាម មាត្រា ៦ នៃកិច្ចព្រមព្រៀងបត្យាប័នដោយបានបញ្ញត្តថា ក្នុងស្មារតីនៃកិច្ចព្រមព្រៀងនេះ គូភាគីត្រូវប្រាស្រ័យទាក់ទងគ្នា តាមរយៈផ្លូវទូត វៀរលែងតែមានបញ្ញត្តិផ្សេងចែងក្នុងកិច្ចព្រមព្រៀងនេះ។ យោងតាមបញ្ញត្តិខាងលើក្នុងកិច្ចព្រមព្រៀងនេះ ការបញ្ជូនសំណើបត្យាប័ន គឺត្រូវធ្វើតាមរយៈផ្លូវទូត ដូចករណីដែលប្រទេសកម្ពុជាដើរតួនាទីជារដ្ឋទទួលសំណើដែរ។

ក្រោយសំណើបត្យាប័នត្រូវបានបញ្ជូនទៅរដ្ឋទទួលសំណើបត្យាប័ននោះត្រូវទទួលការសម្រេចលើការស្នើដោយរដ្ឋទទួលសំណើ។ ផ្អែកតាមកិច្ចព្រមព្រៀងបត្យាប័ន ភាគីទទួលសំណើ ត្រូវពិនិត្យសំណើសុំបត្យាប័នស្របតាមនីតិវិធីដែលច្បាប់របស់ខ្លួនកំណត់ឱ្យ និងត្រូវផ្តល់សេចក្តីសម្រេចរបស់ ខ្លួនទៅភាគីដាក់សំណើ។[៣៨]

ចំពោះការពិនិត្យ និងការសម្រេចលើពាក្យសុំបត្យាប័នដែលស្នើដោយរដ្ឋកម្ពុជា គឺអាស្រ័យទៅលើសន្ធិសញ្ញាអន្តរជាតិ និងច្បាប់ជាតិរបស់រដ្ឋដែលបានទទួលសំណើពីប្រទេសកម្ពុជា។

### ៣.២.សំណើសុំឱ្យចាប់ខ្លួនបណ្តោះអាសន្ន

ដូចគ្នាជាមួយនីតិវិធីបត្យាប័នក្នុងករណីដែលរដ្ឋកម្ពុជាជារដ្ឋទទួលសំណើដែរក្នុងករណីខ្លះព្រះរាជាណាចក្រកម្ពុជាអាចសុំចាប់បុគ្គលដែលទាមទារមុនតែម្តងទោះបីជាពាក្យបណ្តឹងសុំធ្វើបត្យាប័នមិនទាន់បញ្ជូនទៅរដ្ឋទទួលសំណើក៏ដោយដើម្បីរារាំងកុំឱ្យបុគ្គលដែលគេទាមទារនោះលួចរត់បាត់ ឬក៏រត់គេចទៅណាបាន។

ផ្អែកតាមកិច្ចព្រមព្រៀងបត្យាប័នដែលបានកំណត់អំពីការចាប់ខ្លួនបណ្តោះអាសន្នដោយបញ្ញត្តថាៈ

១. ក្នុងករណីបន្ទាន់ ភាគីមួយអាចស្នើទៅភាគីម្ខាងទៀត ឱ្យធ្វើការចាប់ខ្លួនបណ្តោះអាសន្ននូវបុគ្គលដែលត្រូវស្នើសុំ។ សំណើនេះអាចដាក់ជូនជាលាយលក្ខណ៍អក្សរតាមផ្លូវទូត។

២. សំណើសុំចាប់ខ្លួនបណ្តោះអាសន្ន ត្រូវធ្វើជាលាយលក្ខណ៍អក្សរ និងមានៈ

(ក) ការពិពណ៌នាអំពីជនដែលត្រូវស្នើសុំ រួមទាំងព័ត៌មានអំពីសញ្ជាតិនៃបុគ្គលនោះ។

(ខ) សេចក្តីបញ្ជាក់នៃទីកន្លែង ដែលជននោះស្ថិតនៅ ប្រសិនបើដឹង។

(គ) សេចក្តីបញ្ជាក់សង្ខេប អំពីអង្គហេតុនៃសំណុំរឿង ប្រសិនបើមានពេលវេលា

(ឃ) ការពិពណ៌នាអំពីច្បាប់ដែលបានរំលោភ។

(ង) សេចក្តីបញ្ជាក់ថា មានដីកាចាប់ខ្លួនឬសាលក្រម/សាលដីកានៃការកាត់ទោស

(ច) សេចក្តីបញ្ជាក់អំពីសំណើបត្យាប័នលើជនដែលត្រូវស្នើសុំ នឹងត្រូវបញ្ជូនតាម

៣. ភាគីដាក់សំណើនឹងត្រូវបានទទួលដំណឹងពីលទ្ធផលនៃសំណើរបស់ខ្លួនដោយគ្មានបង្អែរបង្អង់។

[៣៨] កិច្ចព្រមព្រៀងស្តីពីបត្យាប័ន រវាងព្រះរាជាណាចក្រកម្ពុជា និងសាធារណរដ្ឋកូរ៉េ, នស/រកម/០១១១/00១, ០៦ មករា ២០១១,មាត្រា១១

៤. ការចាប់ខ្លួនបណ្ដោះអាសន្ននឹងត្រូវបញ្ចប់ ប្រសិនបើអាជ្ញាធរមានសមត្ថកិច្ចរបស់ភាគីទទួលសំណើពុំបានទទួលសំណើបត្យាប័នជាផ្លូវការ និងឯកសារសំអាងនានា ដូចដែលកំណត់ក្នុងមាត្រា ៧ ក្នុងរយៈពេល ៦០ថ្ងៃបន្ទាប់ពីការចាប់ខ្លួនជននោះ។ កថាខណ្ឌនោះ មិនត្រូវរារាំងលទ្ធភាពនៃការដោះលែង ដោយមានលក្ខខណ្ឌនូវជនដែលត្រូវស្នើសុំមុនផុតរយៈពេល៦០ថ្ងៃនេះ ក្នុងករណីដែលភាគីទទួលសំណើមានមូលដ្ឋានបដិសេធដាច់ខាត ឬមូលដ្ឋានបដិសេធដោយឆន្ទានុសិទ្ធិ ឬប្រសិនបើភាគីដាក់សំណើលុបចោលនូវសំណើបត្យាប័នរបស់ខ្លួន។

៥. ការដោះលែងជនដែលស្នើសុំពីការឃុំឃាំង អនុលោមតាមកថាខណ្ឌ៤នៃមាត្រានេះ មិនត្រូវធ្វើឱ្យផលប៉ះពាល់ដល់ការចាប់ខ្លួនឡើងជាបន្តបន្ទាប់ និងការធ្វើបត្យាប័នជននោះទេ ប្រសិនបើសំណើបត្យាប័ន និងរាល់ឯកសារសំអាងនានាត្រូវបានផ្ដល់ជូននៅពេលក្រោយ។[៣៩]

## ៣.៣.នីតិវិធីនៅដំណាក់កាលសភាស៊ើបសួរ

នៅពេលដែលរដ្ឋទទួលសំណើបានយល់ព្រមធ្វើបត្យាប័នបុគ្គលដែលប្រទេសកម្ពុជាទាមទារឱ្យធ្វើបត្យាប័នបុគ្គលនេះនឹងត្រូវបញ្ជូនឱ្យមកកាន់ប្រទេសកម្ពុជាវិញ។ ក្រោយពីបុគ្គលដែលត្រូវធ្វើបត្យាប័នបានមកដល់ប្រទេសកម្ពុជា នីតិវិធីបន្ទាប់គឺជាការពិនិត្យអំពីនិយតភាពនៃបត្យាប័ននោះ។

សភាស៊ើបសួរនៃសាលាឧទ្ធរណ៍ភ្នំពេញជាអង្គការតែមួយគត់ដែលមានសមត្ថកិច្ចដើម្បីពិចារណាលើនិយតភាពនៃបត្យាប័នដែលរាជរដ្ឋាភិបាលកម្ពុជាជាអ្នកទទួលបានក្នុងករណីបត្យាប័នដែលស្នើសុំដោយព្រះរាជាណាចក្រកម្ពុជាចំពោះរដ្ឋបរទេស។

លើសពីនេះទៅទៀតផ្អែកតាមបញ្ញត្តិនេះដដែល បុគ្គលដែលត្រូវធ្វើបត្យាប័នមានរយៈពេល ១៥ថ្ងៃ គិតពីពេលដែលសាមីខ្លួនបានមកដល់កម្ពុជា ដើម្បីលើកអំពីមោឃភាពនៃបត្យាប័ន។ ចំពោះនីតិវិធីបណ្ដឹងអំពីមោឃភាពនៃបត្យាប័ននៅចំពោះសភាស៊ើបសួរត្រូវបានកំណត់ដោយ ក្រមនីតិវិធីព្រហ្មទណ្ឌដោយកំណត់ថាសភាស៊ើបសួរធ្វើការស្ដាប់ចម្លើយរបស់បុគ្គលដែលត្រូវធ្វើបត្យាប័ន សេចក្ដីសន្និដ្ឋានសុំរបស់អគ្គព្រះរាជអាជ្ញា និងសេចក្ដីសន្និដ្ឋានរបស់មេធាវី។

ក្រោយពីនិតិវិធីនៅចំពោះមុខសភាស៊ើបសួរ និងក្រោយពីសភាស៊ើបសួរបានពិនិត្យអំពីនិយតភាពរួចហើយផ្អែកតាម មាត្រា ៥៩៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ក្នុងករណីដែលសភាស៊ើបសួរបានសម្រេចបដិសេធនីតិវិធីបត្យាប័ន បត្យាប័នត្រូវចាត់ទុកជាមោឃៈ បុគ្គលដែលត្រូវបានធ្វើបត្យាប័ននឹងត្រូវដោះលែងឱ្យមាន

[៣៩] កិច្ចព្រមព្រៀងស្ដីពីបត្យាប័ន រវាងព្រះរាជាណាចក្រកម្ពុជា និងសាធារណរដ្ឋកូរ៉េ, នស/រកម/០១១១/០០១, ០៦ មករា ២០១១, មាត្រា៩

សេរីភាពឡើងវិញ និងមានលទ្ធភាពចាកចេញពីដែនដីកម្ពុជា។ ប៉ុន្តែប្រសិនបើក្រោយពេលដែលសភាស៊ើបសួរបានពិនិត្យអំពីនិយតភាពនៃបត្យាប័នរួចហើយពុំមានមោឃភាពនៃបត្យាប័នទេនោះបត្យាប័ននឹងត្រូវផ្តល់ឱ្យ។

## ៣.៤.និតិវិធីក្រោយផ្តល់បត្យាប័ន

ក្រោយពីបត្យាប័នត្រូវបានផ្តល់ឱ្យ ព្រះរាជាណាចក្រកម្ពុជា និងភាគីទទួលសំណើត្រូវសម្រេចអំពីការអនុវត្តបត្យាប័ន។ ផ្អែកតាមកិច្ចព្រមព្រៀងស្តីពីបត្យាប័ន រវាងកម្ពុជា-កូរ៉េ ព្រមទាំងសន្ធិសញ្ញា និងអនុសញ្ញាស្តីពីបត្យាប័នរបស់កម្ពុជា ការអនុវត្តបត្យាប័ន ត្រូវធ្វើតាមវិធីពីរយ៉ាង គឺការប្រគល់ខ្លួនជនដែលត្រូវស្នើសុំ និងការប្រគល់ទ្រព្យសម្បត្តិ។

បន្ថែមពីលើនេះ កិច្ចព្រមព្រៀងស្តីពីបត្យាប័ន បានកំណត់ថា ភាគីទទួលសំណើត្រូវចេញ សោហ៊ុយនៃដំណើរការនីតិវិធីណាមួយដែលស្ថិតនៅក្រោមយុត្តាធិការរបស់ខ្លួនដែលកើតឡើងពី សំណើធ្វើបត្យាប័ន។

ចំណែកភាគីទទួលសំណោត្រូវចេញសោហ៊ុយដែលកើតឡើងនៅក្នុងដែនដីរបស់ខ្លួន ទាក់ទងនឹងការចាប់ខ្លួន និងការឃុំខ្លួននៃជនដែលស្នើសុំបត្យាប័ន ឬការដកហូត និងការប្រគល់ទ្រព្យសម្បត្តិ ។ ភាគីដាក់សំណើត្រូវចេញសោហ៊ុយដែលកើតឡើងពីការដឹកជញ្ជូនបុគ្គលដែលបត្យាប័នត្រូវផ្តល់ជូនពីទឹកដីនៃភាគីទទួលសំណើ រួមទាំងសោហ៊ុយធ្វើដំណើរឆ្លងកាត់។

កាលណាព្រះរាជាណាចក្រកម្ពុជាបានទទួលបត្យាប័ននៃអាណិកជនបរទេស ហើយក្រោយមកទៀតបានទទួលពាក្យប្តឹងសុំឱ្យធ្វើបត្យាប័នពីរដ្ឋបរទេសណាមួយផ្សេង ព្រះរាជាណាចក្រកម្ពុជានឹងអាចយល់ព្រមតាមពាក្យប្តឹងសុំនេះបាន ក្រោយពីបានទទួលការយល់ព្រមពីរដ្ឋដែលបានប្រគល់អាណិកជននេះមករាជរដ្ឋាភិបាលកម្ពុជា ។

ប៉ុន្តែការយល់ព្រមខាងលើនេះមិនជាការចាំបាច់ទេ កាលណាអាណិកជនបរទេសនេះមានលទ្ធភាពចាកចេញដោយសេរីពីដែនដីកម្ពុជារួចទៅហើយ ក្នុងរយៈពេល ៣០ (សាមសិប) ថ្ងៃ។[៩១]

### ក.ការប្រគល់ជនដែលត្រូវស្នើសុំ

ចំពោះនីតិវិធីប្រគល់ជនដែលត្រូវស្នើសុំត្រូវបានកំណត់ដោយកិច្ចព្រមព្រៀងស្តីពីបត្យាប័ន។ ផ្អែកតាមកិច្ចព្រមព្រៀងបត្យាប័នបានកំណត់ថា ៖

១. ប្រសិនបើបត្យាប័នត្រូវបានផ្តល់ឱ្យ ភាគីទទួលសំណើ និងភាគីដាក់សំណើត្រូវសម្រេចអំពីការអនុវត្តបត្យាប័នតាមរយៈការពិគ្រោះយោបល់គ្នា។ សម្រាប់គោលបំណងនេះសំណើត្រូវជូនព័ត៌មានដល់ភាគីដាក់សំណើអំពីរយៈពេលដែលជនដែលត្រូវស្នើសុំនោះត្រូវបានចាប់ឃុំឃាំង មុនពេលប្រគល់ខ្លួន។

---

[៩១] ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៨០៧/០២៤, ១០ សីហា ២០០៧, មាត្រា ៥៩៤

២.ល្គឹកណាកថាខណ្ឌ៣នៃប្រការនេះមិនមានចែងអ្វីមួយផ្ទុយពីនេះភាគីដាក់សំណើត្រូវបានចាត់ទុកថាបានបោះបង់សំណើបត្យាប័ន ប្រសិនបើភាគីនេះពុំទទួលយកជនដែលត្រូវបានស្នើសុំក្នុងរយៈពេល១៥ថ្ងៃក្រោយពីថ្ងៃដែលការអនុវត្តបត្យាប័នត្រូវបានព្រមព្រៀងគ្នារួចហើយ ភាគីទទួលសំណើត្រូវដោះលែងជននោះ ឱ្យមានសេរីភាពជាបន្ទាន់ ហើយអាចបដិសេធធ្វើបត្យាប័នចំពោះបទល្មើសដដែលនេះ។

៣.ប្រសិនបើភាគីណាមួយខកខានពុំបានប្រគល់ឬទទួលយកជនដែលត្រូវស្នើសុំក្នុងថិរវេលាដែលបានព្រមព្រៀងគ្នា ដោយករណីប្រធានសក្តិភាគីម្ខាងទៀតត្រូវតែបានគេជូនព័ត៌មានពីបញ្ហានេះ។ គូភាគីត្រូវសម្រេចជាថ្មីម្តងទៀតតាមការពិគ្រោះយោបល់គ្នា អំពីការអនុវត្តបត្យាប័នហើយបទប្បញ្ញត្តិនៃកថាខណ្ឌ២ នៃមាត្រានេះនឹងត្រូវអនុវត្ត។[៩១]

**ខ.ការប្រគល់ទ្រព្យសម្បត្តិ**

ក្នុងកម្រិតមួយដែលច្បាប់របស់ខ្លួនអនុញ្ញាតឱ្យ និងយោងតាមសំណើភាគីដាក់សំណើភាគីទទួលសំណើ ត្រូវ រឹបអូសទ្រព្យសម្បត្តិ និងក្រោយពីបានផ្តល់បត្យាប័ន ត្រូវប្រគល់ទ្រព្យសម្បត្តិ ដែលអាចតម្រូវឱ្យធ្វើជាភស្តុតាង ឬទ្រព្យសម្បត្តិដែលត្រូវបានទទួល ដោយសារលទ្ធផលនៃបទល្មើស។

ទ្រព្យសម្បត្តិ ដូចបានរៀបរាប់ខាងលើនេះ ត្រូវប្រគល់ជូន ទោះបីការធ្វើបត្យាប័នដែលត្រូវ បានផ្តល់ឱ្យមិនអាចអនុវត្តបានដោយមូលហេតុមកពីមរណភាពការបាត់ខ្លួន ឬការគេចខ្លួននៃជនដែលត្រូវជាប់ចោទ។ កាលណាទ្រព្យសម្បត្តិខាងលើនេះជាកម្មវត្ថុនៃការដកហូត ឬការរឹបអូសនៅក្នុងទឹកដីនភាគីទទួល សំណើភាគីនេះអាចរក្សាទុកជាបណ្តោះអាសន្ននូវទ្រព្យសម្បត្តិទាំងនេះ ឬបញ្ជូនត្រឡប់ទៅវិញក្នុងលក្ខខណ្ឌដែលទ្រព្យសម្បត្តិទាំងនោះ ត្រូវប្រគល់មកឱ្យភាគីទទួលសំណើវិញស្ថិតក្នុងការរង់ចាំនីតិវិធីព្រហ្មទណ្ឌ។

រាល់សិទ្ធិទាំងឡាយណាដែលភាគីទទួលសំណើនៃរដ្ឋណាមួយ ឬបុគ្គលណាមួយ អាចទទួលបានលើទ្រព្យសម្បត្តិ ដូចពោលខាងលើ ត្រូវរក្សាទុក។ នៅពេលដែលសិទ្ធិនេះនៅមាននៅឡើយ ទ្រព្យសម្បត្តិទាំងនេះត្រូវបញ្ជូនទៅភាគីទទួលសំណើ តាមសំណូមពររបស់ខ្លួន ដោយគ្មានបន្ទុកពន្ធអាករ ឱ្យបានឆាប់បំផុតដែលអាចធ្វើទៅបាន បន្ទាប់ពីការជំនុំជម្រះក្តី។[៩២]

---

[៩១] កិច្ចព្រមព្រៀងស្តីពីបត្យាប័ន រវាងព្រះរាជាណាចក្រកម្ពុជា និងសាធារណរដ្ឋកូរ៉េ, នស/រកម/០១១១/០០១, ០៦ មករា ២០១១,មាត្រា ១២

[៩២] កិច្ចព្រមព្រៀងស្តីពីបត្យាប័ន រវាងព្រះរាជាណាចក្រកម្ពុជា និងសាធារណរដ្ឋកូរ៉េ, នស/រកម/០១១១/០០១, ០៦ មករា ២០១១, មាត្រា ១៦

# សេចក្តីសន្និដ្ឋាន

# សេចក្តីសន្និដ្ឋាន

សរុបមកបត្យាប័ន ជានីតិវិធីមួយដ៏ចាំបាច់ និងមានសារៈសំខាន់ណាក្នុងរឿងព្រហ្មទណ្ឌ ជាពិសេសទៅលើ បទល្មើស និងទណ្ឌិតទាំងឡាយដែលស្ថិតនៅក្រៅដែនដីនៃព្រះរាជាណាចក្រកម្ពុជា ព្រោះថា បត្យាប័នជានីតិវិធីមួយដែលក្នុងនោះមានរដ្ឋមួយដែលជារដ្ឋធ្វើសំណើដែលធ្វើសំណើសុំជនណាម្នាក់ ទៅរដ្ឋមួយទៀតដើម្បីយកជននោះមកធ្វើការចោទប្រកាន់នៅចំពោះមុខយុត្តាធិការរបស់ខ្លួនឬយកជននោះមកអនុវត្តទោសនៅចំពោះមុខយុត្តាធិការរបស់ខ្លួននៅក្នុងប្រទេសរបស់ខ្លួន។ បត្យាប័ន ក៏ជានីតិវិធីមួយ ដ៏សំខាន់សម្រាប់រដ្ឋាភិបាលក្នុងការនាំយក ជនល្មើសមកកាត់ទោស ទោះជាពួកគេគេចខ្លួនទៅទីណាក៏ដោយ។ ហើយម៉្យាងវិញទៀតនីតិវិធីបត្យាប័នត្រូវបានបង្កើតឡើងក្នុងគោលបំណង ធានានូវនីត្យានុកូលភាព និងនិយតភាពនៃបត្យាប័នដើម្បីបញ្ចៀសនូវការធ្វើបត្យាប័នជាឯកត្តោភាគីទៅលើប្រជាពលរដ្ឋខ្មែរ ការពារសិទ្ធិសេរីភាពរបស់ប្រជាពលរដ្ឋខ្មែរស្របតាមបញ្ញត្តិនៃ មាត្រា ៣៣នៃរដ្ឋធម្មនុញ្ញ ដែលហាមឃាត់មិនឱ្យធ្វើបត្យាប័ន ជាឯកត្តោភាគី និងហាមមិនឱ្យធ្វើបត្យាប័នចំពោះប្រជាពលរដ្ឋកម្ពុជាក្នុងទឹកដីកម្ពុជាឡើយ។

ដំណើរការនៃការធ្វើបត្យាប័ន ជានីតិវិធីដែលមានលក្ខខណៈស្មុគស្មាញ និងច្រើនដំណាក់កាលដែលទាមទារឱ្យមាននូវការជ្រុមជ្រែងពីសំណាក់ក្រសួង និងស្ថាប័នជាច្រើនដូចជា ក្រសួងយុត្តិធម៌ ក្រសួងការបរទេស និងសាលាឧទ្ធរណ៍រាជធានីភ្នំពេញជាដើម។

ដើម្បីឱ្យបត្យាប័នអាចធ្វើទៅកើតលុះត្រាតែ បត្យាប័ននោះធ្វើទៅ តាមនីតិវិធីដែលច្បាប់បានកំណត់។ តួយ៉ាងសម្រាប់ព្រះរាជាណាចក្រកម្ពុជាយើង មានក្របខណ្ឌសំខាន់ៗបីដែលកំណត់អំពីការធ្វើបត្យាប័នដែលមានដូចជា បត្យាប័នក្នុងករណីមានសន្ធិសញ្ញា បត្យាប័នក្នុងករណីពុំមានសន្ធិសញ្ញា ក្របខណ្ឌនៃការធ្វើបត្យាប័នដែលមានកំណត់ក្នុងច្បាប់ពិសេស។

ដោយផ្អែកតាមក្របខណ្ឌទាំងបីនៃការធ្វើបត្យាប័ននេះ ក្នុងរឿងបត្យាប័ន ព្រះរាជាណាចក្រកម្ពុជា ដើរតួរជាតួអង្គសំខាន់ពីក្នុងទំនាក់ទំនងអន្តរជាតិ អាចជារដ្ឋដែលដាក់សំណើរធ្វើបត្យាប័ន ឬជារដ្ឋដែលទទួលសំណើធ្វើបត្យាប័ន។

ក្នុងករណីដែលព្រះរាជាណាចក្រកម្ពុជាជារដ្ឋទទួលសំណើនីតិវិធីបត្យាប័ន ចាប់ផ្តើមឡើងដោយសារតែមានពាក្យសុំធ្វើបត្យាប័ន និងបញ្ជូនទៅវិញដោយមានការប្រគល់បុគ្គលដែល គេទាមទារ ទៅរដ្ឋធ្វើសំណើដើម្បីធ្វើការចោទប្រកាន់ ឬជំនុំជម្រះ ឬអនុវត្តទោស។ ក្រមនីតិវិធីព្រហ្មទណ្ឌបានកំណត់អំពើនីតិវិធីបត្យាប័ន ក្នុងករណីដែលព្រះរាជាណាចក្រកម្ពុជាជារដ្ឋទទួលសំណើមានដូចជា នីតិវិធីពាក់ព័ន្ធនឹងពាក្យសុំ នីតិវិធីចាប់ខ្លួន និងការឃុំខ្លួនចំពោះបុគ្គលដែលគេ ទាមទារ និងនីតិវិធីនៅដំណាក់កាលសភាស៊ើបសួរ។

ចំណែកឯករណីដែលព្រះរាជាណាចក្រកម្ពុជាជារដ្ឋដាក់សំណើវិញនីតិវិធីបត្យាប័នត្រូវចាប់ផ្ដើមពី ពាក្យសុំធ្វើបត្យាប័ន និង ការបញ្ជូនពាក្យសុំតាមផ្លូវទូត ដូចក្នុងករណីដែលប្រទេសកម្ពុជាដើរតួនាទី ជារដ្ឋទទួលសំណើដែរ។ ចំពោះការពិនិត្យ និងការសម្រេចលើពាក្យសុំធ្វើបត្យាប័នដែលស្នើដោយប្រទេសកម្ពុជា គឺអាស្រ័យទៅលើ សន្ធិសញ្ញាអន្តរជាតិ និង ច្បាប់ជាតិរបស់រដ្ឋដែលបានទទួលសំណើពី ប្រទេសកម្ពុជា។ នៅពេលដែលរដ្ឋទទួលសំណើបានយល់ព្រមធ្វើបត្យាប័នបុគ្គលដែលប្រទេសកម្ពុជាទាមទារឱ្យ ធ្វើបត្យាប័ន បុគ្គលនេះនឹងត្រូវបញ្ជូនឱ្យ មកកាន់ប្រទេសកម្ពុជាវិញ ។

ទោះបីជាការធ្វើបត្យាប័នមានលក្ខណៈស្មុគស្មាញ និងមានបញ្ហាប្រឈមខ្លាំងយ៉ាងណាក៏ដោយក៏រាជរដ្ឋាភិបាលកម្ពុជាព្យាយាមអនុវត្តនូវនីតិវិធីបត្យាប័ននេះបានយ៉ាងគាប់ប្រសើរ ដើម្បីជួយការពារដល់សិទ្ធិ និងសេរីភាពរបស់ប្រជាពលរដ្ឋកម្ពុជា និងរួមចំណែកកិច្ចសហប្រតិបត្តិការផ្នែកច្បាប់ ជាមួយប្រទេសជិតខាង និងប្រទេសទាំងអស់លើឆាកអន្តរជាតិ។

ក្រោយធ្វើការសិក្សាស្រាវជ្រាវអំពីប្រធានបទ ស្ដីពីបត្យាប័នក្រុមយើងខ្ញុំបានទទួលនូវចំណេះដឹងទាក់ទងនឹងមូលដ្ឋាននៃបត្យាប័ន និងចំណេះដឹងស្ដីពី សន្ធិសញ្ញា និងកិច្ចព្រមព្រៀងទាំងឡាយដែលពាក់ព័ន្ធនឹងបត្យាប័ន ព្រមទាំងចំណេះដឹងពាក់ព័ន្ធនឹងលក្ខខណ្ឌ និងនីតិវិធីនៃការធ្វើបត្យាប័នទាំងក្នុងករណីដែលព្រះរាជាណាចក្រកម្ពុជាជារដ្ឋដាក់សំណើ និងករណីដែលព្រះរាជាណាចក្រកម្ពុជាជារដ្ឋទទួលសំណើផងដែរ។

# អនុសាសន៍

# អនុសាសន៍

ផ្អែកតាមការសិក្សាស្រាវជ្រាវរបស់ក្រុមយើងខ្ញុំកន្លងមក យើងខ្ញុំសង្កេតឃើញថា នីតិវិធីបត្យាប័នក្នុងព្រះរាជាណាចក្រកម្ពុជា នៅមានការខ្វះខាតត្រង់វិធានគតិយុត្តសម្រាប់ការអនុវត្ត ព្រមទាំងមានការខ្វះចន្លោះច្រើនលើការសិក្សាស្រាវ និងការចងក្រងជាសៀវភៅលើប្រធានបទស្តីពីបត្យាប័ននេះ។

ទោះបីជាមានការបង្កើតក្របខណ្ឌច្បាប់សម្រាប់ការធ្វើបត្យាប័នក៏ដោយ ក៏កម្ពុជាប្រឈមមុខនឹងបញ្ហាសំខាន់ៗជាច្រើនក្នុងការអនុវត្តច្បាប់ធ្វើបត្យាប័នរបស់ខ្លួនប្រកបដោយប្រសិទ្ធភាព។

បញ្ហាប្រឈមចម្បងមួយគឺខ្វះខាតនូវវិធានច្បាប់សម្រាប់ការអនុវត្តបត្យាប័ន ពោលគឺកម្ពុជាមិនមានច្បាប់ធ្វើបត្យាប័នជាមួយប្រទេសភាគច្រើនទេ ដែលមានន័យថាវាពិបាកសម្រាប់រដ្ឋាភិបាលបរទេសក្នុងការស្នើសុំធ្វើ បត្យាប័នបុគ្គលដែលស្ថិតនៅក្នុងប្រទេសកម្ពុជា និងពិបាកសម្រាប់រាជរដ្ឋាភិបាលកម្ពុជាក្នុងការស្នើសុំប្រជាពលរដ្ឋខ្មែរដែលបានប្រព្រឹត្តនៅក្នុង ប្រទេសផ្សេងទៀត។

ចំណែកឯការចងក្រងជាសៀវភៅស្តីពីអំពីបត្យាប័ន គឺពុំទាន់មានសៀវភៅណាសរសេរ និងចងក្រងឱ្យបានក្បោះក្បាយអំពើនីតិវិធីបត្យាប័នសម្រាប់ឱ្យសិស្ស និស្សិតធ្វើការសិក្សាស្រាវជ្រាវ និងយល់ដឹងលំអិតអំពើបត្យាប័ននេះឡើយ។ ផ្អែកតាមការសិក្សាស្រាវកន្លងមក សម្រាប់ឯកសារស្តីពីប្រធានបទនេះ យើងសង្កេតឃើញមានខ្លះៗក្នុង វិដេអូអប់រំផ្សព្វផ្សាយអំពីច្បាប់ ដែលរៀបចំឡើងដោយការសហការគ្នា រវាងក្រសួងយុត្តិធម៌ និងទូរទស្សន៍ជាតិនៃកម្ពុជាប៉ុណ្ណោះ ដើម្បីចូលរួមក្នុងគោលនយោបាយរបស់រាជរដ្ឋាភិបាលក្នុងការផ្សព្វផ្សាយ ច្បាប់ក្នុងព្រះរាជាណាចក្រកម្ពុជា។

ហេតុដូច្នេះ រាជរដ្ឋាភិបាលកម្ពុជា ត្រូវបន្តការខិតខំប្រឹងប្រែងក្នុងការអនុវត្តបត្យាប័ន និងបង្កើតនូវកិច្ចសហប្រតិបត្តិការជាមួយប្រទេសផ្សេងនៅលើពិភពលោកដើម្បីបង្កើតជាបទប្បញ្ញត្តិផ្សេងទៀតសម្រាប់អនុវត្តបត្យាប័នព្រមទាំងដោះស្រាយនូវបញ្ហាបត្យាប័នទាំងឡាយដែលព្រះរាជាណាចក្រកម្ពុជាកំពុងប្រឈម។ ព្រមទាំងលើកទឹកចិត្តដល់ សាស្ត្រាចារ្យ និងសិស្សនិស្សិតទាំងអស់ខិតខំប្រឹងប្រែងស្រាវជ្រាវ និងតាក់តែងសៀវភៅ និងឯកសារឱ្យបានច្រើនលើប្រធានបទស្តីពីបត្យាប័ន និងបង្កើននូវការបណ្តុះបណ្តាលអំពីការធ្វើបត្យាប័នឱ្យបានទូលំទូលាយ សម្រាប់សាធារណៈជន និងសិស្ស និស្សិតទាំងអស់។

# ឯកសារយោង

# ឯកសារយោង

- **លិខិតបទដ្ឋានគតិយុត្តជាតិ**

  ១- រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ប្រកាសឱ្យប្រើ ថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ ១៩៩៣

  ២- ច្បាប់ស្តីពីការប្រឆាំងអំពើភេរវកម្ម ប្រកាសឱ្យប្រើថ្ងៃទី ១០ ខែកក្កដា ឆ្នាំ ២០០៧

- **លិខិតបទដ្ឋានគតិយុត្តជាតិ**

  ១- សន្ធិសញ្ញាគំរូ ស្តីពីបត្យាប័នរបស់អង្គការសហប្រជាជាតិ អនុម័តថ្ងៃទី ១៤ ខែធ្នូ ឆ្នាំ ១៩៩០

  ២- សន្ធិសញ្ញាសន្ធិសញ្ញាស្តីពីបត្យាប័ន រវាងព្រះរាជាណាចក្រកម្ពុជា ជាមួយៈ

  - ព្រះរាជាណាចក្រថៃ ដែលអនុម័តនៅថ្ងៃទី១៦ ខែមិថុនា ឆ្នាំ១៩៩៩
  - សាធារណរដ្ឋប្រជាមានិតចិន ដែលអនុម័តនៅថ្ងៃទី០៥ ខែមិថុនា ឆ្នាំ២០០០
  - សាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ ដែលអនុម័តនៅថ្ងៃទី០៩ ខែកុម្ភៈ ឆ្នាំ២០០៥
  - សាធារណរដ្ឋសង្គមនិយមវៀតណាម ដែលអនុម័តនៅថ្ងៃទី២៦ ខែមិថុនា ឆ្នាំ២០១៤

  ៣- កិច្ចព្រមព្រៀងទ្វេភាគីស្តីពីបត្យាប័ន រវាងព្រះរាជាណាចក្រកម្ពុជា ជាមួយនឹងសាធារណរដ្ឋកូរ៉េ ដែលបាន អនុម័តថ្ងៃទី២៦ ខែវិច្ឆិកា ឆ្នាំ២០១០

  ៤- អនុសញ្ញាស្តីពីបត្យាប័ន រវាងព្រះរាជាណាចក្រកម្ពុជា និងសាធារណរដ្ឋបារាំងបានអនុម័តថ្ងៃទី០៦ ខែតុលា ឆ្នាំ២០២០

- **ឯកសារផ្សេងៗទៀត**

  ១- សាស្ត្រាចារ្យ រុន ពណ្ណារិទ្ធ,*សៀវភៅ ស្តីពី នីតិព្រហ្មទណ្ឌទូទៅ* បោះពុម្ព ឆ្នាំ២០១១

  ២- កម្មវិធីផ្សព្វផ្សាយច្បាប់ស្តីពីក្រមនីតិវិធីព្រហ្មទណ្ឌ,*វីដេអូស្តីអំពី សមត្ថកិច្ចពិសេសរបស់សភាស៊ើបសួរ ក្នុងរឿងបត្យាប័ន*

# ឧបសម្ព័ន្ធ

# បញ្ជីឧបសម្ព័ន្ធ

## ១- ឧបសម្ព័ន្ធគតិយុត្ត

ឧបសម្ព័ន្ធទី ១.សន្ធិសញ្ញាស្តីពីបត្យាប័ន រវាងព្រះរាជាណាចក្រកម្ពុជា និងព្រះរាជាណាចក្រថៃ

ឧបសម្ព័ន្ធទី ២.សន្ធិសញ្ញាស្តីពីបត្យាប័ន រវាងព្រះរាជាណាចក្រកម្ពុជា និងសាធារណរដ្ឋប្រជាមានិតចិន

ឧបសម្ព័ន្ធទី ៣.សន្ធិសញ្ញា ស្តីពីបត្យាប័ន រវាងព្រះរាជាណាចក្រកម្ពុជា និងសាធារណរដ្ឋប្រជាមានិតឡាវ

ឧបសម្ព័ន្ធទី ៤.កិច្ចព្រមព្រៀងស្តីពីបត្យាប័ន រវាងព្រះរាជាណាចក្រកម្ពុជា និងសាធារណរដ្ឋកូរ៉េ

ឧបសម្ព័ន្ធទី ៥.សន្ធិសញ្ញាស្តីពីបត្យាប័ន រវាងព្រះរាជាណាចក្រកម្ពុជា និងសាធារណរដ្ឋសង្គមនិយមវៀតណាម

ឧបសម្ព័ន្ធទី ៦.អនុសញ្ញាស្តីពីបត្យាប័ន រវាងព្រះរាជាណាចក្រកម្ពុជា និងសាធារណរដ្ឋបារាំង

ឧបសម្ព័ន្ធទី ៧.សន្ធិសញ្ញាស្តីពីបត្យាប័ន រវាងព្រះរាជាណាចក្រកម្ពុជា និងសហព័ន្ធរុស្ស៊ី

## ២- ឧបសម្ព័ន្ធជារូបភាព

ឧបសម្ព័ន្ធទី ១.គំនូសតាងនៃនីតិវិធីបត្យាប័ន

ឧបសម្ព័ន្ធទី ២.គំនូសតាងនៃនីតិវិធីបត្យាប័នតាមក្រមនីតិវិធីព្រហ្មទណ្ឌ ដែលស្នើដោយរដ្ឋបរទេស

## ៣- ឧបសម្ព័ន្ធជាឯកសារ

ឧបសម្ព័ន្ធទី ១.បត្យាប័ន រៀបរៀងដោយ ឯកឧត្តម ផូវ សំភី ខែមករា ឆ្នាំ២០០៨

ឧបសម្ព័ន្ធទី ២.បទបង្ហាញស្តីពីបត្យាប័ន រៀបរៀងដោយក្រសួងយុត្តិធម៌ ឆ្នាំ ២០២២

ឧបសម្ព័ន្ធទី ៣.កំណត់បង្ហាញរឿងរបស់ក្រសួងយុត្តិធម៌ ស្តីពីបត្យាប័នពីប្រទេសឡាវ

# ឧបសម្ព័ន្ធគតិយុត្ត

# ឧបសម្ព័ន្ធជារូបភាព

# ឧបសម្ព័ន្ធទី ១


៧- នីតិវិធីធ្វើបត្យាប័ន
រដ្ឋធ្វើសំណើ (ភស្តុតាង អត្តសញ្ញាបុគ្គលដែលទាមទារ...)
ទី (១) តាមផ្លូវទូត
រដ្ឋាភិបាល (រដ្ឋមន្ត្រីក្រសួងការបរទេស)
រដ្ឋមន្ត្រីក្រសួងការបរទេសត្រូវបញ្ជូនពាក្យសុំទៅរដ្ឋមន្ត្រីក្រសួងយុត្តិធម៌ដើម្បី៖ ទី១-ពិនិត្យផ្ទៀងផ្ទាត់ ទី២-និយតភាពនៃការស្នើសុំធ្វើបត្យាប័ន
រដ្ឋមន្ត្រីក្រសួងយុត្តិធម៌
អគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍
អគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍រៀបចំឯកសារប្ដឹងទៅសភាស៊ើបសួរ
សភាស៊ើបសួរនៃសាលាឧទ្ធរណ៍
ទី (២)
រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ត្រូវជូនរឿងនេះទៅរដ្ឋាភិបាល ដើម្បីចេញអនុក្រឹត្យបង្គាប់ឲ្យធ្វើបត្យាប័ន
ប្រសិនបើយល់ព្រមចំពោះការធ្វើបត្យាប័ន សភាស៊ើបសួរត្រូវជូនដំណឹងភ្លាមទៅរដ្ឋមន្ត្រីក្រសួងយុត្តិធម៌
-មិនយល់ព្រម ឬ យល់ព្រម ចំពោះការស្នើសុំធ្វើបត្យាប័ន
-មិនយល់ព្រមបុគ្គលដែលទាមទារត្រូវដោះលែង
ឧទ្ទេសនាមដោយ៖ លោក ជុំ គីរី
១១

# ឧបសម្ព័ន្ធទី ២



នីតិវិធីនៃបត្យាប័នតាមក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា ដែលស្នើដោយរដ្ឋបរទេស
(ចងក្រងដោយ៖ ស៊ាង សំកស់)
ពាក្យសុំធ្វើបត្យាប័ន
លិខិតបញ្ជាក់កស្តុតាង
- ឯកសារដែលមានលក្ខណៈគ្រប់គ្រាន់ក្នុងការកំណត់អត្តសញ្ញាណបុគ្គលដែលគេទាមទារ
- សេចក្តីរាយការណ៍អំពីអង្គហេតុ ដែលត្រូវចោទប្រកាន់លើបុគ្គលដែលគេទាមទារ
- អត្ថបទច្បាប់ដែលអនុវត្តទៅលើអំពើនោះ និង ទោសដែលត្រូវទទួលរង
- លិខិតចម្លងនៃសេចក្តីសម្រេចផ្តន្ទាទោសប្រសិនបើមាន
រដ្ឋមន្ត្រីក្រសួងការបរទេសកម្ពុជា
រដ្ឋមន្ត្រីក្រសួងយុត្តិធម៌
អគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ភ្នំពេញ
សភាស៊ើបសួរ នៃសាលាឧទ្ធរណ៍ភ្នំពេញ
សាលដីកាដែលចូលជាស្ថាពររួចហើយត្រូវជូនដំណឹងភ្លាមដល់រដ្ឋមន្ត្រីក្រសួងយុត្តិធម៌
យោបល់សភាស៊ើបសួរក្រោយពីពិភាក្សាដេញដោល
(ចេញជាសាលដីកា)
-ក្រោយពីស្តាប់ចម្លើយបុគ្គលដែលគេទាមទារ
-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានសុំរបស់អគ្គព្រះរាជអាជ្ញា
- ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានការពាររបស់មេធាវី
ករណីយល់ព្រម
ករណីមិនយល់ព្រម៖បត្យាប័នមិនអាចធ្វើបានដោយរាជរដ្ឋាភិបាលកម្ពុជា
រដ្ឋមន្ត្រីក្រសួងយុត្តិធម៌អាចបញ្ជូនរឿងនេះទៅរាជរដ្ឋាភិបាល
រាជរដ្ឋាភិបាលចេញអនុក្រឹត្យបង្គាប់ឱ្យធ្វើបត្យាប័ន
ក្នុងរយៈពេល ៣០ ថ្ងៃ បន្ទាប់ពីថ្ងៃជូនដំណឹងអំពីអនុក្រឹត្យបង្គាប់ឱ្យធ្វើបត្យាប័ន ប្រសិនបើរដ្ឋធ្វើសំណើមិនបានចាប់ផ្តើមនីតិវិធីធ្វើមាតុភូមិនិវត្តន៍ នោះបុគ្គលដែលគេទាមទារត្រូវបានដោះលែងឱ្យមានសេរីភាពវិញ។

# ឧបសម្ព័ន្ធជាឯកសារ

**ឧបសម្ព័ន្ធទី ១**

# បត្យាប័ន

## ឯកឧត្តម ផូវ សំតី អគ្គនាយកកិច្ចការរដ្ឋបាលតុលាការ

ខែមករា ឆ្នាំ២០១៨

# មាតិកា

- សន្ធិសញ្ញា អនុសញ្ញា ឬកិច្ចព្រមព្រៀង
- ទិដ្ឋភាពទូទៅ
- និយមន័យ
- លក្ខខណ្ឌធ្វើបត្យាប័ន
- នីតិវិធីនៃបត្យាប័ន
- បត្យាប័នដែលស្នើសុំដោយកម្ពុជាចំពោះរដ្ឋបរទេស
- ពាក្យសុំឆ្លងកាត់

# សន្ធិសញ្ញា អនុសញ្ញា ឬកិច្ចព្រមព្រៀងអន្តរជាតិជាអ្វី ?

- ការរៀបចំសន្ធិសញ្ញា អនុសញ្ញា ឬកិច្ចព្រមព្រៀងមានការកំណត់នៅមាត្រា៧ នៃអនុសញ្ញា Vienna Convention on the Law of Treaties ឆ្នាំ១៩៦៩ ។
- សន្ធិសញ្ញា អនុសញ្ញា ឬកិច្ចព្រមព្រៀង អាចធ្វើជាទ្វេភាគី ឬពហុភាគី ទៅតាមការព្រមព្រៀង និងការឯកភាពគ្នាថាបង្កើតជាទ្វេភាគី ឬពហុភាគី ទៅតាមកម្មវត្ថុនៃការធ្វើសន្ធិសញ្ញា។
- ការរៀបចំសន្ធិសញ្ញា ត្រូវផ្អែកលើច្បាប់រដ្ឋដែលមានរដ្ឋធម្មនុញ្ញាចម្បង អាចភ្ជាប់ទៅនឹងសន្ធិសញ្ញាអន្តរជាតិ ដើម្បីការពារសិទ្ធិ និងផលប្រយោជន៍រដ្ឋ ហើយច្បាប់រដ្ឋក៏មិនអាចជំទាស់នឹងសន្ធិសញ្ញាអន្តរជាតិដែលរដ្ឋនោះបានផ្តល់សច្ចាប័នរួចរាល់ផងដែរ។ ប៉ុន្តែបើសិនមានប៉ះពាល់នឹងផលប្រយោជន៍ជាតិ ឬមិនចំណេះអ្វីណាមួយនោះពីសន្ធិសញ្ញានេះ រដ្ឋនោះអាចស្នើសុំលុបចោល ឬដកខ្លួនចេញពីសន្ធិសញ្ញានោះបាន។

# សន្ធិសញ្ញា អនុសញ្ញា ឬកិច្ចព្រមព្រៀង រវាងកម្ពុជា ជាមួយរដ្ឋបរទេស

- សន្ធិសញ្ញាស្តីពីបត្យាប័ន រវាងកម្ពុជា-ថៃ ឆ្នាំ១៩៩៨
- សន្ធិសញ្ញាស្តីពីបត្យាប័ន រវាងកម្ពុជា-ចិន ឆ្នាំ១៩៩៩
- សន្ធិសញ្ញា ស្តីពីបត្យាប័ន រវាងកម្ពុជា-ឡាវ ឆ្នាំ១៩៩៩
- កិច្ចព្រមព្រៀងស្តីពីបត្យាប័ន រវាងកម្ពុជា-កូរ៉េ ឆ្នាំ២០០៩
- អនុសញ្ញាស្តីពីបត្យាប័ន រវាងកម្ពុជា-បារាំង ឆ្នាំ២០១៥
- សន្ធិសញ្ញាស្តីពីបត្យាប័ន រវាងកម្ពុជា-រុស្ស៊ី ឆ្នាំ២០១៧
- សន្ធិសញ្ញាអាស៊ាន ស្តីពីការជួយគ្នាទៅវិញទៅមកផ្នែកច្បាប់ក្នុងវិស័យព្រហ្មទណ្ឌ ឆ្នាំ២០០៤

# ចិជ្ជាភាពទូទៅ

## ក្រមនីតិវិធីព្រហ្មទណ្ឌ

- អាចយល់ព្រមដល់រដ្ឋបរទេសនូវអេណិកជនបរទេស ស្នាក់នៅកម្ពុជា ៖
  - កម្មវត្ថុនៃនីតិវិធីចោទប្រកាន់
  - ត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារ (មាត្រា ៥៦៦)
- សន្ធិសញ្ញា និងអនុសញ្ញាអន្តរជាតិ ៖ បត្យាប័នអេណិកជនបរទេស ដែលត្រូវបានចាប់ខ្លួនលើដែនដីកម្ពុជា ត្រូវបានគ្រប់គ្រងដោយសន្ធិសញ្ញា និងអនុសញ្ញាអន្តជាតិដែលបានផ្តល់សច្ចាប័នដោយកម្ពុជា
- ក្នុងករណីគ្មានសន្ធិសញ្ញា ឬអនុសញ្ញាអន្តរជាតិ ដែលត្រូវបានទទួលសច្ចាប័នដោយកម្ពុជា បញ្ញាតិនៃករណីនេះ ត្រូវបានយកមកអនុវត្ត លើកលែងតែមានបញ្ញត្តិពិសេសនៅក្នុងច្បាប់ផ្សេងទៀត (មាត្រា ៥៦៧)

# ចិជ្ជាភាពទូទៅ (ត)

## សន្ធិសញ្ញាអន្តរជាតិ

- លើកកម្ពស់កិច្ចសហប្រតិបត្តិការប្រកបដោយប្រសិទ្ធភាពក្នុងការបង្ក្រាបបទល្មើសដោយឈរលើមូលដ្ឋានគោរពអធិបតេយ្យភាពគ្នាទៅវិញទៅមកសមភាព និងផលប្រយោជន៍រួមទាំងសងខាងតាមរយៈការចុះសន្ធិសញ្ញាបត្យាប័ន
- ដោយអនុលោមតាមបទប្បញ្ញត្តិនៃសន្ធិសញ្ញា ភាគីយល់ព្រមធ្វើបត្យាប័នទៅឲ្យភាគីម្ខាងទៀតនូវជនទាំងឡាយដែលមានវត្តមាននៅលើដែនដីរបស់ខ្លួនដែលភាគីម្ខាងទៀតកំពុងតែស្វែងរក ដើម្បីធ្វើការចោទប្រកាន់ ជំនុំជម្រះ ឬអនុវត្តទោស ចំពោះបទល្មើសដែលអាចធ្វើបត្យាប័នបាន
- សន្ធិសញ្ញានេះមិនមានឥទ្ធិពលដល់សិទ្ធិនិងកាតព្វកិច្ចទាំងឡាយដែលមានចែងក្នុងសន្ធិសញ្ញា អនុសញ្ញា កតិកាសញ្ញា លិខិតុបករណ៍អន្តរជាតិផ្សេងទៀតដែលគូភាគីជាសមាជិកឡើយ

# និយមន័យ

មានអត្ថន័យ ២យ៉ាង គឺ ៖

1. រដ្ឋធ្វើសំណើ គឺរដ្ឋបរទេសដែលស្នើសុំធ្វើបត្យាប័នអាណិកជនរស់នៅបរទេស។
2. បុគ្គលដែលគេទាមទារ គឺជាអាណិកជនបរទេសដែលស្នាក់នៅលើដែនដីរដ្ឋត្រូវស្នើសុំ និងជាកម្មវត្ថុនៃសំណើសុំឱ្យធ្វើបត្យាប័ន។

# លក្ខខណ្ឌធ្វើបត្យាប័ន (ត)

## លក្ខខណ្ឌនៃបត្យាប័ននឹងទាក់ទងអំពើ (មាត្រា ៥៦៩)

- បត្យាប័នអាចធ្វើទៅបានលុះត្រាតែអំពើដែលត្រូវចោទប្រកាន់លើបុគ្គលដែលគេទាមទារនោះ ជាបទល្មើសតាមច្បាប់រដ្ឋធ្វើសំណើ និងតាមកម្ពុជាផងដែរ ទោះបីជា ៖
  - អំពើដែលកើតជាបទល្មើស ស្ថិតនៅក្នុងប្រភេទបទល្មើសមិនដូចគ្នាក្តី ឬ
  - ឈ្មោះបទល្មើស ការប្រើបច្ចេកស័ព្ទ ឬនិយមន័យ ឬការកំណត់លក្ខណៈបទល្មើសមិនដូចគ្នាក្តី ឬ
  - ជាតុផ្សំនៃបទល្មើសនៃច្បាប់របស់រដ្ឋធ្វើសំណើ ខុសគ្នាពីជាតុផ្សំនៃបទល្មើស ដែលកំណត់ដោយកម្ពុជាក៏ដោយ ប្រសិនបើពិចារណាទៅលើចំនួនសរុបនៃអំពើដែលត្រូវបានបង្ហាញដោយរដ្ឋធ្វើសំណើដែលប្រព្រឹត្តតាមបញ្ញានៃច្បាប់ជាធរមានកម្ពុជា

# លក្ខខណ្ឌធ្វើបត្យាប័ន (ត)

- មាត្រា ៥៧០ ករណីនៃការប៉ុនប៉ងប្រព្រឹត្តបទល្មើស និងការសមគំនិត
- មាត្រា ៥៧១ លក្ខខណ្ឌទាក់ទងនឹងទោសពន្ធនាគារ
- មាត្រា ៥៧២ លក្ខខណ្ឌទាក់ទងនឹងទៅកន្លែងប្រព្រឹត្តបទល្មើស
- មាត្រា ៥៧៣ អំពើដែលមានលក្ខណៈនយោបាយ
- មាត្រា ៥៧៤ អំពើដែលត្រូវបានប្រព្រឹត្តលើដែនដី និងត្រូវបានជំនុំជម្រះជាស្ថាពរួចរាល់ហើយ
- មាត្រា ៥៧៥ ការរលត់នៃបណ្ដឹងអាជ្ញា
- មាត្រា ៥៧៦ ពាក្យសុំធ្វើបត្យាប័នជាច្រើនទាក់ទងនឹងបុគ្គលតែម្នាក់
- មាត្រា ៥៧៧ លក្ខខណ្ឌធ្វើបត្យាប័នទាក់ទងពាក្យសុំ
- មាត្រា ៥៧៨ ការព្យួរបត្យាប័ន

# នីតិវិធីនៃធ្វើបត្យាប័ន

- គ្រប់ពាក្យសុំធ្វើបត្យាប័នត្រូវជូនរដ្ឋាភិបាលកម្ពុជាតាមផ្លូវទូត។ ពាក្យសុំនេះត្រូវមានលិខិតបញ្ជាក់ភស្តុតាងអមជាមួយផង។

- ការបញ្ជូនពាក្យសុំធ្វើបត្យាប័ន ៖ រដ្ឋមន្ត្រីក្រសួងការបរទេសកម្ពុជាបញ្ជូនពាក្យសុំធ្វើបត្យាប័ន និងលិខិតបញ្ជាក់ភស្តុតាងទៅរដ្ឋមន្ត្រីក្រសួងយុត្តិធម៌។ រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ផ្ទៀងផ្ទាត់មើលនិយតភាពនៃពាក្យសុំ និងបញ្ជូនពាក្យនោះទៅអគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ (មាត្រា ៥៨០)។

- អគ្គព្រះរាជអាជ្ញារៀបចំសំណុំរឿង ដើម្បីប្ដឹងទៅសភាស៊ើបសួរនៃ សាលាឧទ្ធរណ៍ភ្នំពេញ (មាត្រា ៥៨៤)។

# នីតិវិធីនៃធ្វើបត្យាប័ន (ត)

- យោបល់របស់សភាស៊ើបសួរ (មាត្រា ៥៨៦) សភាស៊ើបសួរផ្តល់យោបល់មិនយល់ព្រម ប្រសិនបើយល់ឃើញថាលក្ខខណ្ឌច្បាប់នៃបត្យាប័នមិនត្រូវបានបំពេញទេការយល់ព្រមធ្វើបត្យាប័ន (មាត្រា ៥៨៨) ប្រសិនបើបុគ្គលដែលគេទាមទារ យល់ព្រមឱ្យគេបញ្ជូនតាមពាក្យសុំរបស់រដ្ឋធ្វើសំណើក្រោយពីបានទទួលព័ត៌មានពេញលេញអំពីផលវិបាកនៃការយល់ព្រមចំពោះបត្យាប័ន សភាស៊ើបសួរត្រូវចុះនិទ្ទេសនេះនៅក្នុងសាលដីការបស់ខ្លួន។
- សភាស៊ើបសួរនៃសាលាឧទ្ធរណ៍ភ្នំពេញ ជាអង្គភាពតែមួយគត់ដែលមានសមត្ថកិច្ច ដើម្បីពិចារណាលើនិយតភាពនៃបត្យាប័នដែលរដ្ឋាភិបាលកម្ពុជាបានទទួល។

# នីតិវិធីនៃធ្វើបត្យាប័ន (ត)

## សន្ធិសញ្ញាអន្តរជាតិ

- លើកលែងតែមានបញ្ញត្តិផ្ទុយពីសន្ធិសញ្ញា ច្បាប់ជាតិរបស់ភាគីទទួលសំណើប៉ុណ្ណោះ ដែលអាចអនុវត្តចំពោះនីតិវិធីនៃការចាប់ខ្លួនជាបណ្តោះអាសន្ន ការធ្វើបត្យាប័ន និងការឆ្លងកាត់
- គូភាគីត្រូវធ្វើការទំនាក់ទំនងគ្នាដោយផ្ទាល់តាមរយៈអាជ្ញាធរកណ្តាល ឬ តាមរយៈបណ្តាញការទូត
- ប្រសិនបើភាគីទទួលសំណើយល់ឃើញថា ព័ត៌មានដែលភ្ជាប់មកជាមួយសំណើសុំបត្យាប័នមិនគ្រប់គ្រាន់សម្រាប់អនុវត្តនីតិវិធីធ្វើបត្យាប័ន តាមសន្ធិសញ្ញា ភាគីអាចស្នើសុំផ្តល់ព័ត៌មានបន្ថែមនៅក្នុងអំឡុងពេលសមស្របដែលបានកំណត់ដោយភាគីទទួលសំណើ

# បត្យាប័នស្នើសុំដោយកម្ពុជាចំពោះរដ្ឋបរទេស

- បុគ្គលដែលត្រូវបានធ្វើបត្យាប័ន មានរយៈពេល១៥ថ្ងៃ គិតពីពេលដែលសាមីខ្លួនមកដល់កម្ពុជា ដើម្បីលើកអំពីមោឃភាពនៃបត្យាប័ន។
- សភាស៊ើបសួរធ្វើការសម្រេច ក្រោយពីបានស្តាប់ចម្លើយរបស់បុគ្គលដែលត្រូវបានទទួលពាក្យប្តឹងសុំឱ្យធ្វើបត្យាប័នពីរដ្ឋបរទេសណាមួយផ្សេង កម្ពុជានឹងអាចយល់ព្រមតាមពាក្យប្តឹងនេះបាន ក្រោយពីបានទទួលការយល់ព្រមពីរដ្ឋដែលបានប្រគល់អាណិកជននេះ មករាជរដ្ឋាភិបាលកម្ពុជា។
- ប៉ុន្តែការយល់ព្រមនេះ មិនជាការចាំបាច់ទេ កាលណាអាណិកជនបរទេសនេះមានលទ្ធភាពចាកចេញដោយសេរីពីដែនដីកម្ពុជារួចទៅហើយ រយៈពេល ៣០ថ្ងៃ។

# ពាក្យសុំឆ្លងកាត់

## ក្រមនីតិវិធីព្រហ្មទណ្ឌ

ការឆ្លងកាត់ដែនដីកម្ពុជា ដោយបុគ្គលណាម្នាក់ដែលស្ថិតក្នុងក្របខណ្ឌនៃនីតិវិធីបត្យាប័ន អាចត្រូវបានអនុញ្ញាត កាលណាបត្យាប័ននេះមិនទាន់ទងនឹងបទល្មើសនយោបាយទេ។ ពាក្យសុំត្រូវសុំត្រូវធ្វើតាមផ្លូវទូត។ ពាក្យសុំតែមានលិខិតបញ្ជាក់ភស្តុតាងបញ្ជាក់ថាត្រឹមត្រូវអមជាមួយផង។

# ពាក្យសុំឆ្លងកាត់ (ត)

## សន្ធិសញ្ញាអន្តរជាតិ

1. អនុលោមតាមច្បាប់របស់ភាគី ការឆ្លងកាត់របស់បុគ្គលដែលត្រូវធ្វើបត្យាប័ន ដោយភាគីទីបីទៅភាគីមួយតាមដែនដីនៃភាគីមួយទៀត ត្រូវអនុញ្ញាតតាម សំណើជាលាយលក្ខណ៍អក្សរតាមរយៈបណ្តាញការទូត ឬដោយផ្ទាល់រវាង អាជ្ញាធរកណ្តាលនៃគូភាគី ហើយការឆ្លងកាត់នេះត្រូវបានធ្វើឡើងបន្ទាប់ពីមាន ការយល់ព្រមជាលាយលក្ខណ៍អក្សរពីភាគីនោះ។
2. ការអនុញ្ញាតសុំការឆ្លងកាត់នេះមិនតម្រូវឲ្យមានការស្នើសុំទេ ក្នុងករណីដែល មានការប្រើប្រាស់មធ្យោបាយដឹកជញ្ជូនតាមផ្លូវអាកាស ហើយគ្មានការសុំចុះ ចតលើដែនដីនៃភាគីដែលត្រូវឆ្លងកាត់។ប្រសិនបើមានការចុះចតដោយមិន បានកំណត់ពេលនៅលើដែនដីនៃភាគីដែលត្រូវឆ្លងកាត់ ភាគីទីបីត្រូវផ្តល់ជូននូវ សំណើសម្រាប់ការឆ្លងកាត់ដែលបានចែងនៅក្នុងកថាខណ្ឌ ១ នៃមាត្រានេះ។



# ពាក្យសុំឆ្លងកាត់ (ត)

3. នៅពេលដែលទទួលបានសំណើសុំការអនុញ្ញាតឆ្លងកាត់ ភាគីឆ្លងកាត់ត្រូវ ផ្តល់ជូនការអនុញ្ញាតឲ្យឆ្លងកាត់ លើកលែងតែមានហេតុផលដែលមាន មូលដ្ឋាននៃការបដិសេធសមស្រប។
4. ការអនុញ្ញាត្តិក្នុងការឆ្លងកាត់នេះ ត្រូវស្របតាមច្បាប់នៃភាគីទទួលសំណើ ដោយរាប់បញ្ចូលទាំងការអនុញ្ញាត្តិចំពោះបុគ្គលដែលជាប់ឃុំឃាំងក្នុងការ ឆ្លងកាត់។
5. នៅពេលបុគ្គលដែលជាប់ឃុំឃាំង ដូចដែលមានចែងនៅក្នុងចំណុច៤ ខាង លើ ដែនដីនៃភាគីដែលបុគ្គលស្នើសុំកំពុងស្ថិតនៅ អាចនឹងធ្វើការដោះលែង ប្រសិនបើការដឹកជញ្ជូនមិនបានបន្តក្នុងកំឡុងពេលសមស្របមួយ។
6. ភាគីដែលបុគ្គលស្នើសុំបាននឹងកំពុងបញ្ជូនត្រូវផ្តល់សំណងដល់ភាគីម្ខាង ទៀត សម្រាប់ការចំណាយដែលពាក់ព័ន្ធនឹងការឆ្លងកាត់។ បុគ្គលនោះបាន ចាកចេញពីដែនដីនៃភាគីធ្វើសំណើ បន្ទាប់ពីការធ្វើបត្យាប័នហើយបាន ត្រលប់មកដែនដីវិញដោយស្ម័គ្រចិត្ត។

## ឧបសម្ព័ន្ធទី ២


ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
ក្រសួងយុត្តិធម៌
បទបង្ហាញ
ស្ដីពី
បត្យាប័ន
ក្រសួងយុត្តិធម៌
ឆ្នាំ ២០២២


មាតិកា
១. និយមន័យ និងគោលបំណង
២. ក្របខណ្ឌក្នុងការធ្វើបត្យាប័ន
៣. បត្យាប័នតាមសន្ធិសញ្ញា
៤.បត្យាប័នក្នុងករណីពុំមានសន្ធិសញ្ញា
៥.លក្ខខណ្ឌ និងនីតិវិធីនៃបត្យាប័ន
2

## ពាក្យគន្លឹះ

- រដ្ឋដាក់សំណើ ឬរដ្ឋផ្ញើសំណើ៖ រដ្ឋដែលជាអ្នកស្នើសុំធ្វើបត្យាប័ន

- រដ្ឋទទួលសំណើ៖ រដ្ឋដែលទទួលបានសំណើសុំធ្វើបត្យាប័ន

- សន្ធិសញ្ញា៖ កិច្ចព្រមព្រៀងអន្តរជាតិដែលធ្វើឡើងរវាងរដ្ឋនិងរដ្ឋ នៅក្នុងទម្រង់ជាលាយលក្ខណ៍អក្សរ

3

## និយមន័យ

- បត្យាប័ន គឺជានីតិវិធីនៃការប្រគល់ខ្លួនបុគ្គលម្នាក់ដោយរដ្ឋ (រដ្ឋទទួលសំណើ) ទៅឱ្យអាជ្ញាធររបស់រដ្ឋមួយផ្សេងទៀត (រដ្ឋដាក់សំណុំ)ក្នុងគោលបំណងដើម្បី យកជននោះមកធ្វើការចោទប្រកាន់ចំពោះមុខយុត្តាធិការរបស់ខ្លួន ឬយកជននោះ មកអនុវត្តទោសនៅក្នុងប្រទេសរបស់ខ្លួន។
- បត្យាប័នកើតមានឡើងនៅពេលដែលរដ្ឋមួយដែលជាអ្នកស្នើសុំ ហៅថារដ្ឋដាក់ សំណើ ឬរដ្ឋផ្ញើសំណើ បានធ្វើការស្នើសុំទៅរដ្ឋមួយផ្សេងទៀត ដើម្បីធ្វើបត្យាប័ន ដែលរដ្ឋនោះហៅថារដ្ឋទទួលសំណើ។

4

## ក្របខ័ណ្ឌច្បាប់នៃការធ្វើបត្យាប័នមានបីយ៉ាងគឺ ៖

- ក្របខ័ណ្ឌនៃបត្យាប័នពិសេសៈ ត្រូវអនុលោមទៅតាមសន្ធិសញ្ញាស្តីពីបត្យាប័នដែលកម្ពុជាបានផ្តល់សច្ចាប័ន។ ប្រសិនបើមានសន្ធិសញ្ញាគឺសន្ធិសញ្ញានេះបានចែងនីតិវិធីលម្អិតអំពីការធ្វើបត្យាប័នហើយបត្យាប័ននេះត្រូវអនុវត្តតាមសន្ធិសញ្ញានោះ។
- ក្របខ័ណ្ឌនៃបត្យាប័នតាមក្រមនីតិវិធីព្រហ្មទណ្ឌៈ នៅពេលដែលមិនមានសន្ធិសញ្ញាស្តីពីបត្យាប័នជាមួយរដ្ឋធ្វើសំណើបត្យាប័នទេជាគោលការណ៍ត្រូវអនុវត្តតាមនីតិវិធីរួមស្តីពីបត្យាប័នដែលមានចែងក្នុងក្រមនីតិវិធីព្រហ្មទណ្ឌ។ ដូចនេះប្រទេសមួយចំនួនដែលមិនមានសន្ធិសញ្ញាស្តីពីបត្យាប័នជាមួយកម្ពុជាបើមានការស្នើសុំធ្វើបត្យាប័នត្រូវអនុវត្តតាមលក្ខខណ្ឌដែលមានចែងក្នុងក្រមនីតិវិធីព្រហ្មទណ្ឌ។
- ក្របខ័ណ្ឌដែលមានចែងក្នុងបទប្បញ្ញត្តិពិសេសៈ ក្នុងករណីដែលមានច្បាប់ពិសេសស្តីពីបត្យាប័នគឺត្រូវអនុវត្តតាមនីតិវិធីនៃបត្យាប័នទៅតាមច្បាប់ពិសេសនោះ (មាត្រា ៥៦៧ ក្រមនីតិវិធីព្រហ្មទណ្ឌ)។



## ក្របខ័ណ្ឌច្បាប់ផ្សេងទៀត

មាត្រា៣នៃសន្ធិសញ្ញាគំរូរបស់អង្គការសហប្រជាជាតិស្តីពីការធ្វើបត្យាប័ន បានចែងថា ការធ្វើបត្យាប័នមិនត្រូវបានអនុញ្ញាត ប្រសិនបើបុគ្គលដែលត្រូវបានស្នើសុំឲ្យធ្វើបត្យាប័ន អាចពាក់ព័ន្ធនឹងការដាក់ទណ្ឌកម្ម ហើយការធ្វើបត្យាប័នអាចនឹងត្រូវបានបដិសេធ ប្រសិនបើរដ្ឋដែលត្រូវបានស្នើសុំ ចាត់ទុកថា បទល្មើសដែលត្រូវស្នើឱ្យមានការធ្វើបត្យាប័នមានពាក់ព័ន្ធនឹងនយោបាយ ឬយោធា ។ រដ្ឋដែលត្រូវបានស្នើឲ្យធ្វើបត្យាប័ន ត្រូវបដិសេធសំណើសុំធ្វើបត្យាប័ន ប្រសិនបើរដ្ឋដែលធ្វើការស្នើសុំ មានការកាត់ទោសប្រហារជីវិតចំពោះបទល្មើស លុះត្រាតែមានការធានាថា នឹងមិនមានការអនុវត្តការកាត់ទោសប្រហារជីវិត។ ក្នុងករណីបែបនេះ សេចក្តីសម្រេចថា មិនធ្វើបត្យាប័នមានលក្ខណៈស្របច្បាប់។

ទោះបីជាច្បាប់អន្តរជាតិ មិនបានផ្តល់កាតព្វកិច្ចឱ្យរដ្ឋធ្វើបត្យាប័នក៏ដោយ ក៏សន្ធិសញ្ញាគំរូរបស់អង្គការសហប្រជាជាតិ ស្តីពីការធ្វើបត្យាប័ន (សន្ធិសញ្ញាគំរូរបស់ អ.ស.ប) បានចែងអំពីគំរូសម្រាប់ច្បាប់ជាតិ និងកិច្ចព្រមព្រៀងទ្វេភាគីដែលពាក់ព័ន្ធនឹងការធ្វើបត្យាប័ន ព្រមទាំង មានបំណងចែងអំពីប្រទេសដែលមានមូលដ្ឋានបែបនេះ ដើម្បីធានាថា ដំណើរដំណើរការនៃការធ្វើបត្យាប័នឆ្លុះបញ្ចាំងអំពីកាតព្វកិច្ចសិទ្ធិមនុស្សអន្តរជាតិ។

**បត្យាប័នតាមសន្ធិសញ្ញា**

- បត្យាប័នកើតមានឡើងបានលុះត្រាតែមានការព្រមព្រៀងរវាងរដ្ឋ និងរដ្ឋ។ ទន្ទឹមនឹងនេះ ការព្រមព្រៀងនេះ គឺពឹងផ្អែកទៅលើឆន្ទៈរបស់រដ្ឋទទួលសំណើ ក្នុងការផ្ទេរបុគ្គលម្នាក់ឱ្យទៅរដ្ឋដាក់សំណើ។
- សន្ធិសញ្ញាស្តីពីបត្យាប័នត្រូវធ្វើឡើងតាមរយៈការចរចាគ្នាដើម្បីកំណត់នូវនីតិវិធីសមស្រប និងកំណត់នូវបទល្មើសទាំងឡាយណាដែលអនុញ្ញាតិឱ្យធ្វើបត្យាប័នបានឬមិនបាន។
- សន្ធិសញ្ញាទាក់ទងនឹងការធ្វើបត្យាប័ននេះ បានផ្តល់នូវភាពងាយស្រួលជាច្រើនដល់រដ្ឋជាភាគីតាមរយៈការឱ្យរដ្ឋជាភាគីបានដឹងជាមុន នូវនីតិវិធីក្នុងការធ្វើបត្យាប័ន ព្រមទាំងដែនអនុវត្តខ្លះដែលរដ្ឋ ជាភាគីបានធ្វើការព្រមព្រៀងគ្នានៅក្នុងសន្ធិសញ្ញា។



ព្រះរាជាណាចក្រកម្ពុជាមានសន្ធិសញ្ញាស្តីពីបត្យាប័នជាមួយរដ្ឋបរទេសៈ

- សាធារណរដ្ឋវៀតណាម
- ព្រះរាជាណាចក្រថៃ
- សាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ
- សាធារណរដ្ឋកូរ៉េ
- សាធារណរដ្ឋប្រជាមានិតចិន
- សាធារណរដ្ឋបារាំង
- សហព័ន្ធរុស្ស៊ី

## បត្យាប័នក្នុងករណីពុំមានសន្ធិសញ្ញា

មិនមានច្បាប់ ឬគោលការណ៍ណាមួយហាមឃាត់មិនឱ្យធ្វើបត្យាប័ន ដោយគ្មានសន្ធិសញ្ញាបត្យាប័ននោះទេ បានន័យថា ការធ្វើបត្យាប័នមិនចាំបាច់ទាមទារឱ្យធ្វើឡើងតាមរយៈសន្ធិសញ្ញាបត្យាប័ននោះទេ។ ការធ្វើបត្យាប័ន ជាពិសេស គឺ ត្រូវតែពឹងផ្អែកលើឆន្ទៈជួយគ្នាទៅវិញទៅមក... និងមនោសញ្ចេតនារបស់ប្រទេសជាដៃគូ... ដើម្បីបង្ក្រាបបទល្មើសដែលកើតមានលើទឹកដីរបស់ខ្លួន ព្រមទាំងធានាបាននូវគុណភាពនៃការធ្វើ បត្យាប័នប្រកបដោយភាតរភាព និងនិរន្តរភាព។ប្រទេសមួយចំនួនដែលមិនមានសន្ធិសញ្ញាបត្យាប័ន ក៍បានចែងពីឆន្ទៈរបស់ខ្លួន ក្នុងការធ្វើបត្យាប័នតាមរយៈ ច្បាប់ជាតិរបស់ខ្លួន គោលការណ៍បដិការ ក្នុងគោលបំណងដើម្បីជាប្រយោជន៍ដល់សហគមន៍អន្តរជាតិ ដូចជាប្រទេសដទៃទៀតដែលជាប្រទេសដាក់សំណើ។

ព្រះរាជាណាចក្រកម្ពុជាពុំមានច្បាប់ស្តីពីបត្យាប័នទេ ប៉ុន្តែមានបញ្ញត្តមួយចំនួនដែលទាក់ទងនឹងបត្យាប័នដែលមានចែងក្នុងក្រមនីតិវិធីព្រហ្មទណ្ឌ។



## បត្យាប័នក្នុងករណីពុំមានសន្ធិសញ្ញា (ត)

- ព្រះរាជាណាចក្រកម្ពុជា មានសិទ្ធិក្នុងការធ្វើសំណើបត្យាប័នទៅរដ្ឋដែលបុគ្គលម្នាក់ ឬ ច្រើននាក់ស្នាក់នៅបាន ក្នុងករណីដែលបុគ្គលនោះបានប្រព្រឹត្តិបទល្មើសក្នុងដែនដីនៃព្រះរាជាណាចក្រកម្ពុជា ហើយក្រោយមកជនល្មើសបានទៅស្នាក់នៅប្រទេសដទៃទៀត ដើម្បីគេចខ្លួន និងរួច ផុតពីការទទួលខុសត្រូវ ទោះជាបុគ្គលនោះមានសញ្ញាតិខ្មែរ ឬបរទេសក៍ដោយ។
- អាជ្ញាធរកណ្តាល គឺក្រសួងយុត្តិធម៌។ អាជ្ញាធរកណ្តាលនេះបានដើរតួយ៉ាងសំខាន់ក្នុងការសម្របសម្រួលលើបញ្ហាបត្យាប័ន ជាពិសេសគឺជាអ្នករៀបចំ និងត្រួតពិនិត្យក្នុងការធ្វើសំណើបត្យាប័ន។

## លក្ខខណ្ឌក្នុងការធ្វើបត្យាប័ន

- លក្ខខណ្ឌទាក់ទងនឹងបទល្មើស៖ ការធ្វើបត្យាប័នបានលុះត្រាតែបទល្មើសនោះមានចែងក្នុងច្បាប់នៃរដ្ឋធ្វើសំណើផង និងរដ្ឋទទួលសំណើផង ទោះបីជាឈ្មោះនៃបទល្មើស ឬធាតុផ្សំ ឬពាក្យបច្ចេកទេសនៃបទល្មើសនោះខុសគ្នាក៏ដោយ។
- លក្ខខណ្ឌទាក់ទងនឹងបុគ្គលដែលត្រូវធ្វើបត្យាប័ន៖ ជាចារីផ្ទាល់ ឬអ្នកសមគំនិតក្នុងបទល្មើស
- លក្ខខណ្ឌដែលទាក់ទងនឹងទោសដាក់ពន្ធនាគារ៖ លុះត្រាតែបទល្មើសនោះមានចែងទោសដាក់ពន្ធនាគារអតិបរមាលើសពី ២ ឆ្នាំ ឬជននេះត្រូវបានតុលាការនៃរដ្ឋស្នើសុំផ្តន្ទាទោសរួចហើយដែលមានទោសលើសពី ៦ ខែក៏អាចធ្វើបត្យាប័នបានដែរ។



## លក្ខខណ្ឌក្នុងការធ្វើបត្យាប័ន (ត)

- លក្ខខណ្ឌទាក់ទងនឹងទីកន្លែងនៃការប្រព្រឹត្តបទល្មើស៖ បទល្មើសត្រូវបានប្រព្រឹត្តនៅលើទឹកដីនៃរដ្ឋដាក់សំណើ ទោះបីជនល្មើសមិនមានសញ្ជាតិនៃរដ្ឋដាក់សំណើក៏ដោយ ឬជនល្មើសមានសញ្ជាតិរបស់រដ្ឋដាក់សំណើទោះបីបទល្មើសនោះត្រូវបានប្រព្រឹត្តនៅក្រៅដែនដីនៃរដ្ឋដាក់សំណើក៏ដោយ។
- លក្ខខណ្ឌទាក់ទងនឹងបទល្មើសដែលអាចជាកម្មវត្ថុនៃការធ្វើបត្យាប័ន៖ លុះត្រាតែបទល្មើសនេះជាបទល្មើសនៃនីតិព្រហ្មទណ្ឌពោលគឺមិនមែនជាអំពើមានលក្ខណៈជានយោបាយ ឬការរើសអើងពូជសាសន៍ ឬសាសនា។
- លក្ខខណ្ឌទាក់ទងនឹងពាក្យសុំ៖ កម្ពុជាធ្វើបត្យាប័នផ្តល់ជូនជនដែលត្រូវបានគេស្នើសុំបានលុះត្រាតែរដ្ឋបរទេសនោះសន្យាថាមិនចោទប្រកាន់បទល្មើសផ្សេងទៀតទៅលើបុគ្គលនេះទេ។

## នីតិវិធីក្នុងការធ្វើបត្យាប័ន (ត)

- ពាក្យសុំធ្វើបត្យាប័ន៖ រដ្ឋធ្វើសំណើត្រូវដាក់ពាក្យសុំធ្វើបត្យាប័នជូនរដ្ឋាភិបាលកម្ពុជាតាមផ្លូវទូតដោយភ្ជាប់មកជាមួយភ័ស្តុតាងរួមមាន៖ ឯកសារដែលមានលក្ខណៈគ្រប់គ្រាន់ក្នុងការកំណត់អត្តសញ្ញាណបុគ្គលដែលគេទាមទារធ្វើបត្យាប័ន,របាយការណ៍អំពីអង្គហេតុដែលត្រូវចោទប្រកាន់,លិខិតចម្លងនៃសេចក្តីសម្រេចផ្តន្ទាទោសប្រសិនបើមាន និងឯកសារទាំងអស់ត្រូវចុះហត្ថលេខាបោះត្រាផ្លូវការ និងបិទស្រោម។

- ការទទួលពាក្យសុំធ្វើបត្យាប័ន៖ រដ្ឋមន្ត្រីក្រសួងការបរទេសកម្ពុជាត្រូវបញ្ជូនពាក្យសុំទៅរដ្ឋមន្ត្រីក្រសួងយុត្តិធម៌ដើម្បីផ្ទៀងផ្ទាត់មើលនិយតភាពនៃពាក្យសុំធ្វើបត្យាប័នបន្ទាប់មករដ្ឋមន្ត្រីក្រសួងយុត្តិធម៌បញ្ជូនពាក្យសុំនោះទៅអគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍។

- រដ្ឋធ្វើសំណើអាចសុំឱ្យចាប់ខ្លួនបណ្តោះអាសន្ននូវបុគ្គលដែលទាមទារហើយអគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍អាចចេញបញ្ជាឲ្យចាប់ និងឃុំខ្លួនជនដែលជាកម្មវត្ថុនៃការធ្វើបត្យាប័នបាន។



## នីតិវិធីក្នុងការធ្វើបត្យាប័ន

- អគ្គព្រះរាជអាជ្ញារៀបចំសំណុំរឿងដើម្បីប្តឹងទៅសភាស៊ើបសួរនៃសាលាឧទ្ធរណ៍

- នីតិវិធីនៅចំពោះមុខសភាស៊ើបសួរ៖ បុគ្គលដែលគេទាមទារត្រូវបង្ហាញខ្លួននៅចំពោះមុខសភាស៊ើបសួរដែលមានចៅក្រម ៣ រូប។ ការពិភាក្សាដេញដោលនៅសាលសវនាការអសាធារណៈ។ បន្ទាប់ពីស្តាប់ចម្លើយបុគ្គលដែលគេទាមទារសេចក្តីសន្និដ្ឋានរបស់អគ្គព្រះរាជអាជ្ញាសេចក្តីសន្និដ្ឋានការពាររបស់មេធាវីរួចមកសភាស៊ើបសួរផ្តល់យោបល់ជាសាលដីកាលើពាក្យសុំធ្វើបត្យាប័ននោះ។

**យោបល់របស់សភាស៊ើបសួរ**

ក- មិនយល់ព្រមប្រសិនបើយល់ឃើញថាលក្ខខណ្ឌច្បាប់នៃបត្យាប័នមិនត្រូវបានបំពេញត្រូវដោះលែងបុគ្គលដែលគេទាមទារ

ខ- បើយល់ព្រមឱ្យធ្វើបត្យាប័នសភាស៊ើបសួរត្រូវជូនដំណឹងភ្លាមទៅរដ្ឋមន្ត្រីក្រសួងយុត្តិធម៌ដើម្បីបញ្ជូនរឿងនេះទៅរាជរដ្ឋាភិបាលដើម្បីចេញអនុក្រឹត្យបង្គាប់ឱ្យធ្វើបត្យាប័នប្រគល់បុគ្គលដែលគេទាមទារទៅរដ្ឋស្នើសុំ។

# ឧបសម្ព័ន្ធទី ៣

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងយុត្តិធម៌**
**អគ្គនាយកដ្ឋានកិច្ចការអយ្យការ និងព្រហ្មទណ្ឌ**
**នាយកដ្ឋានជំនួយទៅវិញទៅមកក្នុងវិស័យ**
**ព្រហ្មទណ្ឌ និងបត្យាប័ន**

លេខ៖ . . . . . . . . . . . . . . . .

**សូមគោរពជូន**

**ឯកឧត្តម រដ្ឋមន្ត្រីក្រសួងយុត្តិធម៌**

**កម្មវត្ថុ** ៖ អំពីសំណើសុំធ្វើបត្យាប័នឈ្មោះ ពីប្រទេសឡាវ ដើម្បីនាំខ្លួនមកផ្តន្ទាទោសនៅប្រទេសកម្ពុជា។

**យោង** ៖ លិខិតលេខ ២០៨៥ លស ចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ២០១៨ របស់ក្រសួងមហាផ្ទៃ។

**<u>កំណត់បង្ហាញរឿង</u>**

សេចក្តីដូចមានចែងក្នុងកម្មវត្ថុ និងយោងខាងលើ ខ្ញុំសូមគោរពជម្រាបជូន ឯកឧត្តមរដ្ឋមន្ត្រី មេត្តាជ្រាបថា ក្រសួងយុត្តិធម៌បានទទួលលិខិតរបស់ក្រសួងមហាផ្ទៃដែលមានកម្មវត្ថុស្នើសុំធ្វើបត្យាប័ន ឈ្មោះ ភេទប្រុស កាន់អត្តសញ្ញាណប័ណ្ណ មានទីលំនៅបច្ចុប្បន្ននៅផ្ទះលេខ សង្កាត់បឹងសាឡាង ខណ្ឌទួលគោក រាជធានីភ្នំពេញ ជានីតិជន ដោយសារបុគ្គលរូបនេះ ត្រូវបានចៅក្រមស៊ើបសួរនៃសាលាដំបូងរាជធានីភ្នំពេញចេញដីកាបង្គាប់ឲ្យចាប់ខ្លួន លេខ ចុះថ្ងៃទី១១ ខែកក្កដា ឆ្នាំ២០១៧ ពីបទ **ឆបោក** តាមមាត្រា ៣៧៧ និង៣៧៨ នៃក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ប្រព្រឹត្តនៅរាជធានីភ្នំពេញ កាលពីឆ្នាំ២០១៣។ កាលពីថ្ងៃទី៣១ ខែមករា ឆ្នាំ២០១៨ ការិយាល័យនគរបាលអន្តរជាតិទីក្រុងវៀងច័ន្ទ ប្រទេសឡាវ បានជូនដំណឹងអំពីការចាប់ខ្លួនឈ្មោះ កាន់លិខិតឆ្លងដែនលេខ ដែលត្រូវបានចាប់ខ្លួនកាលពីថ្ងៃទី២៩ ខែមីនា ឆ្នាំ២០១៧ ពីបទឆបោកប្រជាជនឡាវ តាមបញ្ញត្តមាត្រា ១២០ នាំក្រមព្រហ្មទណ្ឌឡាវ និងបានឃុំខ្លួនចាប់ពីថ្ងៃទី០៦ ខែមេសា ឆ្នាំ២០១៧ ដល់បច្ចុប្បន្ននៅពន្ធនាគារ PHONTONG ទីក្រុងវៀងច័ន្ទ ប្រទេសឡាវ។ ដោយហេតុថា ជនត្រូវចោទ បានប្រព្រឹត្តបទល្មើសនៅកម្ពុជា ដោយក្រុមហ៊ុន EBC និងមានដីកាបង្គាប់ឲ្យចាប់ខ្លួនរបស់សាលាដំបូងរាជធានីភ្នំពេញ ដូចនេះ ក្រសួងមហាផ្ទៃស្នើសុំធ្វើបត្យាប័នជនត្រូវចោទរូបនេះពីប្រទេសឡាវ យកមកផ្តន្ទាទោសតាមច្បាប់ជាធរមាននៅព្រះរាជាណាចក្រកម្ពុជា។

តាមសន្ធិសញ្ញារវាងព្រះរាជាណាចក្រកម្ពុជា និងសាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ ស្តីពី បត្យាប័ន៖

- ប្រការទី១៖ ដោយអនុលោមតាមបទប្បញ្ញត្តិទាំងឡាយនៃសន្ធិសញ្ញានេះ ភាគីចុះកិច្ចព្រមព្រៀងមានភារកិច្ចធ្វើបត្យាប័នទៅភាគីម្ខាងទៀតនូវជនទាំងឡាយណា ដែលត្រូវបានឃើញនៅលើដែនដីនៃភាគីចុះកិច្ចព្រមព្រៀងណាមួយ ហើយជនទាំងនោះកំពុងត្រូវគេតាមចាប់ខ្លួន ដើម្បីធ្វើការចោទប្រកាន់ ដើម្បីធ្វើការជំនុំជម្រះក្តី ឬដើម្បីឲ្យទទួលទោស ឬអនុវត្តទណ្ឌកម្មតាមទោសកំណត់ នៅលើទឹកដីរបស់ភាគីម្ខាងទៀត ចំពោះបទល្មើសដែលអាចធ្វើបត្យាប័នបានណាមួយ។

- ប្រការទី២ កថាខណ្ឌទី១ ៖ ក្នុងស្មារតីនៃសន្ធិសញ្ញានេះ បទល្មើសដែលអាចធ្វើបត្យាប័នបាន គឺជាបទល្មើសដែលអាចផ្តន្ទាទោសតាមធរមាននៃច្បាប់របស់ភាគីចុះកិច្ចព្រមព្រៀងទាំងពីរ ដោយការដាក់ពន្ធនាគារ ឬដោយរូបភាពផ្សេងទៀតនៃការឃុំឃាំងសម្រាប់រយៈពេលលើសពីមួយឆ្នាំឡើងទៅ ឬការផ្តន្ទាទោសណាមួយដែលធ្ងន់ជាងនេះ។

- ប្រការទី៧ ចែងថា៖

១-សំណើបត្យាប័នត្រូវធ្វើជាលាយលក្ខណ៍អក្សរ ហើយត្រូវភ្ជាប់ជាមួយនូវ៖

ក-ឯកសារសេចក្តីបញ្ជាក់ ឬភស្តុតាងដទៃទៀត មានលក្ខណៈគ្រប់គ្រាន់សម្រាប់ពិពណ៌នាអំពីអត្តសញ្ញាណ និងទីកន្លែងប្រហាក់ប្រហែលដែលជនត្រូវស្នើសុំកំពុងស្នាក់នៅ

ខ-សេចក្តីបញ្ជាក់លើអង្គហេតុនៃបណ្តឹងក្តី

គ-រាល់បទបញ្ញត្តិនៃច្បាប់ ដែលពិពណ៌នាអំពីធាតុសំខាន់ៗ និងការកំណត់នៃបទល្មើសដែលជាកម្មវត្ថុនៃបត្យាប័ន

ឃ-រាល់បទប្បញ្ញត្តិនៃច្បាប់ដែលចែងពីការផ្តន្ទាទោសទៅលើបទល្មើស និង

ង-រាល់បទប្បញ្ញត្តិនៃច្បាប់ ដែលចែងពីការកំណត់ពេលនៃការចោទប្រកាន់ ឬការអនុវត្តទណ្ឌកម្មចំពោះបទល្មើសប្រសិនបើមាន។

២-សំណើបត្យាប័ន ដែលទាក់ទងនឹងជនដែលត្រូវបានស្នើសុំ ដើម្បីចោទប្រកាន់ ត្រូវជាមួយផងដែរនូវ៖

ក-សេចក្តីចម្លងនៃដីកាចាប់ខ្លួន ដែលចេញដោយចៅក្រម ឬអាជ្ញាធរមានសមត្ថកិច្ចដទៃទៀតរបស់ ភាគីដាក់សំណើ។

ខ-ភស្តុតាងដែលអាចសំអាងបានសម្រាប់ការចាប់ខ្លួន និងការឃុំខ្លួនដើម្បីរង់ចាំការជំនុំជម្រះក្តីរបស់ជននោះដោយរាប់បញ្ចូលទាំងភស្តុតាងដែលបញ្ជាក់ថា ជនដែលត្រូវស្នើសុំពិតជាជនដែលកំណត់ក្នុងដីកាចាប់ខ្លួន ។

៤-រាល់ឯកសារទាំងអស់ដែលភាគីដាក់សំណើ ត្រូវបញ្ជូនឲ្យក្នុងក្របខណ្ឌនៃបទប្បញ្ញត្តិនៃសន្ធិសញ្ញានេះ ត្រូវចុះហត្ថលេខា ឬបោះត្រាជាផ្លូវការ និងភ្ជាប់មកជាមួយនូវអត្ថបទបកប្រែជាភាសានៃភាគីទទួលសំណើ ឬជាភាសាអង់គ្លេស។

តាមក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា៖

- មាត្រា ៣៧៧ និយមន័យនៃការឆបោក៖ អំពើឆបោក គឺជាអំពើបន្លំចំពោះរូបវន្តបុគ្គល ឬនីតិបុគ្គលណាមួយដោយប្រើឈ្មោះក្លែង ដោយអះអាងទៅលើឋានៈក្លែង ដោយរំលោភលើឋានៈពិតប្រាកដ ឬដោយប្រើឧបាយកលទុច្ចរិតហើយដូច្នេះបានទទួលពីបុគ្គលនេះ ដែលនាំឲ្យខូចប្រយោជន៍របស់បុគ្គលនេះ ឬរបស់តតិយជននូវ (១) ការប្រគល់មូលនិធិតម្លៃ ឬទ្រព្យសម្បត្តិអ្វីមួយ (២) ការផ្គត់ផ្គង់សេវា (៣) ការធ្វើលិខិតដែលមានតម្លៃជាកាតព្វកិច្ច ឬជាការឲ្យរួចពីកាតព្វកិច្ច។

- មាត្រា ៣៧៨ ទោសដែលត្រូវអនុវត្ត៖ អំពើឆបោកត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ៦ (ប្រាំមួយ) ខែ ទៅ ៣ (បី) ឆ្នាំ និងពិន័យជាប្រាក់ពី ១.០០០.០០០ (មួយលាន) រៀល ទៅ ៦.០០០.០០០ (ប្រាំមួយលាន) រៀល។

**<u>ពាក់ព័ន្ធនឹងករណីនេះ ពិនិត្យឃើញថា៖</u>**

- ព្រះរាជាណាចក្រកម្ពុជា និងប្រទេសឡាវ មានសន្ធិសញ្ញារវាងព្រះរាជាណាចក្រកម្ពុជា និងសាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ ស្តីពីបត្យាប័ន
- ជនត្រូវចោទ ឈ្មោះ មានសញ្ជាតិខ្មែរ ត្រូវបានចៅក្រមស៊ើបសួរនៃសាលាដំបូងរាជធានីភ្នំពេញ ចេញដីកាបង្គាប់ឲ្យចាប់ខ្លួន លេខ ចុះថ្ងៃទី១១ ខែកក្កដា ឆ្នាំ២០១៧ ពីបទ **ឆបោក** តាមមាត្រា ៣៧៧ និង ៣៧៨ នៃក្រមព្រហ្ម-ទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ប្រព្រឹត្តនៅរាជធានីភ្នំពេញ កាលពីឆ្នាំ២០១៣ ដែលត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ៦ (ប្រាំមួយ) ខែ ទៅ ៣ (បី) ឆ្នាំ ហើយបទល្មើសនេះ ក៏ជាបទឆបោក តាមបញ្ញត្តមាត្រា ១២០ នៃក្រមព្រហ្មទណ្ឌឡាវផងដែរ និងបានឃុំខ្លួនចាប់ពីថ្ងៃទី០៦ ខែមេសា ឆ្នាំ២០១៧ ដល់បច្ចុប្បន្ននៅពន្ធនាគារ PHONTONG ទីក្រុងវៀងច័ន្ទ ប្រទេសឡាវ ដោយអនុលោមតាមប្រការទី១ និងទី២ កថាខណ្ឌទី១ នៃសន្ធិសញ្ញា។
- ឯកសារដែលក្រសួងមហាផ្ទៃបានភ្ជាប់មកបញ្ជាក់ថាជនត្រូវចោទ ឈ្មោះ មានសញ្ជាតិខ្មែរ កំពុងជាប់ឃុំនៅពន្ធនាគារ PHONTONG ទីក្រុងវៀងច័ន្ទ ប្រទេសឡាវ។ ជាមួយគ្នានេះ ជននេះបានប្រព្រឹត្តបទល្មើសឆបោកនៅកម្ពុជា ដោយក្រុមហ៊ុន EBC តាមមាត្រា ៣៧៧ និង៣៧៨ នៃក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា និងមានភ្ជាប់នូវដីកាបង្គាប់ឲ្យចាប់ខ្លួន លេខ៤២៧ ដ.ច.ន ចុះថ្ងៃទី១១ ខែកក្កដា ឆ្នាំ២០១៧ របស់សាលាដំបូងរាជធានីភ្នំពេញ ប៉ុន្តែមិនបានភ្ជាប់នូវភស្តុតាងសំអាងផ្សេងទៀត ពាក់ព័ន្ធនឹងសំណុំរឿងរបស់ជនត្រូវចោទរូបនេះនោះទេ ដែលភស្តុតាងសំអាងពាក់ព័ន្ធនឹងការចាប់ខ្លួននេះ ជាតម្រូវការនៃការធ្វើបត្យាប័នផ្អែកតាមសន្ធិសញ្ញារវាងព្រះរាជាណាចក្រកម្ពុជា និងសាធារណរដ្ឋប្រជា-ធិបតេយ្យប្រជាមានិតឡាវ ស្តីពីបត្យាប័ន។
- កថាខណ្ឌទី៤ នៃសន្ធិសញ្ញារវាងព្រះរាជាណាចក្រកម្ពុជា និងសាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ ស្តីពីបត្យាប័ន ទាមទារនូវឯកសារចុះហត្ថលេខា ឬបោះត្រាផ្លូវការ តែដីកាបង្គាប់ឲ្យចាប់ខ្លួន លេខ៤២៧ ដ.ច.ន ចុះថ្ងៃទី១១ ខែកក្កដា ឆ្នាំ២០១៧ ដែលបានទទួលពីក្រសួងមហាផ្ទៃ មិនមែនជាច្បាប់ដើមនោះទេ។ ម្យ៉ាងវិញទៀត កថាខណ្ឌនេះ ក៏តម្រូវឲ្យធ្វើការបកប្រែឯកសារភ្ជាប់នឹងសំណើបត្យាប័នជាភាសានៃភាគីទទួលសំណើ ឬជាភាសាអង់គ្លេសផងដែរ។

សេចក្តីដូចបានគោរពជម្រាបជូនខាងលើ ក្រសួងគប្បី៖

- ធ្វើលិខិតទៅសាលាដំបូងរាជធានីភ្នំពេញ ដើម្បីធ្វើការពិនិត្យ និងរាយការណ៍អំពីព័ត៌មានលម្អិតដោយភ្ជាប់មកជាមួយឯកសារពាក់ព័ន្ធនឹងជនត្រូវចោទរូបនេះ ដើម្បីក្រសួងមានមូលដ្ឋានរៀបចំសំណើធ្វើបត្យាប័ន។
- ធ្វើការបកប្រែឯកសារភ្ជាប់នឹងសំណើបត្យាប័នជាភាសាអង់គ្លេស
- រៀបចំសំណើធ្វើបត្យាប័នជនត្រូវចោទ ឈ្មោះ ពីប្រទេសឡាវ មកផ្តន្ទាទោសនៅព្រះរាជាណាចក្រកម្ពុជា។

| មតិយោបល់ មន្ត្រីជំនាញ | មតិយោបល់ លោកស្រីប្រធាននាយកដ្ឋាន |
|---|---|
| សំណើសុំធ្វើបត្យាប័នជនត្រូវចោទ ពីប្រទេសឡាវ មកផ្តន្ទាទោសនៅព្រះរាជាណាចក្រកម្ពុជាក្រសួងគប្បីធ្វើលិខិតទៅសាលាដំបូងរាជធានីភ្នំពេញ ដើម្បីធ្វើការពិនិត្យ និងរាយការណ៍ អំពីព័ត៌មានលម្អិតដោយភ្ជាប់មកជាមួយឯកសារពាក់ព័ន្ធនឹងជនត្រូវចោទរូបនេះ ដើម្បីក្រសួងមានមូលដ្ឋានរៀបចំសំណើធ្វើបត្យាប័ន និងធ្វើការបកប្រែឯកសារភ្ជាប់នឹងសំណើបត្យាប័នជាភាសាអង់គ្លេស។ ម៉្យាងទៀត ក្រសួងគួររៀបចំសំណើធ្វើបត្យាប័នជនត្រូវចោទ ឈ្មោះ ហួត សុវណ្ណ ពីប្រទេសឡាវ មកផ្តន្ទាទោសនៅព្រះរាជាណាចក្រកម្ពុជា។<br>សូមគោរពជូនលោកស្រីប្រធាននាយកដ្ឋានមេត្តាពិនិត្យ និងសម្រេចដ៏ខ្ពង់ខ្ពស់។ | |

| មតិយោបល់ ឯកឧត្តមអគ្គនាយក |
|---|
| |

| មតិយោបល់ ឯកឧត្តមរដ្ឋលេខាធិការ | មតិយោបល់ ឯកឧត្តមរដ្ឋមន្ត្រី |
|---|---|
| | |